# កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី
# រវាង
# រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# និង
# រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន

# តារាងមាតិកា


បុព្វកថា

ជំពូក ១ បទប្បញ្ញត្តិទូទៅ និងនិយមន័យ

ជំពូក ២ ពាណិជ្ជកម្មទំនិញ

ជំពូក ៣ វិធានដើមកំណើត

ជំពូក ៤ នីតិវិធីគយ និងកិច្ចសម្រួលពាណិជ្ជកម្ម

ជំពូក ៥ របាំងបច្ចេកទេសលើការធ្វើពាណិជ្ជកម្ម

ជំពូក ៦ វិធានការអនាម័យ និងភូតគាមអនាម័យ

ជំពូក ៧ ពាណិជ្ជកម្មសេវាកម្ម

ជំពូក ៨ កិច្ចសហប្រតិបត្តិការវិនិយោគ

ជំពូក ៩ កិច្ចសហប្រតិបត្តិការក្រោមគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវ

ជំពូក ១០ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ជំពូក ១១ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស

ជំពូក ១២ តម្លាភាព

ជំពូក ១៣ បទប្បញ្ញត្តិ ស្តីពីរដ្ឋបាល និងស្ថាប័ន

ជំពូក ១៤ ដំណោះស្រាយវិវាទ

ជំពូក ១៥ ការលើកលែង

ជំពូក ១៦ អវសានប្បញ្ញត្តិ

# ឧបសម្ព័ន្ធ


ឧបសម្ព័ន្ធ ១ តារាងការសន្យាពន្ធគយ

ផ្នែក ក តារាងការសន្យាពន្ធគយរបស់ចិន

ផ្នែក ខ តារាងការសន្យាពន្ធគយរបស់កម្ពុជា

ឧបសម្ព័ន្ធ ២ វិធានផលិតផលជាក់លាក់

ឧបសម្ព័ន្ធ ៣ វិញ្ញាបនបត្រដើមកំណើត

ឧបសម្ព័ន្ធ ៤ តារាងសន្យាតាមវិស័យសម្រាប់ពាណិជ្ជកម្មសេវា

ផ្នែក ក តារាងសន្យាតាមវិស័យរបស់ភាគីចិន

ផ្នែក ខ តារាងសន្យាតាមវិស័យរបស់ភាគីកម្ពុជា

ឧបសម្ព័ន្ធ ៥ វិធាននីតិវិធីនៃវេទិកាមជ្ឈត្តកម្ម

# បុព្វកថា

រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ("ចិន") និងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") តទៅនេះហៅជារួមថា "ភាគីទាំងពីរ"៖

ដែលជំរុញដោយមិត្តភាពយូរអង្វែងរវាងភាគីទាំងពីរ និងការរីកចម្រើននៃទំនាក់ទំនងសេដ្ឋកិច្ចទ្វេភាគី ចាប់តាំងពីការបង្កើតទំនាក់ទំនងការទូតក្នុងឆ្នាំ ១៩៥៨

ក្នុងគោលបំណងពង្រឹងភាពជាដៃគូសេដ្ឋកិច្ចរវាងភាគីទាំងពីរ និងបង្កើនការធ្វើសេរីភាវូបនីយកម្ម ពាណិជ្ជកម្មទ្វេភាគី និងជំរុញការវិនិយោគ ដើម្បីជាឧត្តមប្រយោជន៍សេដ្ឋកិច្ច និងសង្គម

ដោយតាំងចិត្តបង្កើតវិធានសម្រាប់គ្រប់គ្រងពាណិជ្ជកម្ម និងវិនិយោគប្រកបដោយតម្លាភាព និងភាពអាចព្យាករណ៍បាន រវាងភាគីទាំងពីរ

ដោយមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការអនុវត្តកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយបែបប្រាកដនិយម ក្រោមគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវ និងរួមគ្នាបង្កើតសហគមន៍ដែលមានអនាគតរួមគ្នា

ដោយបន្ថែមលើសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាំងពីរ ក្រោមកិច្ចព្រមព្រៀងទីក្រុងម៉ារ៉ាកេសបង្កើតអង្គការ WTO

ដោយប្រកាន់ខ្ជាប់នូវសិទ្ធិស្វ័យសម្រេច របស់រដ្ឋាភិបាលភាគីទាំងពីរក្នុងការអនុវត្តគោលនយោបាយជាតិ និងរក្សានូវភាពបត់បែនក្នុងការការពារសុខុមាលភាពសាធារណៈ

ដោយទទួលស្គាល់ថាការពង្រឹងភាពជាដៃគូសេដ្ឋកិច្ចតាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនឹងផ្តល់ផលប្រយោជន៍ទៅវិញទៅមកដល់ភាគីទាំងពីរ

បានព្រមព្រៀងគ្នាដូចខាងក្រោម ៖

# ជំពូក ១
# បទប្បញ្ញត្តិទូទៅ និងនិយមន័យ

## មាត្រា ១.១ ការបង្កើតតំបន់ពាណិជ្ជកម្មសេរី

ភាគីទាំងពីរ បង្កើតតំបន់ពាណិជ្ជកម្មសេរី ដោយអនុលោមតាមមាត្រា XXIV នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម (GATT) ឆ្នាំ ១៩៩៤ និងមាត្រា V នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម (GATS) ។

## មាត្រា ១.២ ការពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងផ្សេងទៀត

ភាគីទាំងពីរ អះអាងអំពីសិទ្ធិ និងកាតព្វកិច្ចនានាដែលមានស្រាប់របស់ពួកគេក្រោមកិច្ចព្រមព្រៀងអង្គការ WTO និងកិច្ចព្រមព្រៀងជាធរមានផ្សេងទៀតដែលភាគីទាំងពីរជាហត្ថលេខី។

## មាត្រា ១.៣ វិសាលភាពនិងដែនអនុវត្ត

១. សម្រាប់ភាគីចិន កិច្ចព្រមព្រៀងនេះត្រូវអនុវត្តលើដែនដីគយទាំងមូល នៃសាធារណរដ្ឋប្រជាមានិតចិន ដែលរួមមានដែនដីគោក ដែនអាកាស ដែនទឹកផ្ទៃក្នុង ដែនសមុទ្រ និងតំបន់នានាដែលនៅហួសពីដែនសមុទ្រហើយដែលភាគីចិនអនុវត្តសិទ្ធិអធិបតេយ្យភាព ឬយុត្តាធិការ ក្រោមច្បាប់ជាតិដោយអនុលោមតាមច្បាប់អន្តរជាតិ។

២. សម្រាប់ភាគីកម្ពុជា កិច្ចព្រមព្រៀងនេះត្រូវអនុវត្តលើដែនអធិបតេយ្យភាពនៃព្រះរាជាណាចក្រកម្ពុជា និងតំបន់សមុទ្រ ដែលរួមមានខ្ពង់រាបបាតសមុទ្រ និងស្រទាប់ដីក្រោមបាតសមុទ្រ ដែលជាប់នឹងដែនសមុទ្រខាងក្រៅ និងដែនអាកាស ហើយដែលព្រះរាជាណាចក្រកម្ពុជាអនុវត្តសិទ្ធិអធិបតេយ្យភាព ឬយុត្តាធិការ ដោយអនុលោមតាមច្បាប់អន្តរជាតិ។

៣. ភាគីនីមួយៗ ទទួលខុសត្រូវទាំងស្រុងចំពោះការប្រតិបត្តិតាមរាល់បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ និងត្រូវមានវិធានការសមហេតុផលតាមការដែលអាចមាន សំដៅធានាថា អាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរក្នុងទឹកដីរបស់ខ្លួន ប្រតិបត្តិតាមបទប្បញ្ញត្តិទាំងនេះ។

## មាត្រា ១.៤ និយមន័យទូទៅ

លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ សម្រាប់គោលបំណង នៃកិច្ចព្រមព្រៀងនេះ គឺ៖

(ក) ថ្ងៃ មានន័យថា ថ្ងៃប្រតិទិន

(ខ) ដែលមានស្រាប់ មានន័យថា នៅជាធរមាន នៅកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះ ចូលជាធរមាន

(គ) GATS មានន័យថា កិច្ចព្រមព្រៀងទូទៅ ស្តីពីពាណិជ្ជកម្មសេវាកម្ម ដែលមាននៅក្នុងឧបសម្ព័ន្ធ ១(B) នៃកិច្ចព្រមព្រៀងអង្គការ WTO

(ឃ) GATT ១៩៩៤ មានន័យថា កិច្ចព្រមព្រៀងទូទៅ ស្តីពីពន្ធគយ និងពាណិជ្ជកម្ម ឆ្នាំ១៩៩៤ ដែលជាផ្នែកនៃកិច្ចព្រមព្រៀងអង្គការ WTO

(ង) **វិធានការ** មានន័យថា ច្បាប់ បទប្បញ្ញត្តិ នីតិវិធី លក្ខខណ្ឌតម្រូវ ការអនុវត្ត ក្នុងទម្រង់ផ្សេងៗ

(ច) បុគ្គល មានន័យថា រូបវន្តបុគ្គល ឬនីតិបុគ្គល

(ឆ) WTO មានន័យថាអង្គការពាណិជ្ជកម្មពិភពលោក និង

(ជ) **កិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក** មានន័យថា កិច្ចព្រមព្រៀងទីក្រុងម៉ារ៉ាកេស បង្កើតអង្គការពាណិជ្ជកម្មពិភពលោក ដែលបានធ្វើនៅទីក្រុងម៉ារ៉ាកេស នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៤។

# ជំពូក ២
# ពាណិជ្ជកម្មទំនិញ

## មាត្រា ២.១ វិសាលភាព

លើកលែងតែមានការចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ ជំពូកនេះអនុវត្តលើពាណិជ្ជកម្មទំនិញរវាងភាគីទាំងពីរ។

## មាត្រា ២.២ និយមន័យ

លើកលែងតែមានការបញ្ជាក់ផ្សេង សម្រាប់ជាគោលបំណងនៃជំពូកនេះ គឺ៖

**អត្រាមូលដ្ឋាននៃពន្ធគយ** មានន័យថា អត្រាពន្ធគយនាំចូលសម្រាប់ប្រជាជាតិដែលទទួលបានការអនុគ្រោះបំផុត (Most Favored Nation-MFN) បានអនុវត្តនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ ផ្តល់ដោយភាគីនីមួយៗ។

**ពន្ធគយ** រាប់បញ្ចូលពន្ធគយ ឬបន្ទុកផ្សេងពាក់ព័ន្ធនឹងការនាំចូលទំនិញ ប៉ុន្តែមិនរាប់បញ្ចូលនូវ៖

(ក) បន្ទុកផ្សេងៗ ដែលសមមូលនឹងពន្ធក្នុងស្រុកដែលត្រូវបង់ស្របនឹងមាត្រា III:2 នៃ GATT 1994

(ខ) ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ ឬពន្ធប៉ះប៉ូវដែលបានអនុវត្តស្របតាមមាត្រា VI នៃ GATT 1994 កិច្ចព្រមព្រៀងអង្គការ WTO ស្តីពីការអនុវត្តមាត្រា VI នៃ GATT 1994 ឬកិច្ចព្រមព្រៀងអង្គការ WTO ស្តីពីការឧបត្ថម្ភធននិងវិធានការប៉ះប៉ូវ និងពន្ធណាមួយបានអនុវត្តស្របតាមមាត្រា ២.៨ (វិធានការការពារជាសកល)

(គ) កម្រៃ ឬ បន្ទុកផ្សេងទៀតពាក់ព័ន្ធនឹងការនាំចូលដែលសមស្របនឹងថ្លៃសេវាបានប្រើប្រាស់។

**ទំនិញ និងផលិតផល** ត្រូវបានបកស្រាយក្នុងអត្ថន័យដូចគ្នា លើកលែងតែក្នុងបរិបទតម្រូវផ្សេងពីនេះ

**ភាពមានកំណើតដើម** មានន័យថា មានលក្ខណៈគ្រប់គ្រាន់ក្រោមវិធានដើមកំណើតដែលបានកំណត់ក្នុងជំពូក ៣ (វិធានដើមកំណើត)។

## មាត្រា ២.៣ ប្រព្រឹត្តិកម្មជាតិ

ភាគីនីមួយៗត្រូវផ្តល់ប្រព្រឹត្តិកម្មជាតិលើទំនិញនៃភាគីមួយទៀត ស្របតាមមាត្រា III នៃ GATT 1994 រាប់បញ្ចូលទាំងកំណត់សម្គាល់បកស្រាយ។ ក្នុងគោលបំណងនេះ មាត្រា III នៃ GATT 1994 និងកំណត់សម្គាល់បកស្រាយ ត្រូវបានដាក់បញ្ចូលនិងក្លាយជាផ្នែកនៃកិច្ចព្រមព្រៀងនេះ *និងត្រូវយកមកអនុវត្តតាមទាំងស្រុង*។

## មាត្រា ២.៤ ការកាត់បន្ថយនិង/ឬការលុបបំបាត់ពន្ធគយ

១. លើកលែងតែមានចែងផ្សេងក្នុងកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗត្រូវកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយលើទំនិញដែលមានដើមកំណើត នៃភាគីមួយទៀត នៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន ស្របតាមតារាងកម្មវិធីក្នុងឧបសម្ព័ន្ធ ១ (តារាងសន្យាពន្ធគយ)។

២. លើកលែងតែមានចែងផ្សេងក្នុងកិច្ចព្រមព្រៀងនេះ គ្មានភាគីណាមួយអាចដំឡើងពន្ធគយនាំចូលដែលមានស្រាប់ ឬអនុវត្តពន្ធគយថ្មី លើទំនិញដែលមានដើមកំណើត នៃភាគីមួយទៀតឡើយ។

៣. អត្រាមូលដ្ឋាននៃពន្ធគយសម្រាប់ផលិតផលនីមួយៗ ដែលប្រើជាគោលសម្រាប់កាត់បន្ថយបន្តបន្ទាប់ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ ១ (តារាងសន្យាពន្ធគយ) ត្រូវតែជាអត្រាពន្ធគយប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុតដែលអនុវត្តនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧។

៤. ប្រសិនបើភាគីមួយបានកាត់បន្ថយនូវអត្រាអនុវត្តនៃអត្រាពន្ធគយប្រជាជាតិដែលទទួលបានភាពអនុគ្រោះបំផុត (តទៅនេះហៅថា "MFN") ក្រោយពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន អត្រាពន្ធគយដែលបានកាត់បន្ថយនោះត្រូវយកមកអនុវត្តចំពោះការធ្វើពាណិជ្ជកម្មក្រោមកិច្ចព្រមព្រៀងនេះ ក្នុងករណីដែលអត្រាពន្ធគយនោះទាបជាងអត្រាពន្ធគយ យោងតាមតារាងឧបសម្ព័ន្ធ ១ (តារាងសន្យាពន្ធគយ)។

## មាត្រា ២.៥ ការពន្លឿនការអនុវត្តការសន្យាពន្ធគយ

១. តាមសំណើរបស់ភាគីណាមួយ ភាគីទាំងពីរត្រូវពិភាក្សាក្នុងការពិចារណាពន្លឿនការកាត់បន្ថយនិងការលុបបំបាត់ពន្ធគយលើទំនិញដែលមានដើមកំណើតដូចបានកំណត់ក្នុងតារាងកម្មវិធីរបស់ខ្លួនក្នុងឧបសម្ព័ន្ធ ១ (តារាងសន្យាពន្ធគយ)។

២. ការព្រមព្រៀងណាមួយដោយភាគីទាំងពីរក្នុងការពន្លឿនការកាត់បន្ថយនិងការលុបបំបាត់ពន្ធគយលើទំនិញដែលមានដើមកំណើត ត្រូវយកមកជំនួសអត្រាពន្ធគយដែលបានកំណត់ក្នុងតារាងកម្មវិធីសម្រាប់ទំនិញទាំងនោះ ហើយត្រូវចូលជាធរមានបន្ទាប់ពីទទួលបានការអនុម័តដោយភាគីនីមួយៗ អនុលោមតាមនីតិវិធីច្បាប់ជាធរមានរបស់ភាគីនីមួយៗ។

៣. ក្នុងពេលណាមួយដែលភាគីមួយអាចពន្លឿនការកាត់បន្ថយនិងលុបបំបាត់ពន្ធគយជាឯកតោភាគី លើទំនិញដែលមានដើមកំណើតនៃភាគីមួយទៀត ដូចដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធ ១ (តារាងសន្យាពន្ធគយ) ភាគីនោះត្រូវផ្តល់ព័ត៌មានដល់ភាគីមួយទៀតឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន មុនអត្រាពន្ធគយថ្មីនេះចូលជាធរមាន។

## មាត្រា ២.៦ ការដាក់កម្រិតលើបរិមាណនិងវិធានការមិនមែនពន្ធគយ

១. លើកលែងតែមានចែងផ្សេងក្នុងកិច្ចព្រមព្រៀងនេះ គ្មានភាគីណាមួយត្រូវអនុម័ត ឬរក្សា ការហាមឃាត់ ឬការដាក់កម្រិត ឬវិធានការដែលមានឥទ្ធិពលសមមូល រួមទាំងការដាក់កម្រិតបរិមាណលើការនាំចូល

ទំនិញដែលមានដើមកំណើតក្នុងដែនដីនៃភាគីមួយទៀត ឬលើការនាំចេញ ឬលក់សម្រាប់ការនាំចេញទំនិញទៅកាន់ដែនដីនៃភាគីមួយទៀត លើកលែងតែសិទ្ធិនិងកាតព្វកិច្ចនៅក្រោមអង្គការ WTO។ ក្នុងន័យនេះ មាត្រា XI នៃ GATT 1994 ត្រូវបញ្ចូលជាផ្នែកនៃកិច្ចព្រមព្រៀងនេះ *និងត្រូវយកមកអនុវត្តតាមទាំងស្រុង*។

២. ភាគីមួយមិនត្រូវអនុម័តឬរក្សាវិធានការមិនមែនពន្ធគយ លើការនាំចូលទំនិញនៃភាគីមួយទៀត ឬលើការនាំចេញទំនិញទៅកាន់ដែនដីនៃភាគីមួយទៀត លើកលែងតែសិទ្ធិ និងកាតព្វកិច្ចក្រោមអង្គការ WTO ឬក្រោមកិច្ចព្រមព្រៀងនេះ។

៣. ភាគីនីមួយៗត្រូវធានានូវតម្លាភាពនៃវិធានការមិនមែនពន្ធគយដែលបានអនុញ្ញាតក្នុងកថាខណ្ឌ ២ និងត្រូវធានាថាវិធានការទាំងនោះមិនបានរៀបចំឡើង អនុម័ត ឬអនុវត្តក្នុងគោលបំណងឬមានឥទ្ធិពលបង្កើតជាឧបសគ្គមិនចាំបាច់ដែលរារាំងដល់ការធ្វើពាណិជ្ជកម្មរវាងភាគីទាំងពីរ។

## មាត្រា ២.៧ នីតិវិធីផ្តល់អាជ្ញាប័ណ្ណនាំចូល

ភាគីនីមួយៗត្រូវធានាថា នីតិវិធីផ្តល់អាជ្ញាប័ណ្ណនាំចូលទំនិញដែលមានដើមកំណើតក្នុងភាគីមួយទៀតត្រូវអនុវត្តតាមកិច្ចព្រមព្រៀង WTO និងត្រូវអនុលោមតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីនីតិវិធីផ្តល់អាជ្ញាប័ណ្ណនាំចូល។

## មាត្រា ២.៨ វិធានការការពារជាសកល

ភាគីនីមួយៗរក្សាសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនក្រោមមាត្រា XIX នៃ GATT 1994 និងកិច្ចព្រមព្រៀងស្តីពីការការពារ។

## មាត្រា ២.៩ កម្រៃនិងទម្រង់បែបបទរដ្ឋបាល

១. យោងតាមមាត្រា VIII.1 នៃ GATT 1994 និងកំណត់សម្គាល់បកស្រាយ ភាគីនីមួយៗត្រូវធានាថា កម្រៃនិងបន្ទុកផ្សេងៗគ្រប់ប្រភេទ (ក្រៅពីពន្ធគយ បន្ទុកផ្សេងដែលសមមូលនឹងពន្ធក្នុងស្រុក ឬបន្ទុកក្នុងស្រុកផ្សេងទៀត ត្រូវបានអនុវត្តស្របតាមមាត្រា III.2 នៃ GATT 1994 និងពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ និងពន្ធប៉ះប៉ូវ) ដែលដាក់បន្ទុកលើ ឬពាក់ព័ន្ធនឹងការនាំចូលឬការនាំចេញ ត្រូវបានកំណត់ត្រឹមចំនួនប្រហាក់ប្រហែលទៅនឹងថ្លៃសេវាដែលបានប្រើ និងមិនត្រូវធ្វើឡើងក្នុងន័យការពារទំនិញក្នុងស្រុកដោយប្រយោលឬការយកពន្ធលើការនាំចូលឬនាំចេញសម្រាប់គោលបំណងសារពើពន្ធឡើយ។

២. បញ្ជីកម្រៃ និងថ្លៃសេវាបច្ចុប្បន្នដែលបានដាក់បន្ទុកលើការនាំចូលនិងនាំចេញរបស់ភាគីនីមួយៗ ត្រូវផ្សព្វផ្សាយក្នុងអ៊ីនធើណែត ឬតាមបណ្តាញទូរគមនាគមន៍តាមប្រព័ន្ធកុំព្យូទ័រ។

## មាត្រា ២.១០ ការជំរុញពាណិជ្ជកម្ម

១. ភាគីទាំងពីរត្រូវបង្កើនកិច្ចសហប្រតិបត្តិការ សំដៅជំរុញពាណិជ្ជកម្មទ្វេភាគីដោយពិចារណាលើសារៈសំខាន់នៃការធានាដល់ការផ្គត់ផ្គង់ប្រកបដោយសុវត្ថិភាពនិងអាចជឿទុកចិត្តបាន ការពង្រីកផលប្រយោជន៍រួម និងការកាត់បន្ថយគម្លាតអភិវឌ្ឍន៍ ដើម្បីជួយកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច ក្នុងដែនដីរបស់ភាគីទាំងពីរ។

២. ដើម្បីបន្តជំរុញពាណិជ្ជកម្មទ្វេភាគី ភាគីទាំងពីរត្រូវផ្តល់បរិយាកាសគោលនយោបាយល្អ និងបង្កើតឱ្យមានកិច្ចរៀបចំមួយ ដើម្បីពង្រីកកាលានុវត្តភាពពាណិជ្ជកម្មនៃការបើកទីផ្សារសម្រាប់ផលិតផលក្រោមបញ្ជីកាត់បន្ថយពន្ធគយភាគខ្លះ (Partial Reduction Category) និងបញ្ជីលើកលែង (Exclusion Category) នៃភាគីនីមួយៗ។ ភាគីទាំងពីរត្រូវលើកទឹកចិត្តឧស្សាហកម្មនិងធុរកិច្ច ឱ្យចូលរួមប្រាស្រ័យទាក់ទងគ្នានិងសហប្រតិបត្តិការលើពាណិជ្ជកម្មទំនិញ។

## មាត្រា ២.១១ ការលើកលែង

ចំពោះការលើកលែងទូទៅ និងការលើកលែងដោយមូលហេតុសន្តិសុខ មាត្រា XX និង XXI នៃ GATT 1994 ត្រូវយកមកអនុវត្តនិងដាក់បញ្ចូលនិងក្លាយជាផ្នែកនៃកិច្ចព្រមព្រៀងនេះ *ហើយត្រូវយកមកអនុវត្តតាមទាំងស្រុង*។

## មាត្រា ២.១២ មន្ត្រីទំនាក់ទំនង

ភាគីនីមួយៗត្រូវចាត់តាំងមន្ត្រីទំនាក់ទំនងមួយឬច្រើនរូប ដើម្បីសម្របសម្រួលការប្រាស្រ័យទាក់ទងរវាងភាគីទាំងពីរលើបញ្ហានានាក្នុងជំពូកនេះ និងត្រូវផ្តល់ព័ត៌មានលម្អិតរបស់មន្ត្រីទំនាក់ទំនងនោះ ទៅភាគីមួយទៀត។ ភាគីទាំងពីរត្រូវជូនដំណឹងភ្លាមៗ រាល់ការផ្លាស់ប្តូរព័ត៌មានលម្អិតរបស់មន្ត្រីទំនាក់ទំនងនេះ។

# ជំពូក ៣ វិធានដើមកំណើត
## ផ្នែក ក

### មាត្រា ៣.១ និយមន័យ

សម្រាប់គោលបំណងនៃឧបសម្ព័ន្ធនេះ៖

(ក) **វារីវប្បកម្ម** មានន័យថា ការធ្វើកសិកម្មនៃសរីរាង្គរស់នៅក្នុងទឹក រួមមានត្រី សិប្បីសត្វ សត្វមានសម្បក និងនិប្បិជ្បាផ្សិកសត្វដែលឥតឆ្អឹងខ្នង និងរុក្ខជាតិជុះក្នុងទឹកផ្សេងទៀត ចេញពីការចម្រាញ់ពូជ ដូចជាស៊ុត កូនត្រីទើបញាស់ កូនត្រី និងកូនញាស់ ដែលចូលរួមក្នុងដំណើរការចិញ្ចឹម ឬលូតលាស់ ដើម្បីបង្កើនផលិតកម្ម ដូចជាការស្តុកទុកជាប្រចាំ ការចិញ្ចឹម ការឱ្យចំណី ឬការការពារពីសត្វដែលស៊ីសាច់សត្វដទៃ។ល។

(ខ) **ថ្លៃទំនិញ រួមនឹងថ្លៃធានារ៉ាប់រង និងថ្លៃដឹកជញ្ជូន** (CIF) មានន័យថា ថ្លៃនៃទំនិញនាំចូល និងរួមទាំងថ្លៃដឹកជញ្ជូននិងការធានារ៉ាប់រងដល់កំពង់ផែ ឬមាត់ច្រកចូលទៅកាន់ប្រទេសដែលជាភាគីនាំចូល។ តម្លៃនេះត្រូវបានកំណត់ដោយអនុលោមតាមកិច្ចព្រមព្រៀងស្តីពីការកំណត់តម្លៃគិតពន្ធគយ

(គ) **ថ្លៃទំនិញដឹកជញ្ជូនដល់លើនាវា** (FOB) មានន័យថា តម្លៃនៃទំនិញដែលដឹកជញ្ជូនមកដល់លើនាវា រួមបញ្ចូលទាំងចំណាយនៃការដឹកជញ្ជូនទំនិញទៅកាន់កំពង់ផែ ឬទីកន្លែងដឹកជញ្ជូនចុងក្រោយបំផុតទៅក្រៅប្រទេស។ តម្លៃនេះត្រូវកំណត់ដោយអនុលោមតាមកិច្ចព្រមព្រៀង ស្តីពីការកំណត់តម្លៃគិតពន្ធគយ

(ឃ) **គោលការណ៍គណនេយ្យទទួលស្គាល់ទូទៅ** (GAAP) មានន័យថា ស្តង់ដារគណនេយ្យដែលមានការទទួលស្គាល់ជាទូទៅ ឬទទួលស្គាល់ភាគច្រើនដោយភាគីណាមួយ ពាក់ព័ន្ធនឹងការកត់ត្រាចំណូល ចំណាយ ថ្លៃដើម ទ្រព្យសកម្ម និងបំណុល ការលាតត្រដាងព័ត៌មាន និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ ស្តង់ដារទាំងនេះអាចរាប់បញ្ចូលទាំងគោលការណ៍ណែនាំទូលំទូលាយនៃការអនុវត្តទូទៅ រួមទាំង ស្តង់ដារ ការអនុវត្ត និងនីតិវិធីលម្អិតផ្សេងៗ

(ង) **ទំនិញ** មានន័យថា ទំនិញ ផលិតផល របស់របរ ឬវត្ថុធាតុនានា

(ច) **វត្ថុធាតុដូចគ្នា ឬវត្ថុធាតុអាចផ្លាស់ប្តូរគ្នាបាន** មានន័យថា វត្ថុធាតុក្នុងប្រភេទដូចគ្នានេះ អាចជំនួសគ្នាបានសម្រាប់គោលបំណងពាណិជ្ជកម្ម ហើយមានលក្ខណៈសំខាន់ប្រហាក់ប្រហែលគ្នា និងដែលពិបាកក្នុងការញែកលក្ខណៈខុសប្លែកគ្នា តាមរយៈការពិនិត្យដោយភ្នែក

(ឆ) **វត្ថុធាតុ** មានន័យថា រូបធាតុ ឬសារធាតុទាំងឡាយណាដែល ត្រូវបានប្រើប្រាស់ក្នុងផលិតកម្មនៃទំនិញ ត្រូវបានផ្សំបញ្ចូលជាទំនិញមួយ ឬត្រូវបានប្រើសម្រាប់ដំណើរការផលិតកម្មនៃទំនិញមួយផ្សេងទៀត

(ជ) **វត្ថុធាតុមានដើមកំណើត ឬទំនិញមានដើមកំណើត** មានន័យថា វត្ថុធាតុ ឬទំនិញដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមលក្ខខណ្ឌដើមកំណើត ដោយអនុលោមតាមបទប្បញ្ញត្តិនៃជំពូកនេះ

(ឈ) **វត្ថុធាតុវេចខ្ចប់ និងកុងតឺន័រសម្រាប់ការដឹកជញ្ជូន** មានន័យថា វត្ថុធាតុ និងកុងតឺន័រដែលត្រូវបានប្រើប្រាស់សម្រាប់ការពារទំនិញក្នុងអំឡុងពេលដឹកជញ្ជូន ដែលមានលក្ខណៈខុសពីប្រអប់ ឬកេស ឬសម្ភារៈដែលប្រើប្រាស់សម្រាប់ការលក់រាយ

(ញ) **ផលិតកម្ម** មានន័យថា វិធីក្នុងការទទួលបានទំនិញ រាប់បញ្ចូលទាំងការដាំដុះ ការចិញ្ចឹម ការជីករ៉ែ ការប្រមូលផល ការនេសាទ វារីវប្បកម្ម កសិកម្ម ការដាក់អន្ទាក់ ការប្រមាញ់ ការប្រមូលយកការប្រមូលផ្តុំ ការចាប់យក ការបង្កាត់ពូជ ការចម្រាញ់ចេញ កម្មន្តសាល ការផលិត ការកែច្នៃ ការតម្លើង/ផ្គុំទំនិញ។ល។

(ដ) **វិធានផលិតផលជាក់លាក់** មានន័យថា វិធានដែលបញ្ជាក់ថាវត្ថុធាតុទាំងនោះ បានឆ្លងកាត់ការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធ ឬការផលិតជាក់លាក់ ឬប្រតិបត្តិការកែច្នៃណាមួយ ឬឆ្លើយតបតាមលក្ខណៈវិនិច្ឆ័យសមាសធាតុតម្លៃតំបន់ ឬការរួមបញ្ចូលគ្នានៃលក្ខណៈវិនិច្ឆ័យទាំងនេះ

(ឋ) **ប្រព័ន្ធសុខដុមនីយកម្ម** មានន័យថា ប្រព័ន្ធលេខកូដ និងប្រព័ន្ធបរិយាយចំណាត់ថ្នាក់ទំនិញ នៃអង្គការគយពិភពលោក

(ឌ) **ជាតុអព្យាក្រឹត** មានន័យថា ទំនិញដែលត្រូវបានប្រើប្រាស់ក្នុងផលិតកម្ម ការធ្វើតេស្ត ឬការត្រួតពិនិត្យនៃទំនិញមួយទៀត ប៉ុន្តែមិនត្រូវបានផ្សំបញ្ចូលគ្នាជាមួយនឹងទំនិញមួយទៀតនោះឡើយ

(ឍ) **កិច្ចព្រមព្រៀងស្តីពីការកំណត់តម្លៃគិតពន្ធគយ** មានន័យថា កិច្ចព្រមព្រៀងស្តីពីការអនុវត្តមាត្រា VII នៃកិច្ចព្រមព្រៀងទូទៅស្តីពីអត្រាពន្ធគយ និងពាណិជ្ជកម្មឆ្នាំ ១៩៩៤ (GATT) ដែលជាផ្នែកមួយនៃកិច្ចព្រមព្រៀងម៉ារ៉ាកេស (Marrakesh) ស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក។

(ណ) **ទំនិញមិនមានដើមកំណើត ឬវត្ថុធាតុមិនមានដើមកំណើត** មានន័យថា ទំនិញ ឬវត្ថុធាតុដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមលក្ខខណ្ឌដើមកំណើត ដោយអនុលោមតាមបទប្បញ្ញត្តិនៃជំពូកនេះ ឬជាទំនិញ ឬវត្ថុធាតុដែលមិនអាចកំណត់ដើមកំណើតបាន។

## មាត្រា ៣.២ ទំនិញមានដើមកំណើត

សម្រាប់គោលបំណងនៃជំពូកនេះ ទំនិញដែលត្រូវបានចាត់ទុកថាមានដើមកំណើត និងអាចទទួលបាននូវប្រព្រឹត្តកម្មអនុគ្រោះពន្ធគយ គឺជាទំនិញដែល៖

(ក) ត្រូវបានផលិតទាំងស្រុង ឬទទួលបានទាំងស្រុងពីភាគីមួយ ដូចមានចែងក្នុងមាត្រា ៣.៣ (ទំនិញដែលផលិតទាំងស្រុង ឬទទួលបានទាំងស្រុង) នៃជំពូកនេះ

(ខ) ត្រូវបានផលិតនៅក្នុងភាគីមួយទាំងស្រុងចេញពីវត្ថុធាតុមានដើមកំណើត

(គ) ត្រូវបានផលិតចេញពីវត្ថុធាតុមិនមានដើមកំណើតនៅក្នុងភាគីមួយ លុះត្រាតែទំនិញនោះបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់តាមមាត្រា ៣.៤ (មាត្រា ៣.៤ ទំនិញដែលមិនផលិតទាំងស្រុង ឬមិនទទួលបានទាំងស្រុង) នៃជំពូកនេះ និងបំពេញតាមលក្ខខណ្ឌតម្រូវផ្សេងៗទៀតទាំងអស់នៃជំពូកនេះ។

## មាត្រា ៣.៣ ទំនិញដែលផលិតទាំងស្រុង ឬទទួលបានទាំងស្រុង

សម្រាប់គោលបំណងនៃមាត្រា៣.២ (ក) នៃជំពូកនេះ ទំនិញដែលត្រូវបានចាត់ទុកថា ជាទំនិញដែលផលិតទាំងស្រុង ឬទទួលបានទាំងស្រុង មានដូចខាងក្រោម៖

(ក) រុក្ខជាតិ និងផលិតផលពីរុក្ខជាតិ (រួមមាន ផ្លែឈើ ផ្កា បន្លែ ដើមឈើ សារាយសមុទ្រ ផ្សិត និងរុក្ខជាតិរស់) ដាំដុះ ប្រមូលផល បេះ ឬប្រមូលយក នៅក្នុងភាគីមួយ

(ខ) សត្វរស់ ដែលបានកើត និងចិញ្ចឹមនៅក្នុងភាគីមួយ

(គ) ទំនិញដែលទទួលបានពីសត្វរស់នៅក្នុងភាគីមួយ ដោយគ្មានការកែច្នៃបន្ថែមទៀត រួមទាំង ទឹកដោះសត្វ ស៊ុត ទឹកឃ្មុំធម្មជាតិ សក់ រោម ទឹកអសុចិសត្វនិងលាមកសត្វ

(ឃ) ទំនិញដែលទទួលបានមកពី ការប្រមាញ់ ការដាក់អន្ទាក់ ការនេសាទ វារីវប្បកម្ម ការប្រមូលយក និងការចាប់ នៅក្នុងភាគីមួយ

(ង) រ៉ែ និងសារធាតុកើតឡើងដោយធម្មជាតិដទៃទៀត ដែលបានមកពីការទាញ ឬយកចេញពីដី ទឹក បាតសមុទ្រ ឬនៅក្រោមបាតសមុទ្រនៅក្នុងភាគីមួយ

(ច) ទំនិញដែលបានពីទឹក បាតសមុទ្រ ឬនៅក្រោមបាតសមុទ្រ នៅក្រៅដែនទឹកនៃភាគីនោះ លុះត្រាតែភាគីនោះមានសិទ្ធិទាញយកផលប្រយោជន៍ពីទឹក បាតសមុទ្រ និងក្រោមបាតសមុទ្រ ដោយអនុលោមតាមច្បាប់អន្តរជាតិ

(ឆ) ទំនិញបានមកពីការនេសាទសមុទ្រ និងផលិតផលសមុទ្រដទៃទៀត ដែលត្រូវបានយកពីដែនសមុទ្រអន្តរជាតិដោយនាវាដែលបានចុះបញ្ជីជាមួយភាគីមួយ ឬមានសិទ្ធិដាក់ទង់ជាតិរបស់ភាគីនោះ

(ជ) ទំនិញដែលឆ្លងកាត់ការកែច្នៃ និង/ឬ បានមកពីការផលិតទាំងស្រុងចេញពីផលិតផលទាំងអស់ដូចមានចែងក្នុងកថាខណ្ឌ (ឆ) នៅលើបណ្តានាវារោងចក្រដែលបានចុះបញ្ជីជាមួយភាគីមួយ ឬមានសិទ្ធិដាក់ទង់ជាតិរបស់ភាគីនោះ

(ឈ) កាកសំណល់ និងកម្ទេចកម្ទីដែលបានមកពី ដំណើរការផលិតកម្ម ឬការប្រើប្រាស់ក្នុងភាគីមួយ ប្រសិនបើទំនិញនោះ សមស្របសម្រាប់តែចម្រាញ់យកមកវិញនៃវត្ថុធាតុដើមតែប៉ុណ្ណោះ ឬ

(ញ) ទំនិញប្រើប្រាស់រួចដែលបានប្រើ និងបានប្រមូលនៅក្នុងភាគីមួយ ប្រសិនបើទំនិញនោះ សមស្របសម្រាប់តែចម្រាញ់យកមកវិញនៃវត្ថុធាតុដើមតែប៉ុណ្ណោះ និង

(ដ) ទំនិញដែលផលិត ឬទទួលបានទាំងស្រុងក្នុងភាគីមួយ ចេញពីទំនិញដែលមានចែងក្នុងវាក្យខណ្ឌ (ក) ដល់ (ញ) តែប៉ុណ្ណោះ ឬបានមកពីការកែច្នៃចេញពីទំនិញដែលផលិត ឬទទួលបានទាំងស្រុង ក្នុងភាគីមួយ ចេញពីផលិតផលដែលមានចែងក្នុងវាក្យខណ្ឌ (ក) ដល់ (ញ) តែប៉ុណ្ណោះ។

## មាត្រា ៣.៤ ទំនិញដែលមិនផលិតទាំងស្រុង ឬមិនទទួលបានទាំងស្រុង

១. សម្រាប់គោលបំណងនៃមាត្រា ៣.២ (គ) នៃជំពូកនេះ ទំនិញក្រៅពីទំនិញទាំងឡាយណាដែលមានចែងក្នុងកថាខណ្ឌ ២ ត្រូវបានចាត់ទុកថាជាទំនិញមានដើមកំណើតៈ

(ក) ប្រសិនបើទំនិញនោះមានសមាសធាតុតម្លៃតំបន់ (RVC) មិនតិចជាង ៤០ ភាគរយ នៃតម្លៃ FOB ដោយគណនាតាមរូបមន្តដូចមានចែងក្នុងមាត្រា ៣.៥ នៃជំពូកនេះ ហើយដំណើរការផលិតកម្មចុងក្រោយត្រូវបានប្រព្រឹត្តទៅនៅក្នុងភាគីមួយ ឬ

(ខ) សម្រាប់គោលបំណងនៃទំនិញដែលមានចំណាត់ថ្នាក់ក្នុងជំពូក ២៥, ២៦, ២៨, ២៩[១], ៣១[២], ៣៩[៣], ៤២-៤៩, ៥៧-៥៩, ៦១, ៦២, ៦៤, ៦៦-៧១, ៧៣-៨៣, ៨៦, ៨៨, ៩១-៩៧ នៃប្រព័ន្ធសុខដុមនីយកម្ម ប្រសិនបើរាល់វត្ថុធាតុមិនមានដើមកំណើតដែលបានប្រើប្រាស់ក្នុងផលិតកម្មនៃទំនិញនោះត្រូវបានផ្លាស់ប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធគយ (តទៅនេះហៅថា "CTC") ក្នុងកម្រិត ៤ខ្ទង់ ដែលជាការផ្លាស់ប្តូរទីតាំង ក្នុងប្រព័ន្ធសុខដុមនីយកម្ម។

---

[១]សម្រាប់ទីតាំង ២៩.០១ និង ២៩.០២, លក្ខណៈវិនិច្ឆ័យត្រូវបំពេញគឺ RVC 40% លើកលែងតែមានការព្រមព្រៀងរួមគ្នារវាងភាគី។

[២]សម្រាប់ទីតាំង ៣១.០៥, លក្ខណៈវិនិច្ឆ័យត្រូវបំពេញគឺ RVC 40% លើកលែងតែមានការព្រមព្រៀងរួមគ្នារវាងភាគី។

[៣]សម្រាប់ទីតាំង ៣៩.០១, ៣៩.០២, ៣៩.០៣, ៣៩.០៧ និង ៣៩.០៨, លក្ខណៈវិនិច្ឆ័យត្រូវបំពេញគឺ RVC 40% លើកលែងតែមានការព្រមព្រៀងរួមគ្នារវាងភាគី

២. ដោយអនុលោមតាមកថាខណ្ឌ ១ ហើយលុះត្រាតែមានចែងផ្សេងក្នុងវិធានផលិតផលជាក់លាក់ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធ២ ទំនិញមួយត្រូវចាត់ទុកថាជាទំនិញមានដើមកំណើត ប្រសិនបើទំនិញនោះស្របតាមលក្ខណៈវិនិច្ឆ័យសមាសធាតុតម្លៃតំបន់មិនតិចជាង ៤០ភាគរយ ឬលក្ខណៈវិនិច្ឆ័យផ្សេងទៀតដែលចែងក្នុងវិធានផលិតផលជាក់លាក់។

## មាត្រា ៣.៥ ការគណនាសមាសធាតុតម្លៃតំបន់

១. សមាសធាតុតម្លៃតំបន់ (RVC) ត្រូវគណនាដោយប្រើរូបមន្តដូចខាងក្រោម៖

$$\text{RVC} = \frac{FOB - VNM}{FOB} \times ១០០\%$$

ដែល៖

RVC គឺជាសមាសធាតុតម្លៃតំបន់ដែលគិតជាភាគរយ

VNM គឺជាតម្លៃនៃវត្ថុធាតុមិនមានដើមកំណើត

២. VNM ត្រូវកំណត់ក្នុងកាលៈទេសៈដូចខាងក្រោម៖

(ក) ក្នុងករណីវត្ថុធាតុមិនមានដើមកំណើតដែលបាននាំចូល VNM ត្រូវតែជាតម្លៃ CIF នៃវត្ថុធាតុនោះនាពេលនាំចូល

(ខ) ក្នុងករណីវត្ថុធាតុមិនមានដើមកំណើតសម្រេចបានក្នុងភាគីមួយ VNM ត្រូវតែជាតម្លៃដែលបានទូទាត់ឬត្រូវទូទាត់ដំបូងបំផុត លើវត្ថុធាតុដើមមិនមានដើមកំណើតក្នុងភាគីនោះ។ តម្លៃនៃវត្ថុធាតុមិនមានដើមកំណើតនេះមិនត្រូវរាប់បញ្ចូលថ្លៃដឹកជញ្ជូន ថ្លៃធានារ៉ាប់រង ថ្លៃវេចខ្ចប់ និងថ្លៃដើមផ្សេងទៀតដែលបានចំណាយក្នុងការដឹកជញ្ជូនវត្ថុធាតុពីឃ្លាំងរបស់អ្នកផ្គត់ផ្គង់ទៅកាន់ទីតាំងរបស់អ្នកផលិតឡើយ។

៣. ប្រសិនបើផលិតផលមួយដែលទទួលស្គាល់ថាមានដើមកំណើតក្នុងភាគីមួយ ស្របតាមកថាខណ្ឌ ១ ត្រូវបានកែច្នៃបន្តក្នុងភាគីនោះ ហើយត្រូវបានប្រើប្រាស់ជាវត្ថុធាតុក្នុងការផលិតផលិតផលផ្សេងមួយទៀត ដូច្នេះសមាសភាគដែលមិនមានដើមកំណើតរបស់វត្ថុធាតុនោះមិនត្រូវរាប់បញ្ចូលក្នុងការកំណត់ស្ថានភាពដើមកំណើតរបស់ផលិតផលនោះទេ។

៤. ការកំណត់តម្លៃត្រូវធ្វើឡើងដោយអនុលោមតាមកិច្ចព្រមព្រៀងស្តីពីការកំណត់តម្លៃគិតពន្ធគយ។

## មាត្រា ៣.៦ វិធានបូកបន្ថែម (Accumulation)

លើកលែងតែមានចែងផ្សេងនៅក្នុងជំពូកនេះ ទំនិញមានដើមកំណើតក្នុងភាគីមួយដែលត្រូវបានយកទៅប្រើប្រាស់ដោយភាគីមួយទៀតជាវត្ថុធាតុនៃផលិតផលសម្រេច ដែលអាចទទួលបានប្រព្រឹត្តិកម្មអនុគ្រោះ

ពន្ធគយ ត្រូវចាត់ទុកថាមានដើមកំណើតនៅក្នុងភាគីមួយទៀតនោះ ដែលការផលិតឬកែច្នៃផលិតផលសម្រេចនោះ ត្រូវបានធ្វើឡើង។

## មាត្រា ៣.៧ ប្រតិបត្តិការ និងដំណើរការអប្បបរមា

១. ថ្វីបើមានចែងក្នុងបទប្បញ្ញត្តិនៃជំពូកនេះ នៅពេលដែលប្រតិបត្តិការដូចខាងក្រោមប្រព្រឹត្តទៅដោយប្រើវត្ថុធាតុមិនមានដើមកំណើតដើម្បីផលិតទំនិញមួយ ត្រូវចាត់ទុកថាជាប្រតិបត្តិការ ឬការកែច្នៃមិនមានភាពគ្រប់គ្រាន់ក្នុងការផ្តល់ដើមកំណើតដល់ទំនិញនោះឡើយៈ

(ក) ប្រតិបត្តិការរក្សាទុក ដើម្បីធានាថាទំនិញនៅតែមានស្ថានភាពល្អ សម្រាប់គោលបំណងដឹកជញ្ជូន ឬស្តុកទុក

(ខ) ការវេចខ្ចប់ ឬការបង្ហាញទំនិញ សម្រាប់ដឹកជញ្ជូន ឬលក់

(គ) ដំណើរការសាមញ្ញ[៤] ដែលរួមមាន ការរែង ការចម្រាញ់ ការបែងចែងតាមប្រភេទ ការបែងចែងតាមចំណាត់ថ្នាក់ ការសម្រួច ការកាត់ ការវះ ការកិន ការបត់/ពត់ ការមូរចូល ឬការមូរចេញ

(ឃ) ការបិទឬបោះពុម្ពម៉ាក ស្លាកសញ្ញា រូបសញ្ញា ឬសញ្ញាសម្គាល់ផ្សេងទៀតលើទំនិញ ឬកញ្ចប់ទំនិញនោះ

(ង) ការលាយជាមួយទឹក ឬសារធាតុផ្សេងទៀតដែលមិនផ្លាស់ប្តូរជំដុំដល់លក្ខណៈរបស់ទំនិញ

(ច) ការដោះបំបែកទំនិញទៅជាបំណែក

(ឆ) ការសម្លាប់សត្វ[៥]

(ជ) ប្រតិបត្តិការសាមញ្ញ លើការដាក់ពណ៌ និងខាត់ឱ្យរលោង

(ឈ) ការចិតសំបក ការដំ ឬការបកសំបក ដែលសាមញ្ញ

(ញ) ការលាយផលិតផលបញ្ចូលគ្នាបែបសាមញ្ញ ទោះបីជាប្រភេទដូច ឬផ្សេងគ្នាក៏ដោយ ឬ

(ដ) ការរួមបញ្ចូលគ្នានៃប្រតិបត្តិការពីរ ឬច្រើនដែលមានចែងក្នុងវាក្យខណ្ឌ (ក) រហូតដល់ (ញ)។

## មាត្រា ៣.៨ ការបញ្ជូនទំនិញដោយផ្ទាល់

១. ប្រព្រឹត្តិកម្មអនុគ្រោះពន្ធគយ ត្រូវអនុវត្តចំពោះទំនិញដែលបំពេញបានតាមលក្ខខណ្ឌតម្រូវនៃជំពូកនេះ ហើយដែលត្រូវបានបញ្ជូនទៅដោយផ្ទាល់រវាងភាគីនាំចេញ និងភាគីនាំចូល។

---

[៤] សម្រាប់គោលបំណងនៃមាត្រានេះ "សាមញ្ញ" មានន័យថា សកម្មភាពដែលមិនត្រូវការជំនាញពិសេស គ្រឿងម៉ាស៊ីន គ្រឿងបរិក្ខារ ឬឧបករណ៍ដែលជាពិសេសត្រូវបានផលិត ឬដំឡើងសម្រាប់ធ្វើសកម្មភាព។

[៥] សម្រាប់គោលបំណងនៃមាត្រានេះ "ការសម្លាប់សត្វ" មានន័យថា ការសម្លាប់សត្វតែប៉ុណ្ណោះ។

២. សកម្មភាពខាងក្រោមនេះ ត្រូវចាត់ទុកថាជាការបញ្ជូនទៅដោយផ្ទាល់ពីភាគីនាំចេញទៅកាន់ភាគីនាំចូលៈ

(ក) ទំនិញដែលត្រូវបានដឹកជញ្ជូនដោយផ្ទាល់ពីភាគីនាំចេញ ទៅភាគីនាំចូល ឬ

(ខ) ទំនិញដែលត្រូវបានដឹកជញ្ជូនឆ្លងកាត់ប្រទេសមិនមែនជាភាគីមួយ ឬច្រើន ក្នុងលក្ខខណ្ឌដែលៈ

(i) ប្រកឆ្លងកាត់នោះផ្អែកលើហេតុផលភូមិសាស្ត្រឬលើការពិចារណាដែលទាក់ទងនឹងលក្ខខណ្ឌតម្រូវផ្នែកដឹកជញ្ជូនតែប៉ុណ្ណោះ

(ii) ទំនិញមិនសម្រាប់ជួញដូរ ឬប្រើប្រាស់នៅទីនោះ និង

(iii) ទំនិញមិនបានឆ្លងកាត់ប្រតិបត្តិការណាមួយនៅទីនោះ ក្រៅពីការលើកដាក់ឡើងចុះ ឬប្រតិបត្តិការផ្សេងទៀត ដើម្បីរក្សាទំនិញនោះឱ្យស្ថិតក្នុងស្ថានភាពល្អ។

## មាត្រា ៣.៩ វិធានអប្បបរមា ( *De Minimis* )

ទំនិញដែលមិនបំពេញតាមលក្ខខណ្ឌតម្រូវនៃការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធគយ ដូចមានចែងក្នុងមាត្រា៣.៤ ( ទំនិញដែលមិនផលិតទាំងស្រុង ឬមិនទទួលបានទាំងស្រុង ) នៃជំពូកនេះ នឹងនៅតែជាទំនិញមានដើមកំណើត ប្រសិនបើៈ

(ក) សម្រាប់ទំនិញណាមួយក្រៅពីទំនិញក្នុងជំពូក ៥០ ដល់ ៦៣ នៃប្រព័ន្ធសុខដុមនីយកម្ម តម្លៃវត្ថុធាតុមិនមានដើមកំណើតទាំងអស់ប្រើក្នុងផលិតកម្មទំនិញដែលមិនឆ្លងកាត់លក្ខខណ្ឌតម្រូវនៃការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធគយ មានតម្លៃមិនលើសពី១០ភាគរយ នៃតម្លៃ FOB របស់ទំនិញនោះ

(ខ) សម្រាប់ទំនិញក្នុងជំពូក ៥០ ដល់ ៦៣ នៃប្រព័ន្ធសុខដុមនីយកម្ម ទម្ងន់វត្ថុធាតុមិនមានដើមកំណើតទាំងអស់ប្រើក្នុងផលិតកម្មទំនិញដែលមិនឆ្លងកាត់លក្ខខណ្ឌតម្រូវនៃការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធគយ មានទម្ងន់មិនលើសពី១០ភាគរយ នៃទម្ងន់សរុបរបស់ទំនិញនោះ ឬតម្លៃវត្ថុធាតុមិនមានដើមកំណើតទាំងអស់ប្រើក្នុងផលិតកម្មទំនិញ ដែលមិនឆ្លងកាត់លក្ខខណ្ឌតម្រូវនៃការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធគយ មានតម្លៃមិនលើសពី ១០ភាគរយ នៃតម្លៃ FOB របស់ទំនិញនោះ

ហើយទំនិញនោះបំពេញតាមលក្ខណៈវិនិច្ឆ័យទាំងអស់ នៃជំពូកនេះ។

## មាត្រា ៣.១០ ប្រព្រឹត្តិកម្មវត្ថុធាតុវេចខ្ចប់ កញ្ចប់ និងប្រអប់

១. វត្ថុធាតុវេចខ្ចប់ កញ្ចប់ និងប្រអប់ សម្រាប់ការដឹកជញ្ជូន មិនត្រូវរាប់បញ្ចូលក្នុងការកំណត់ដើមកំណើតទំនិញឡើយ។

២. វត្ថុធាតុវេចខ្ចប់ កញ្ចប់ និងប្រអប់ ដែលប្រើប្រាស់សម្រាប់វេចខ្ចប់ដើម្បីលក់រាយៈ

(ក) ចំពោះទំនិញដែលជាកម្មវត្ថុនៃលក្ខណៈវិនិច្ឆ័យសមាសធាតុតម្លៃតំបន់ តម្លៃនៃវត្ថុធាតុវេចខ្ចប់ កញ្ចប់ និងប្រអប់ ដែលប្រើប្រាស់សម្រាប់វេចខ្ចប់ទំនិញសម្រាប់លក់រាយ ត្រូវរាប់បញ្ចូលក្នុងការកំណត់ដើមកំណើតទំនិញ ប្រសិនបើវត្ថុធាតុវេចខ្ចប់ កញ្ចប់ និងប្រអប់នេះ ត្រូវបានចាត់ថ្នាក់ចូលជាមួយទំនិញនោះ។

(ខ) ចំពោះទំនិញដែលជាកម្មវត្ថុនៃលក្ខណៈវិនិច្ឆ័យលើការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធគយ ដើមកំណើតនៃវត្ថុធាតុវេចខ្ចប់ កញ្ចប់ និងប្រអប់ ដែលទំនិញត្រូវបានវេចខ្ចប់សម្រាប់លក់រាយ មិនត្រូវយកមកគិតក្នុងការកំណត់ដើមកំណើតទំនិញទេ ប្រសិនបើវត្ថុធាតុវេចខ្ចប់ កញ្ចប់ និងប្រអប់នេះ ត្រូវបានចាត់ថ្នាក់ចូលជាមួយទំនិញនោះ។

## មាត្រា ៣.១១ គ្រឿងបន្លាប់បន្សំ គ្រឿងបន្លាស់ និងឧបករណ៍

១. គ្រឿងបន្លាប់បន្សំ គ្រឿងបន្លាស់ និងឧបករណ៍ ដែលបានបង្ហាញ និងចាត់ថ្នាក់ជាមួយទំនិញ ត្រូវចាត់ទុកជាផ្នែកនៃទំនិញនោះ ប្រសិនបើ៖

(ក) គ្រឿងបន្លាប់បន្សំ គ្រឿងបន្លាស់ និងឧបករណ៍ បានដាក់បញ្ចូលក្នុងវិក្កយបត្រតែមួយជាមួយទំនិញនោះ និង

(ខ) បរិមាណ និងតម្លៃរបស់គ្រឿងបន្លាប់បន្សំ គ្រឿងបន្លាស់ និងឧបករណ៍ មានភ្ជាប់ជាមួយទំនិញនោះតាមលក្ខណៈពាណិជ្ជកម្មទូទៅ។

២. នៅពេលទំនិញមួយជាកម្មវត្ថុនៃលក្ខណៈវិនិច្ឆ័យលើការប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធគយ ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ២ នោះគ្រឿងបន្លាប់បន្សំ គ្រឿងបន្លាស់ និងឧបករណ៍ ដែលបានពណ៌នានៅក្នុងកថាខណ្ឌ ១ មិនត្រូវរាប់បញ្ចូលនៅពេលកំណត់ប្រភពដើមកំណើតទំនិញឡើយ។

៣. នៅពេលទំនិញមួយជាកម្មវត្ថុនៃលក្ខណៈវិនិច្ឆ័យសមាសធាតុតម្លៃតំបន់ តម្លៃនៃគ្រឿងបន្លាប់បន្សំ គ្រឿងបន្លាស់ និងឧបករណ៍ ដែលបានពណ៌នាក្នុងកថាខណ្ឌ ១ ត្រូវរាប់បញ្ចូលជាវត្ថុធាតុមានដើមកំណើត ឬវត្ថុធាតុមិនមានដើមកំណើត ក្នុងការគណនាសមាសធាតុតម្លៃតំបន់នៃទំនិញនោះ តាមករណីនីមួយៗ។

## មាត្រា ៣.១២ ធាតុអព្យាក្រឹត

ក្នុងការកំណត់ទំនិញមួយជាទំនិញមានដើមកំណើតឬមិនមានដើមកំណើត ដើមកំណើតនៃធាតុអព្យាក្រឹតខាងក្រោម មិនត្រូវរាប់បញ្ចូលក្នុងការកំណត់ឡើយ៖

(ក) ប្រេងឥន្ធនៈ ថាមពល សារធាតុកាតាលីករ និងសារធាតុរំលាយ

(ខ) គ្រឿងបរិក្ខារ ឧបករណ៍ និងសម្ភារៈផ្គត់ផ្គង់ ដែលត្រូវបានប្រើសម្រាប់ការធ្វើតេស្ត ឬការត្រួតពិនិត្យទំនិញ

(គ) ស្រោមដៃ វ៉ែនតា ស្បែកជើង សម្លៀកបំពាក់ ឧបករណ៍និងសម្ភារៈផ្គត់ផ្គង់សុវត្ថិភាព

(ឃ) ឧបករណ៍ ពុម្ព និងឧបករណ៍ចាក់ពុម្ព

(ង) គ្រឿងបន្លាស់ និងវត្ថុធាតុដែលប្រើក្នុងការថែទាំគ្រឿងបរិក្ខារ និងអគារ

(ច) ប្រេងរំអិល ខ្លាញ់គោ វត្ថុធាតុបន្សំ និងវត្ថុធាតុផ្សេងទៀតដែលប្រើក្នុងផលិតកម្ម ឬប្រើដើម្បីធ្វើប្រតិបត្តិការគ្រឿងបរិក្ខារ និងអគារ និង

(ឆ) ទំនិញផ្សេងទៀតដែលមិនត្រូវបានផ្សំបញ្ចូលទៅក្នុងទំនិញនោះ ប៉ុន្តែការប្រើក្នុងផលិតកម្មទំនិញនោះ មានហេតុផលសមរម្យថាជាផ្នែកមួយនៃផលិកម្មនោះ។

## មាត្រា ៣.១៣ វត្ថុធាតុដូចគ្នា និងវត្ថុធាតុអាចផ្លាស់ប្តូរគ្នាបាន

នៅពេលវត្ថុធាតុដូចគ្នា និងវត្ថុធាតុអាចផ្លាស់ប្តូរគ្នាបាន ដែលមានដើមកំណើតនិងមិនមានដើមកំណើត ត្រូវបានប្រើក្នុងផលិតកម្មទំនិញមួយ នោះវិធីខាងក្រោមត្រូវប្រើក្នុងការកំណត់ថាតើវត្ថុធាតុដែលបានប្រើមាន ឬមិនមានដើមកំណើតៈ

(ក) ការបែងចែកដោយរូបវន្តនៃវត្ថុធាតុ ឬ

(ខ) វិធីគ្រប់គ្រងបញ្ជីសារពើភណ្ឌ ដែលត្រូវបានទទួលស្គាល់នៅក្នុងគោលការណ៍គណនេយ្យទទួលស្គាល់ទូទៅនៃភាគីនាំចេញ។ នៅពេលដែលមានការសម្រេចចិត្តលើការជ្រើសយកវិធីគ្រប់គ្រងបញ្ជីសារពើភណ្ឌ វិធីនោះត្រូវយកមកប្រើពេញមួយឆ្នាំសារពើពន្ធ។

## មាត្រា ៣.១៤ វិញ្ញាបនបត្រដើមកំណើត

លើកលែងតែមានចែងផ្សេងពីនេះ ការអះអាងថា ទំនិញមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានប្រព្រឹត្តិកម្មអនុគ្រោះពន្ធគយ ត្រូវបញ្ជាក់ដោយវិញ្ញាបនបត្រដើមកំណើតទំនិញ ដែលចេញដោយអាជ្ញាធរចេញវិញ្ញាបនបត្រដោយជូនដំណឹងទៅភាគីមួយទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធ ៣ នៃជំពូកនេះ។

## មាត្រា ៣.១៥ ការពិគ្រោះយោបល់ ការពិនិត្យឡើងវិញ និងការកែតម្រូវ

១. ភាគីទាំងពីរត្រូវពិគ្រោះយោបល់គ្នាជាប្រចាំដើម្បីធានាបានថាជំពូកនេះត្រូវបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធិភាព មានលក្ខណៈដូចគ្នា និងសង្គតិភាព ដើម្បីសម្រេចឱ្យបាននូវស្មារតី និងគោលបំណងនៃកិច្ចព្រមព្រៀងនេះ។

២. ជំពូកនេះអាចនឹងត្រូវយកមកពិនិត្យឡើងវិញ និងកែតម្រូវនៅពេលចាំបាច់ តាមសំណើរបស់ភាគីណាមួយ និងអាស្រ័យទៅតាមការព្រមព្រៀងរវាងភាគីទាំងពីរ ហើយអាចនឹងបើកឱ្យមានការពិនិត្យឡើងវិញ និងការកែតម្រូវ ដូចបានព្រមព្រៀងដោយគណៈកម្មការរួមពាណិជ្ជកម្មសេរីកម្ពុជា-ចិន។

## មាត្រា ៣.១៦ គណៈកម្មាធិការវិធានដើមកំណើត

១. គណៈកម្មាធិការវិធានដើមកំណើត (ក្នុងមាត្រានេះតទៅហៅថា "គណៈកម្មាធិការ") រួមមានតំណាងនៃភាគីទាំងពីរ ដែលបានបង្កើតឡើងក្រោមគណៈកម្មការរួម។

២. គណៈកម្មាធិការ ត្រូវដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងវិធានដើមកំណើតនៃកិច្ចព្រមព្រៀង CCFTA ដូចខាងក្រោម៖

(ក) តាមដាន និងពិនិត្យឡើងវិញ លើវិធានការដែលបានដាក់ និងការអនុវត្តតាមការសន្យា

(ខ) ផ្លាស់ប្តូរព័ត៌មាន និងពិនិត្យឡើងវិញលើវិឌ្ឍនភាព

(គ) បញ្ហាផ្សេងទៀត ដែលភាគីទាំងពីរអាចនឹងឯកភាព

(ឃ) បញ្ហាផ្សេងទៀត ដែលគណៈកម្មការរួម បានបញ្ជូនមកគណៈកម្មាធិការ

(ង) ផ្តល់អនុសាសន៍នានា និងរាយការណ៍ជូនគណៈកម្មការរួមតាមការចាំបាច់

៣. គណៈកម្មាធិការ ត្រូវដឹកនាំដោយសហប្រធានដែលមានតំណាងអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីទាំងពីរ។ ភាគីដែលជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំ ត្រូវធ្វើជាប្រធានអង្គប្រជុំ។ ប្រធានអង្គប្រជុំ ត្រូវរៀបចំសេចក្តីព្រាងរបៀបវារៈសម្រាប់កិច្ចប្រជុំនីមួយៗនៃគណៈកម្មាធិការ ដោយធ្វើការពិគ្រោះយោបល់ជាមួយភាគីមួយទៀត និងធ្វើជូនទៅភាគីមួយទៀតនូវសេចក្តីព្រាងរបៀបវារៈមុនកិច្ចប្រជុំ។

៤. គណៈកម្មាធិការ ត្រូវធ្វើការជួបប្រជុំឱ្យបានញឹកញាប់តាមការចាំបាច់និងតាមការណែនាំរបស់គណៈកម្មការរួម ឬតាមការព្រមព្រៀងដោយភាគីទាំងពីរ។ កិច្ចប្រជុំនេះ ត្រូវធ្វើឡើងនៅប្រទេសចិន ឬប្រទេសកម្ពុជា តាមការព្រមព្រៀងគ្នារវាងភាគីទាំងពីរ។

៥. គណៈកម្មាធិការ ត្រូវរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីលទ្ធផលនៃកិច្ចប្រជុំនីមួយៗ។

៦. គណៈកម្មាធិការ ត្រូវចាត់តាំងមន្ត្រីទំនាក់ទំនង ដើម្បីធានានូវការអនុវត្តប្រកបដោយប្រសិទ្ធិភាព និងស័ក្តិសិទ្ធភាពនៃជំពូកនេះ។

# ផ្នែក ខ

សម្រាប់គោលបំណងក្នុងការអនុវត្តវិធានដើមកំណើត នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន (CCFTA) នីតិវិធីប្រតិបត្តិស្តីពីការចេញ និងការផ្ទៀងផ្ទាត់វិញ្ញាបនបត្រដើមកំណើត និងកិច្ចការរដ្ឋបាលពាក់ព័ន្ធផ្សេងទៀតត្រូវអនុវត្តដូចខាងក្រោម៖

## និយមន័យ

## វិធាន ១

សម្រាប់គោលបំណងនៃផ្នែកនេះ៖

**អាជ្ញាធរគយ** មានន័យថា អាជ្ញាធរមានសមត្ថកិច្ចដែលទទួលខុសត្រូវក្រោមច្បាប់របស់ភាគីមួយ លើសមត្ថកិច្ចអនុវត្តច្បាប់ និងបទប្បញ្ញត្តិគយ [៦]

**អ្នកនាំចេញ** មានន័យថា រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមាននិវេសនដ្ឋានក្នុងដែនដីនៃភាគីដែលទំនិញត្រូវបាននាំចេញដោយបុគ្គលនោះ

**អ្នកនាំចូល** មានន័យថា រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមាននិវេសនដ្ឋានក្នុងដែនដីនៃភាគីដែលទំនិញត្រូវបាននាំចូលដោយបុគ្គលនោះ

**អាជ្ញាធរចេញវិញ្ញាបនបត្រ** មានន័យថា អាជ្ញាធររដ្ឋាភិបាល ឬអង្គភាពផ្សេងទៀតដែលត្រូវបានផ្តល់សិទ្ធិដោយច្បាប់ បទប្បញ្ញត្តិ និងវិធានរដ្ឋបាលក្នុងស្រុកនៃភាគីមួយ ដើម្បីចេញវិញ្ញាបនបត្រដើមកំណើត។

## អាជ្ញាធរចេញវិញ្ញាបនបត្រ

## វិធាន ២

វិញ្ញាបនបត្រដើមកំណើតត្រូវចេញដោយអាជ្ញាធរចេញវិញ្ញាបនបត្ររបស់ភាគីនាំចេញ។

## វិធាន ៣

(ក) ភាគីនីមួយៗត្រូវជូនដំណឹងដល់ភាគីមួយទៀតនូវឈ្មោះ និងអាសយដ្ឋានអាជ្ញាធរចេញវិញ្ញាបនបត្ររបស់ខ្លួន ហើយត្រូវផ្តល់គំរូហត្ថលេខា[៧] គំរូត្រាផ្លូវការ និងគំរូត្រាកែតម្រូវដែលប្រើដោយអាជ្ញាធរចេញវិញ្ញាបនបត្ររបស់ខ្លួន ប្រសិនបើមាន។

---

[៦] ច្បាប់និងបទប្បញ្ញត្តិនេះត្រូវគ្រប់គ្រងនិងអនុវត្តដោយអាជ្ញាធរគយរបស់ភាគីនីមួយៗទាក់ទងនឹងការនាំចូល ការនាំចេញ និងការដឹកទំនិញឆ្លងកាត់ នៅពេលមានការពាក់ព័ន្ធនឹងពន្ធគយ ការយកថ្លៃប្រភេទណាមួយ ឬពន្ធផ្សេងទៀត ឬការហាមឃាត់ ការរឹតត្បិត និងការត្រួតពិនិត្យទាក់ទងនឹងការផ្លាស់ទីទំនិញត្រួតពិនិត្យឆ្លងកាត់ដែនសមត្ថកិច្ចនៃអាជ្ញាធរគយរបស់ភាគីនីមួយៗ។

[៧] លក្ខខណ្ឌតម្រូវក្នុងការចែករំលែកគំរូហត្ថលេខាគឺមិនចាំបាច់ទេ ករណីដែលអាជ្ញាធរចេញវិញ្ញាបនបត្របានបង្កើតគេហទំព័រដែលមានព័ត៌មានពាក់ព័ន្ធនៃវិញ្ញាបនបត្រដើមកំណើតដែលភាគីនាំចូលអាចចូលមើលបាន។

(ខ) ព័ត៌មានខាងលើនេះត្រូវផ្តល់ជូនដោយមន្ត្រីទំនាក់ទំនង តាមមធ្យោបាយអេឡិចត្រូនិក ឱ្យបាន យ៉ាងតិចមួយខែមុនពេលចូលជាធរមាន។ ភាគីមួយត្រូវជូនដំណឹងភ្លាមៗដល់ភាគីមួយទៀត អំពីការផ្លាស់ប្តូរឈ្មោះ អាសយដ្ឋាន ឬត្រាផ្លូវការ តាមមធ្យោបាយដូចគ្នា។

(គ) ភាគីមួយត្រូវផ្តល់ការបញ្ជាក់ភ្លាមៗទៅភាគីមួយទៀតអំពីការទទួលបានព័ត៌មានខាងលើនោះ និងការផ្លាស់ប្តូរណាមួយនោះ។

## វិធាន ៤

សម្រាប់គោលបំណងក្នុងការផ្ទៀងផ្ទាត់លក្ខខណ្ឌសម្រាប់ប្រព្រឹត្តិកម្មអនុគ្រោះពន្ធគយ អាជ្ញាធរចេញវិញ្ញាបនបត្រត្រូវមានសិទ្ធិស្នើសុំភស្តុតាងឯកសារគាំទ្រ ឬអនុវត្តការត្រួតពិនិត្យដែលចាត់ទុកថាសមរម្យ។ ប្រសិនបើសិទ្ធិនេះមិនអាចទទួលបានតាមរយៈច្បាប់ បទប្បញ្ញត្តិ និងវិធានរដ្ឋបាលផ្ទៃក្នុងដែលមានស្រាប់ សិទ្ធិនោះត្រូវដាក់បញ្ចូលជាប្រយោគក្នុងពាក្យស្នើសុំដូចមានចែងក្នុងវិធាន៥ និង៦នៃផ្នែកនេះ។

## ពាក្យស្នើសុំវិញ្ញាបនបត្រដើមកំណើត

## វិធាន ៥

(ក) អ្នកនាំចេញ និង/ឬអ្នកផលិតទំនិញដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ប្រព្រឹត្តិកម្មអនុគ្រោះពន្ធគយ ត្រូវដាក់សំណើទៅអាជ្ញាធរចេញវិញ្ញាបនបត្រដើម្បីស្នើសុំឱ្យមានការផ្ទៀងផ្ទាត់ដើមកំណើតទំនិញមុននាំចេញ។ លទ្ធផលនៃការផ្ទៀងផ្ទាត់នេះដែលជាកម្មវត្ថុនៃការពិនិត្យជាទៀងទាត់ ឬនៅពេលសមស្របណាមួយ ត្រូវទទួលយកជាភស្តុតាងគាំទ្រក្នុងការផ្ទៀងផ្ទាត់ដើមកំណើតនៃទំនិញនាំចេញនោះនាពេលក្រោយ។ ការផ្ទៀងផ្ទាត់មុនការនាំចេញអាចមិនអនុវត្តចំពោះទំនិញដែលដើមកំណើតអាចផ្ទៀងផ្ទាត់បានដោយងាយ តាមលក្ខណៈធម្មជាតិរបស់ទំនិញនោះ។

(ខ) សម្រាប់វត្ថុធាតុដែលត្រូវបានផ្គត់ផ្គង់ក្នុងស្រុក ស្វ័យប្រតិវេទន៍ដោយអ្នកផលិតចុងក្រោយដែលនាំចេញក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិនត្រូវប្រើជាមូលដ្ឋាន នៅពេលដាក់ពាក្យស្នើសុំឱ្យចេញវិញ្ញាបនបត្រដើមកំណើត។

## វិធាន ៦

នៅពេលអនុវត្តបែបបទសម្រាប់នាំចេញទំនិញក្រោមប្រព្រឹត្តិកម្មអនុគ្រោះ អ្នកនាំចេញ ឬតំណាងដែលទទួលបានសិទ្ធិត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រដើមកំណើតរួមជាមួយឯកសារគាំទ្រសមស្របដែលបង្ហាញថាទំនិញនាំចេញនោះមានគុណវុឌ្ឍិគ្រប់គ្រាន់សម្រាប់ការចេញវិញ្ញាបនបត្រដើមកំណើត[៨]។

---

[៨] អ្នកផលិតអាចដាក់ពាក្យស្នើសុំវិញ្ញាបនបត្រដើមកំណើត ក្នុងករណីដែលអ្នកផលិតនោះត្រូវការផ្តល់សិទ្ធិដល់ភ្នាក់ងារផ្សេងឱ្យនាំចេញក្នុងនាមរបស់ខ្លួន។

## ការពិនិត្យមុននាំចេញ

### វិធាន ៧

ផ្អែកតាមសមត្ថកិច្ចនិងលទ្ធភាពដែលមាន អាជ្ញាធរចេញវិញ្ញាបនបត្រនៃភាគីនីមួយៗត្រូវអនុវត្តការពិនិត្យឱ្យបានត្រឹមត្រូវលើពាក្យស្នើសុំនីមួយៗសម្រាប់វិញ្ញាបនបត្រដើមកំណើត ដើម្បីធានាថា៖

(ក) ពាក្យស្នើសុំ និងវិញ្ញាបនបត្រដើមកំណើតត្រូវបំពេញឱ្យបានត្រឹមត្រូវដោយអនុលោមតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងកំណត់សម្គាល់នៅទំព័រខាងខ្នងនៃវិញ្ញាបនបត្រដើមកំណើត និងចុះហត្ថលេខាដោយហត្ថលេខីដែលទទួលបានសិទ្ធិ

(ខ) ដើមកំណើតទំនិញនោះ មានអនុលោមភាពតាមវិធានដើមកំណើតរបស់កិច្ចព្រមព្រៀង CCFTA

(គ) ព័ត៌មានលម្អិតផ្សេងទៀតនៅក្នុងវិញ្ញាបនបត្រដើមកំណើតត្រូវស្របគ្នាទៅនឹងភស្តុតាងឯកសារគាំទ្រដែលបានដាក់ជូន

(ឃ) ការពិពណ៌នា បរិមាណ និងទម្ងន់នៃទំនិញនោះ ម៉ាកសញ្ញា និងចំនួនកញ្ចប់ ចំនួននិងប្រភេទកញ្ចប់ ដូចបានបញ្ជាក់ស្របទៅនឹងទំនិញត្រូវនាំចេញនោះ

(ង) ទំនិញច្រើនមុខដែលបានធ្វើប្រតិវេទន៍នៅលើវិញ្ញាបនបត្រដើមកំណើតតែមួយត្រូវបានអនុញ្ញាតដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងវិធានរដ្ឋបាលក្នុងស្រុករបស់ភាគីនាំចូល ប្រសិនបើទំនិញនីមួយៗមានលក្ខណៈសម្បត្តិគ្រប់គ្រាន់រៀងៗខ្លួន។

## ការចេញវិញ្ញាបនបត្រដើមកំណើត

### វិធាន ៨

(ក) វិញ្ញាបនបត្រដើមកំណើតត្រូវតែជាក្រដាសពណ៌សមានទំហំ ISO A4 ដោយមានអនុលោមភាពតាមគំរូក្នុងឧបសម្ព័ន្ធ៣។ វិញ្ញាបនបត្រដើមកំណើតត្រូវបំពេញជាភាសាអង់គ្លេស ហើយត្រូវមានហត្ថលេខា និងត្រាផ្លូវការដែលទទួលបានសិទ្ធិពីអាជ្ញាធរចេញវិញ្ញាបនបត្រដើមកំណើតនៃភាគីនាំចេញ។ ហត្ថលេខា និងត្រានោះត្រូវបានធ្វើឡើងដោយដៃ ឬតាមអេឡិចត្រូនិក។ វិញ្ញាបនបត្រដើមកំណើតត្រូវមានច្បាប់ដើមមួយ និងច្បាប់ចម្លងពីរច្បាប់ គឺច្បាប់ចម្លងសន្លឹកទីពីរ (Duplicate) និងច្បាប់ចម្លងសន្លឹកទី៣ (Triplicate)។

(ខ) ចំពោះវិញ្ញាបនបត្រដើមកំណើតដែលមានច្រើនទំព័រ ភាគីទាំងពីរត្រូវប្រើគំរូភ្ជាប់ដូចមានក្នុងឧបសម្ព័ន្ធ៣។ ទំព័របន្តបន្ទាប់ត្រូវមានហត្ថលេខា ត្រា និងលេខយោងដូចគ្នានឹងទំព័រដំបូង។

(គ) វិញ្ញាបនបត្រដើមកំណើតនីមួយៗត្រូវមានលេខយោងដោយឡែកមួយ និងមានទំនិញមួយឬច្រើនមុខសម្រាប់ការដឹកជញ្ជូនតែមួយ។

(ឃ) វិញ្ញាបនបត្រដើមកំណើតច្បាប់ដើមត្រូវបញ្ជូនបន្តដោយអ្នកនាំចេញទៅអ្នកនាំចូល សម្រាប់ដាក់ជូនអាជ្ញាធរគយនៅកំពង់ផែ ឬកន្លែងនាំចូល ប្រសិនបើមានការតម្រូវឱ្យដាក់ជូនវិញ្ញាបនបត្រដើមកំណើតច្បាប់ដើមដោយអាជ្ញាធរគយនៃភាគីនាំចូល។ ច្បាប់ចម្លងសន្លឹកទីពីរ (Duplicate) ត្រូវរក្សាទុកដោយអាជ្ញាធរចេញវិញ្ញាបនបត្ររបស់ភាគីនាំចេញ។ ច្បាប់ចម្លងសន្លឹកទីបី (Triplicate) ត្រូវរក្សាទុកដោយអ្នកនាំចេញ។

(ង) ក្នុងករណីដែលវិញ្ញាបនបត្រដើមកំណើតត្រូវបានបដិសេធដោយអាជ្ញាធរគយនៃភាគីនាំចូល វិញ្ញាបនបត្រដើមកំណើតដែលបដិសេធនោះត្រូវគូសកំណត់សម្គាល់ក្នុងប្រអប់៤។

(ច) ក្នុងករណីដែលវិញ្ញាបនបត្រដើមកំណើតមិនត្រូវបានទទួលយក ដូចមានចែងក្នុងកថាខណ្ឌ (ង) អាជ្ញាធរគយនៃភាគីនាំចូលត្រូវពិចារណាលើការបញ្ជាក់របស់អាជ្ញាធរចេញវិញ្ញាបនបត្រនៃភាគីនាំចេញ ហើយវាយតម្លៃថាតើវិញ្ញាបនបត្រដើមកំណើតអាចទទួលយកបានក្នុងការផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះពន្ធគយដែរឬទេ។ ការបញ្ជាក់ត្រូវធ្វើឱ្យបានលម្អិត និងពេញលេញក្នុងការឆ្លើយតបទៅនឹងមូលហេតុនៃការបដិសេធលើប្រព្រឹត្តិកម្មអនុគ្រោះពន្ធគយដែលបានលើកឡើងដោយភាគីនាំចូល។

## វិធាន ៩

ដើម្បីអនុវត្តបទប្បញ្ញត្តិរបស់មាត្រា ៣.២ (ទំនិញមានដើមកំណើត) នៃជំពូកនេះ ក្រោមកិច្ចព្រមព្រៀង CCFTA វិញ្ញាបនបត្រដើមកំណើតដែលចេញដោយភាគីនាំចេញត្រូវបង្ហាញពីលក្ខណៈវិនិច្ឆ័យដើមកំណើត ឬភាគរយនៃសមាសធាតុតម្លៃតំបន់របស់កិច្ចព្រមព្រៀង CCFTA ដែលប្រើនៅក្នុងប្រអប់៨។

## វិធាន ១០

ការកោសលុប ឬការសរសេរត្រួតគ្នា មិនត្រូវបានអនុញ្ញាតឱ្យមាននៅលើវិញ្ញាបនបត្រដើមកំណើតឡើយ។ ការកែប្រែណាមួយត្រូវធ្វើឡើងដោយការឆូតចោលពាក្យខុស និងសរសេរបន្ថែមទៀត។ ការកែប្រែនេះ ត្រូវមានការយល់ព្រមដោយមន្ត្រីដែលទទួលបានសិទ្ធិចុះហត្ថលេខាលើវិញ្ញាបនបត្រដើមកំណើត និងបញ្ជាក់ដោយត្រាផ្លូវការ ឬតែមកែតម្រូវរបស់អាជ្ញាធរចេញវិញ្ញាបនបត្រ។ ប្រអប់ទំនេរ ត្រូវគូសសញ្ញាខ្វែងដើម្បីចៀសវាងការសរសេរបន្ថែម។

## វិធាន ១១

ជាគោលការណ៍ វិញ្ញាបនបត្រដើមកំណើតត្រូវចេញជូនមុនពេលឬនៅពេលដឹកទំនិញ។ ក្នុងករណីលើកលែងខ្លះដែលវិញ្ញាបនបត្រដើមកំណើតមិនបានចេញជូននៅពេលដឹកទំនិញ ឬមិនលើសពីបី (០៣) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទដឹកទំនិញ តាមសំណើអ្នកនាំចេញ ដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងវិធានរដ្ឋបាលក្នុងស្រុកនៃភាគីនាំចេញ វិញ្ញាបនបត្រដើមកំណើតត្រូវចេញជាប្រតិសកម្ម ក្នុងរយៈពេល

ដប់ពីរ (១២) ខែ គិតចាប់ពីកាលបរិច្ឆេទដឹកទំនិញ ដែលករណីនេះ ចាំបាច់ត្រូវបង្ហាញដោយឃ្លា "ISSUED RETROACTIVELY" ក្នុងប្រអប់១៣។ ក្នុងករណីនេះ អ្នកនាំចេញដែលស្នើសុំប្រព្រឹត្តិកម្មអនុគ្រោះពន្ធគយសម្រាប់ទំនិញ អាចផ្តល់ជូនអាជ្ញាធរគយរបស់ភាគីនាំចូលនូវវិញ្ញាបនបត្រដើមកំណើតដែលចេញដោយប្រតិសកម្ម ដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងវិធានរដ្ឋបាលក្នុងស្រុកនៃភាគីនាំចូល។

## វិធាន ១២

ក្នុងករណីដែលវិញ្ញាបនបត្រដើមកំណើតត្រូវបានលួច បាត់បង់ ឬខូចខាត អ្នកនាំចេញអាចដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរដែលធ្លាប់បានចេញវិញ្ញាបនបត្រជូន ដើម្បីចេញច្បាប់ចម្លងដែលមានបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើមនិងច្បាប់ចម្លងសន្លឹកទីបី (Triplicate) ផ្អែកលើមូលដ្ឋានឯកសារនាំចេញដែលមាន ហើយត្រូវមានពាក្យ "CERTIFIED TRUE COPY" ក្នុងប្រអប់១២។ ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវតាមវិញ្ញាបនបត្រដើមកំណើតច្បាប់ដើមត្រូវមានកាលបរិច្ឆេទរបស់វិញ្ញាបនបត្រដើមកំណើតច្បាប់ដើម។ ច្បាប់ចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវតាមវិញ្ញាបនបត្រដើមកំណើតច្បាប់ដើមត្រូវចេញជូនមិនឱ្យលើសពីរយៈពេលមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចេញវិញ្ញាបនបត្រដើមកំណើតច្បាប់ដើម ហើយក្នុងលក្ខខណ្ឌដែលអ្នកនាំចេញផ្តល់ជូនអាជ្ញាធរចេញវិញ្ញាបនបត្រពាក់ព័ន្ធនូវច្បាប់ចម្លងសន្លឹកទីបី (Triplicate) នៃវិញ្ញាបនបត្រដើមកំណើត ឬកស្តុតាងណាមួយនៃការចេញវិញ្ញាបនបត្រដើមកំណើតច្បាប់ដើម។

## ការបង្ហាញ

## វិធាន ១៣

វិញ្ញាបនបត្រដើមកំណើតច្បាប់ដើមត្រូវដាក់ជូនអាជ្ញាធរគយនៃភាគីនាំចូល នៅពេលធ្វើប្រតិវេទន៍នាំចូលទំនិញពាក់ព័ន្ធដែលស្នើសុំប្រើប្រាស់ប្រព្រឹត្តិកម្មអនុគ្រោះពន្ធគយ ដោយដៃ ឬដោយអេឡិចត្រូនិកស្របតាមច្បាប់ បទប្បញ្ញត្តិ និងវិធានរដ្ឋបាលក្នុងស្រុកនៃភាគីនាំចូល។

## វិធាន ១៤

វិញ្ញាបនបត្រដើមកំណើតត្រូវមានសុពលភាពរយៈពេលមួយ (១) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចេញវិញ្ញាបនបត្រដើមកំណើត។ ប្រសិនបើការដាក់ជូនវិញ្ញាបនបត្រដើមកំណើតត្រូវតម្រូវដោយអាជ្ញាធរគយនៃភាគីនាំចូល ការដាក់ជូននេះត្រូវធ្វើឡើងក្នុងអំឡុងពេលដូចបានកំណត់នេះ។

## វិធាន ១៥

(ក) ក្នុងករណីការបញ្ជូនទំនិញដែលមានដើមកំណើតនៅក្នុងភាគីនាំចេញ និងមានតម្លៃ FOB មិនលើស ២០០ ដុល្លារអាមេរិក ការចេញវិញ្ញាបនបត្រដើមកំណើតត្រូវលើកលែង ហើយការប្រើនូវប្រតិវេទន៍សាមញ្ញដោយអ្នកនាំចេញដែលបញ្ជាក់ថាទំនិញនោះមានដើមកំណើតនៅ

ប្រទេសនាំចេញត្រូវទទួលយក។ ទំនិញដែលបានផ្ញើតាមរយៈប៉ុស្តិ៍ប្រៃសណីយ៍ ហើយមានតម្លៃ FOB មិនលើសពី ២០០ ដុល្លារអាមេរិក ត្រូវអនុវត្តស្រដៀងគ្នានេះផងដែរ។

(ខ) ការលើកលែងដូចមានចែងក្នុងកថាខណ្ឌ (ក) មិនត្រូវយកមកអនុវត្ត នៅពេលអាជ្ញាធរគយនៃភាគីនាំចូលរកឃើញថា ការនាំចូលបង្កើតជាផ្នែកនៃការនាំចូលច្រើនដង ក្រោមហេតុផលណាមួយអាចចាត់ទុកថាបានប្រព្រឹត្តទៅ ឬរៀបចំឡើងក្នុងគោលបំណងគេចវេសពីការដាក់ជូនវិញ្ញាបនបត្រដើមកំណើតទំនិញមួយ ឬច្រើន។

## វិធាន ១៦

(ក) នៅពេលគ្មានការសង្ស័យលើដើមកំណើតទំនិញក្រោមកិច្ចព្រមព្រៀង CCFTA ការរកឃើញនូវភាពលម្អៀងតិចតួចដូចជាភាពខុសគ្នារវាងការចាត់ថ្នាក់លេខកូដទំនិញលើឯកសារវិញ្ញាបនបត្រដើមកំណើត និងនៅលើឯកសារផ្សេងទៀតដែលដាក់ជូនអាជ្ញាធរគយនៃភាគីនាំចូល ក្នុងគោលបំណងបំពេញបែបបទនាំចូលទំនិញ *ក្នុងតថភាពបែបនេះ* មិនត្រូវធ្វើមោឃភាពចំពោះវិញ្ញាបនបត្រដើមកំណើតឡើយ ប្រសិនបើការពិតមានភាពស្របគ្នាទៅនឹងទំនិញដែលបានដាក់ជូន។

(ខ) ក្នុងករណីមានភាពលម្អៀងតិចតួចរវាងភាគីនាំចេញ និងភាគីនាំចូលដូចមានចែងក្នុងកថាខណ្ឌ (ក) ទំនិញនោះត្រូវបញ្ចេញដោយមិនមានការពន្យារពេល ដោយអនុលោមតាមវិធានរដ្ឋបាលដូចជា ការកំណត់ពន្ធគយនៅអត្រាអនុវត្តន៍ដែលខ្ពស់ជាងមុន ឬការតម្កល់និមុត្តិធានាក្នុងបរិមាណសមមូលជាដើម។ នៅពេលដែលភាពលម្អៀងនេះត្រូវបានដោះស្រាយរួច អត្រាពន្ធគយក្រោមកិច្ចព្រមព្រៀងCCFTA ដែលត្រឹមត្រូវនឹងត្រូវយកមកអនុវត្ត និងពន្ធដែលបានបង់លើសត្រូវសង ត្រឡប់ទៅវិញ ស្របតាមច្បាប់ បទប្បញ្ញត្តិ និងវិធានរដ្ឋបាលរបស់ភាគីនាំចូល។

(គ) ចំពោះទំនិញច្រើនមុខដែលបានធ្វើប្រតិវេទន៍ក្រោមវិញ្ញាបនបត្រដើមកំណើតតែមួយ ករណីបញ្ហាណាមួយកើតមានចំពោះទំនិញណាមួយដែលមានរាយនាមក្នុងវិញ្ញាបនបត្រនោះ មិនត្រូវប៉ះពាល់ ឬពន្យារពេលការផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះពន្ធគយ និងបញ្ចេញទំនិញផ្សេងទៀតពីគយដែលមាននៅក្នុងវិញ្ញាបនបត្រដើមកំណើត។ វិធាន ១៧ (ក)(ii) នៃជំពូកនេះអាចនឹងយកមកអនុវត្តចំពោះមុខទំនិញដែលមានបញ្ហា។

## វិធាន ១៧

(ក) អាជ្ញាធរគយនៃភាគីនាំចូលអាចស្នើសុំការត្រួតពិនិត្យជាប្រតិសកម្មដោយចៃដន្យ និង/ឬ នៅពេលដែលមានការសង្ស័យដោយសមហេតុផលណាមួយអំពីយថាភូតភាពនៃឯកសារ ឬអំពីភាពត្រឹមត្រូវនៃព័ត៌មានដែលទាក់ទងនឹងដើមកំណើតពិតប្រាកដនៃទំនិញដែលមានការសង្ស័យ ឬផ្នែកខ្លះរបស់ទំនិញនោះ។

(i) សំណើសុំនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយភ្ជាប់ជាមួយនូវច្បាប់ចម្លងវិញ្ញាបនបត្រដើមកំណើត ហើយត្រូវបញ្ជាក់នូវហេតុផល និងព័ត៌មានបន្ថែមណាមួយ ដែលបង្ហាញថាព័ត៌មានដែលបានបង្ហាញលើវិញ្ញាបនបត្រដើមកំណើតនោះអាចមានភាពមិនត្រឹមត្រូវ លុះត្រាតែការត្រួតពិនិត្យជាប្រតិសកម្មត្រូវបានស្នើដោយផ្អែកលើមូលដ្ឋានត្រួតពិនិត្យដោយចៃដន្យ។

(ii) អាជ្ញាធរគយនៃភាគីនាំចូលអាចព្យួរការផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះពន្ធគយក្នុងអំឡុងពេលរង់ចាំលទ្ធផលនៃការផ្ទៀងផ្ទាត់។ ទោះជាយ៉ាងនេះក្តី អាជ្ញាធរគយនៃភាគីនាំចូលអាចបញ្ចេញទំនិញទៅអ្នកនាំចូល ដោយអនុលោមតាមវិធានការរដ្ឋបាលដែលចាត់ទុកថាចាំបាច់ រួមមានការកំណត់ពន្ធគយនៅអត្រាអនុវត្តន៍ខ្ពស់ជាងមុន ឬការតម្កល់និមុត្តិជានាក្នុងបរិមាណសមមូលជាដើម ប្រសិនបើទំនិញនោះមិនស្ថិតក្រោមការហាមឃាត់ ឬការដាក់កម្រិតនាំចូល ហើយមិនមានការសង្ស័យលើការបន្លំណាមួយ។

(iii) អាជ្ញាធរគយ ឬអាជ្ញាធរចេញវិញ្ញាបនបត្រដើមកំណើតនៃភាគីនាំចេញដែលទទួលបានសំណើត្រួតពិនិត្យជាប្រតិសកម្មត្រូវឆ្លើយតបទៅនឹងសំណើភ្លាមៗ និងមិនឱ្យលើសពីកៅសិប (៩០) ថ្ងៃបន្ទាប់ពីទទួលបានសំណើ។ អាជ្ញាធរគយ ឬអាជ្ញាធរចេញវិញ្ញាបនបត្រដើមកំណើតនៃភាគីនាំចេញអាចស្នើសុំពន្យារពេលជាលាយលក្ខណ៍អក្សរបានរហូតដល់ទៅកៅសិប (៩០) ថ្ងៃ ដរាបណាសំណើសុំពន្យារពេលនេះត្រូវបានធ្វើឡើងក្នុងអំឡុងពេលកៅសិប (៩០) ថ្ងៃដំបូង។

(ខ) ក្នុងករណីពិសេស ប្រសិនបើអាជ្ញាធរគយនៃភាគីនាំចូលមិនអាចទទួលយកលទ្ធផលនៃការត្រួតពិនិត្យជាប្រតិសកម្មនេះ អាជ្ញាធរគយនៃភាគីនាំចូលនោះអាចស្នើសុំធ្វើទស្សនកិច្ចផ្ទៀងផ្ទាត់នៅភាគីនាំចេញ។

(i) មុនពេលធ្វើទស្សនកិច្ចផ្ទៀងផ្ទាត់ស្របតាមបទប្បញ្ញត្តិនេះ អាជ្ញាធរគយនៃភាគីនាំចូលត្រូវជូនដំណឹងទៅអាជ្ញាធរមានសមត្ថកិច្ចនៃភាគីនាំចេញ ដើម្បីឈានដល់ការឯកភាពគ្នាទៅវិញទៅមកលើលក្ខខណ្ឌ និងមធ្យោបាយនៃការធ្វើទស្សនកិច្ចផ្ទៀងផ្ទាត់នេះ។

(ii) ការធ្វើទស្សនកិច្ចផ្ទៀងផ្ទាត់ត្រូវធ្វើឡើងមិនឱ្យលើសពីហុកសិប (៦០) ថ្ងៃ បន្ទាប់ពីទទួលបានការជូនដំណឹងស្របតាមវាក្យខណ្ឌ (ខ)(១)។

(គ) ដំណើរការផ្ទៀងផ្ទាត់ រួមទាំងការត្រួតពិនិត្យជាប្រតិសកម្មនិងទស្សនកិច្ចផ្ទៀងផ្ទាត់ ត្រូវអនុវត្ត ហើយលទ្ធផលទស្សនកិច្ចផ្ទៀងផ្ទាត់ត្រូវជូនដំណឹងទៅអាជ្ញាធរគយ និង/ឬអាជ្ញាធរចេញវិញ្ញាបនបត្រដើមកំណើតនៃភាគីនាំចេញក្នុងអំឡុងពេលយ៉ាងយូរបំផុតមួយរយប៉ែតសិប(១៨០) ថ្ងៃបន្ទាប់ពីទទួលបានសំណើ។ ក្នុងករណីដែលសំណើពន្យារពេល ស្របតាមវាក្យខណ្ឌ (ក)(៣) ត្រូវបានស្នើសុំ នោះដំណើរការផ្ទៀងផ្ទាត់ រួមទាំងការត្រួតពិនិត្យជាប្រតិសកម្មនិងទស្សនកិច្ចផ្ទៀងផ្ទាត់ ត្រូវអនុវត្ត ហើយលទ្ធផលនៃការផ្ទៀងផ្ទាត់ដែលជូនដំណឹងទៅអាជ្ញាធរគយ និង/ឬអាជ្ញាធរចេញវិញ្ញាបនបត្រដើមកំណើតនៃភាគីនាំចេញ ត្រូវពន្យារពេលពីមួយរយប៉ែតសិប

(១៨០) ថ្ងៃ ទៅយ៉ាងយូរបំផុតពីររយចិតសិប (២៧០) ថ្ងៃ បន្ទាប់ពីទទួលបានសំណើ។ ក្នុងអំឡុងពេលរង់ចាំលទ្ធផលនៃទស្សនកិច្ចផ្ទៀងផ្ទាត់នេះ វាក្យខណ្ឌ (ក)(២) លើការព្យួរប្រព្រឹត្តិកម្មអនុគ្រោះពន្ធគយត្រូវអនុវត្ត។

(ឃ) រាល់ការដោះដូរព័ត៌មានពាក់ព័ន្ធនឹងសំណើផ្ទៀងផ្ទាត់នេះ គួរធ្វើឡើងតាមរយៈមន្ត្រីទំនាក់ទំនងរបស់ភាគីទាំងពីរ តែប៉ុណ្ណោះ។

(ង) ប្រព្រឹត្តិកម្មអនុគ្រោះពន្ធគយអាចត្រូវបានបដិសេធ ក្នុងករណីអាជ្ញាធរគយនៃភាគីនាំចូលមិនអាចទទួលយកបាននូវការឆ្លើយតបរបស់ភាគីនាំចេញលើសំណើរបស់អាជ្ញាធរគយនៃភាគីនាំចូលក្នុងដំណើរការត្រួតពិនិត្យជាប្រតិសកម្ម ឬដំណើរការផ្ទៀងផ្ទាត់តាមករណីជាក់ស្តែង ក្នុងអំឡុងពេលសម្រាប់ការផ្ទៀងផ្ទាត់ដូចមានចែងក្នុងកថាខណ្ឌ (ក) (ខ) និង (គ)។

(ច) ភាគីនីមួយៗត្រូវរក្សាការសម្ងាត់នូវរាល់ព័ត៌មាននិងឯកសារដែលផ្តល់ដោយភាគីមួយទៀតក្នុងដំណើរការផ្ទៀងផ្ទាត់។ ព័ត៌មាននិងឯកសារទាំងនេះមិនត្រូវយកមកប្រើក្នុងគោលបំណងផ្សេងឡើយ រួមទាំងការប្រើជាភស្តុតាងក្នុងនីតិវិធីរដ្ឋបាលនិងតុលាការ ប្រសិនបើគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរច្បាស់លាស់របស់ភាគីដែលផ្តល់ព័ត៌មាននោះ។

## តម្កល់ការរក្សាទុកឯកសារ
## វិធាន ១៨

(ក) ពាក្យស្នើសុំវិញ្ញាបនបត្រដើមកំណើត និងរាល់ឯកសារពាក់ព័ន្ធនឹងពាក្យស្នើសុំនេះត្រូវរក្សាទុកដោយអាជ្ញាធរចេញវិញ្ញាបនបត្រដើមកំណើតមិនឱ្យតិចជាងរយៈពេលបី (០៣) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចេញវិញ្ញាបនបត្រដើមកំណើត។

(ខ) ព័ត៌មានពាក់ព័ន្ធនឹងសុពលភាពនៃវិញ្ញាបនបត្រដើមកំណើតត្រូវផ្តល់ឱ្យកាលណាមានការស្នើសុំដោយភាគីនាំចូល

(គ) រាល់ព័ត៌មានដែលប្រាស្រ័យទាក់ទងគ្នារវាងភាគីទាំងពីរត្រូវចាត់ទុកជាការសម្ងាត់ និងត្រូវប្រើសម្រាប់តែក្នុងគោលបំណងបញ្ជាក់សុពលភាពនៃវិញ្ញាបនបត្រដើមកំណើតតែប៉ុណ្ណោះ។

(ឃ) សម្រាប់គោលបំណងនៃដំណើរការផ្ទៀងផ្ទាត់/ត្រួតពិនិត្យជាប្រតិសកម្ម ស្របតាមវិធាន ១៧ នៃផ្នែកនេះ អ្នកផលិត និង/ឬ អ្នកនាំចេញដែលដាក់ពាក្យស្នើសុំវិញ្ញាបនបត្រដើមកំណើតត្រូវរក្សាទុកឯកសារគាំទ្រពាក្យស្នើសុំនោះមិនឱ្យតិចជាងបី (០៣) ឆ្នាំគិតចាប់ពីកាលបរិច្ឆេទនៃការចេញវិញ្ញាបនបត្រដើមកំណើត ដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងវិធានរដ្ឋបាលក្នុងស្រុកនៃភាគីនាំចេញ។

## ករណីពិសេស
## វិធាន ១៩

សម្រាប់គោលបំណងនៃការអនុវត្តមាត្រា ៣.៨ (ការបញ្ជូនទំនិញដោយផ្ទាល់) នៃវិធានដើមកំណើតក្រោមកិច្ចព្រមព្រៀងCCFTA ក្នុងករណីដែលការដឹកជញ្ជូនត្រូវឆ្លងកាត់ដែនដីនៃភាគីមួយឬច្រើនដែលមិនមែនជាភាគីនៃកិច្ចព្រមព្រៀង នោះឯកសារខាងក្រោមត្រូវដាក់ជូនអាជ្ញាធរគយនៃភាគីនាំចូល៖

(ក) អញ្ញត្តិប័ណ្ណដឹកជញ្ជូនពីដើមទីដល់ចុងទី (Through Bill of Lading) ដែលចេញដោយភាគីនាំចេញ

(ខ) វិញ្ញាបនបត្រដើមកំណើតចេញដោយអាជ្ញាធរចេញវិញ្ញាបនបត្រមានសមត្ថកិច្ចនៃភាគីនាំចេញ

(គ) វិក្កយបត្រពាណិជ្ជកម្មច្បាប់ដើមនៃទំនិញនោះ មួយច្បាប់ និង

(ឃ) ឯកសារគាំទ្រដើម្បីជាភស្តុតាងបង្ហាញពីអនុលោមភាពតាមលក្ខខណ្ឌតម្រូវនៃវាក្យខណ្ឌ (ខ)(១) (ខ)(២) និង (ខ)(៣) នៃកថាខណ្ឌ ២ នៃមាត្រា ៨ នៃវិធានដើមកំណើតនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន។

## វិធាន ២០

(ក) ចំពោះផលិតផលដែលបញ្ជូនពីភាគីនាំចេញសម្រាប់ការតាំងពិព័រណ៍នៅក្នុងដែនដីនៃភាគីមួយទៀត និងត្រូវបានលក់ក្នុងអំឡុងពេលឬបន្ទាប់ពីការដាក់តាំងពិព័រណ៍ ការនាំចូលនោះត្រូវទទួលបានប្រព្រឹត្តិកម្មអនុគ្រោះពន្ធគយក្រោមលក្ខខណ្ឌដែលផលិតផលនោះបានបំពេញតាមលក្ខខណ្ឌតម្រូវនៃវិធានដើមកំណើតនៃកិច្ចព្រមព្រៀង CCFTA ប្រសិនបើទំនិញនោះអាចទទួលយកបានដោយអាជ្ញាធរគយនៃភាគីនាំចូល ក្នុងលក្ខខណ្ឌ៖

(i) អ្នកនាំចេញបានបញ្ជូនផលិតផលទាំងនោះពីដែនដីនៃភាគីនាំចេញទៅកាន់ភាគីមួយទៀតដែលរៀបចំការតាំងពិព័រណ៍ ហើយបានដាក់តាំងបង្ហាញផលិតផលនៅទីនោះ

(ii) អ្នកនាំចេញនោះបានលក់ឬផ្ទេរផលិតផលនោះទៅកាន់អ្នកទទួលផលិតផលនៅក្នុងភាគីនាំចូល និង

(iii) ផលិតផលនោះត្រូវបានបញ្ជូនក្នុងអំឡុងពេលតាំងពិព័រណ៍ ឬភ្លាមៗក្រោយការតាំងពិព័រណ៍ទៅកាន់ភាគីនាំចូលក្នុងសភាពដែលត្រូវបានបញ្ជូនសម្រាប់ការតាំងពិព័រណ៍។

(ខ) សម្រាប់គោលបំណងនៃការអនុវត្តបទប្បញ្ញត្តិខាងលើ វិញ្ញាបនបត្រដើមកំណើតត្រូវដាក់ជូនអាជ្ញាធរគយនៃភាគីនាំចូល។ ឈ្មោះនិងអាសយដ្ឋាននៃការតាំងពិព័រណ៍ និងវិញ្ញាបនបត្រចេញដោយអាជ្ញាធរចេញវិញ្ញាបនបត្រនៃភាគីរៀបចំការតាំងពិព័រណ៍ត្រូវបង្ហាញដោយភ្ជាប់ជាមួយនឹងឯកសារគាំទ្រដូចមានចែងក្នុងវិធាន ១៩(ឃ) នៃផ្នែកនេះ តាមការចាំបាច់។

(គ) កថាខណ្ឌ (ក) ត្រូវអនុវត្តចំពោះការតាំងពិព័រណ៌ពាណិជ្ជកម្ម កសិកម្ម ឬសិប្បកម្មណាមួយ ឬការតាំងបង្ហាញប្រហាក់ប្រហែល ឬការតាំងបង្ហាញនៅក្នុងហាង ឬអគារពាណិជ្ជកម្ម សម្រាប់លក់ផលិតផលបរទេស និងទីកន្លែងដែលផលិតផលនោះស្ថិតក្រោមការគ្រប់គ្រងរបស់គយក្នុងអំឡុងពេលតាំងពិព័រណ៌។

## វិធាន ២១

អាជ្ញាធរគយនៃភាគីនាំចូលត្រូវទទួលយកវិញ្ញាបនបត្រដើមកំណើតក្នុងករណីដែលវិក្កយបត្រលក់ត្រូវបានចេញដោយក្រុមហ៊ុនដែលមាននិវេសនដ្ឋាននៅប្រទេសទីបី ឬដោយអ្នកនាំចេញក្រោមកិច្ចព្រមព្រៀង CCFTA ជំនួសឱ្យក្រុមហ៊ុននោះ ប្រសិនបើផលិតផលនោះអាចបំពេញបាននូវលក្ខខណ្ឌតម្រូវនៃវិធានដើមកំណើតក្រោមកិច្ចព្រមព្រៀងCCFTA ។ លេខវិក្កយបត្រដើម ឬលេខវិក្កយបត្រដែលចេញដោយភាគីទីបីត្រូវបង្ហាញក្នុងប្រអប់១០ នៃវិញ្ញាបនបត្រដើមកំណើត អ្នកនាំចេញនិងអ្នកទទួលទំនិញត្រូវមាននិវេសនដ្ឋាននៅក្នុងដែនដីនៃភាគីទាំងពីរ ហើយវិក្កយបត្រចេញដោយភាគីទី៣ត្រូវភ្ជាប់ជាមួយវិញ្ញាបនបត្រដើមកំណើតនៅពេលបង្ហាញវិញ្ញាបនបត្រដើមកំណើតនោះដល់អាជ្ញាធរគយនៃភាគីនាំចូល ប្រសិនបើមានការតម្រូវឱ្យដាក់ជូនអាជ្ញាធរគយនៃភាគីនាំចូល។

## សកម្មភាពប្រឆាំងនឹងការក្លែងបន្លំ

## វិធាន ២២

(ក) នៅពេលដែលមានការសង្ស័យថា សកម្មភាពក្លែងបន្លំទាក់ទងនឹងវិញ្ញាបនបត្រដើមកំណើតបានកើតមាន អាជ្ញាធររដ្ឋាភិបាលនៃភាគីទាំងពីរត្រូវសហការគ្នាក្នុងការអនុវត្តសកម្មភាពនៅក្នុងដែនដីនៃភាគីរៀងខ្លួនដើម្បីប្រឆាំងនឹងបុគ្គលជាប់ទាក់ទងនឹងការក្លែងបន្លំនោះ។

(ខ) ភាគីនីមួយៗ ត្រូវទទួលខុសត្រូវក្នុងការដាក់ទណ្ឌកម្មផ្លូវច្បាប់លើការក្លែងបន្លំពាក់ព័ន្ធនឹងវិញ្ញាបនបត្រដើមកំណើតដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងវិធានរដ្ឋបាលក្នុងស្រុករបស់ភាគីនោះ។

## វិធាន ២៣

ក្នុងករណីដែលមានវិវាទពាក់ព័ន្ធនឹងការកំណត់ដើមកំណើត ការចាត់ថ្នាក់ទំនិញ ឬបញ្ហាដទៃទៀត អាជ្ញាធររដ្ឋាភិបាលនៃភាគីទាំងពីរត្រូវពិគ្រោះយោបល់គ្នាដើម្បីដោះស្រាយវិវាទ។

## វិធាន ២៤

ភាគីទាំងពីរត្រូវខិតខំព្យាយាមបង្កើតប្រព័ន្ធដោះដូរទិន្នន័យដើមកំណើតតាមអេឡិចត្រូនិកមុនពេលអនុវត្តកិច្ចព្រមព្រៀងនេះដើម្បីធានាបានពីប្រសិទ្ធិភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តជំពូកនេះក្នុងកម្រិតមួយដែលត្រូវកំណត់រួមគ្នាដោយភាគីទាំងពីរ។

# ជំពូក ៤
# នីតិវិធីគយ និងកិច្ចសម្រួលពាណិជ្ជកម្ម

## មាត្រា ៤.១ និយមន័យ

សម្រាប់គោលបំណងនៃជំពូកនេះ៖

រដ្ឋបាលគយមានន័យថា៖

(ក) សម្រាប់ប្រទេសចិន អគ្គរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិន និង

(ខ) សម្រាប់កម្ពុជា អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

**ច្បាប់គយ** មានន័យថា បទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការនាំចូល ការនាំចេញ ការធ្វើចរាចរឬការផ្ទុកទំនិញ ការគ្រប់គ្រងនិងការអនុវត្តច្បាប់ ដែលត្រូវបានប្រគល់ឱ្យជាពិសេសដល់អាជ្ញាធរគយ និងបទប្បញ្ញត្តិទាំងឡាយណាដែលធ្វើឡើងក្រោមដែនអំណាចច្បាប់គយ។

**នីតិវិធីគយ** មានន័យថា ប្រព្រឹត្តិកម្មដែលត្រូវបានអនុវត្តដោយអាជ្ញាធរគយលើទំនិញ និងមធ្យោបាយដឹកជញ្ជូនដែលស្ថិតនៅក្រោមច្បាប់គយរបស់ភាគីនីមួយៗ

**កិច្ចព្រមព្រៀងស្តីពីការកំណត់តម្លៃគិតពន្ធគយ** មានន័យថា កិច្ចព្រមព្រៀងស្តីពីការអនុវត្តមាត្រា៧ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម (GATT) ឆ្នាំ ១៩៩៤ ដែលមានក្នុងឧបសម្ព័ន្ធ ១ (ក) នៃកិច្ចព្រមព្រៀងអង្គការWTO និង

**មធ្យោបាយដឹកជញ្ជូន** មានន័យថា ប្រភេទផ្សេងៗនៃនាវា យានយន្ត និងអាកាសយាន និងសត្វពាហនៈទាំងឡាយណាដែលចូលទៅឬចេញពីដែនដោយដឹកជញ្ជូនមនុស្ស និង/ឬទំនិញដែលអនុវត្តបានក្រោមច្បាប់និងបទប្បញ្ញត្តិរបស់ភាគីនីមួយៗ។

## មាត្រា ៤.២ វិសាលភាពនិងគោលបំណង

១. ដោយអនុលោមតាមកាតព្វកិច្ចអន្តរជាតិរបស់ភាគីនីមួយៗ និងច្បាប់និងបទប្បញ្ញត្តិរបស់ភាគីនីមួយៗ ជំពូកនេះត្រូវអនុវត្តចំពោះនីតិវិធីគយដែលត្រូវអនុវត្តចំពោះការធ្វើពាណិជ្ជកម្មទំនិញ និងការធ្វើចរាចរនៃមធ្យោបាយដឹកជញ្ជូនរវាងភាគីទាំងពីរ។

២. គោលបំណងនៃជំពូកនេះគឺដើម្បី៖

(ក) ធ្វើសាមញ្ញកម្ម និងធ្វើឱ្យមានសុខដុមនីយកម្មនូវនីតិវិធីគយឱ្យស្របជាមួយនឹងស្តង់ដារអន្តរជាតិពាក់ព័ន្ធ តាមដែលអាចធ្វើទៅបាន

(ខ) ធានានូវភាពអាចព្យាករណ៍បាន សង្គតិភាព និងតម្លាភាពនៃការអនុវត្តច្បាប់និងបទប្បញ្ញត្តិគយរបស់ភាគីទាំងពីរ

(គ) លើកកម្ពស់ការគ្រប់គ្រងនីតិវិធីគយប្រកបដោយប្រសិទ្ធិភាព និងការបញ្ចេញទំនិញពីគយឱ្យបានឆាប់រហ័ស

(ឃ) សម្រួលពាណិជ្ជកម្មរវាងភាគីទាំងពីរ តាមរយៈការបង្កើតបរិយាកាសសម្រាប់ខ្សែច្រវាក់ផ្គត់ផ្គង់សកលនិងក្នុងតំបន់ និង

(ង) ជំរុញកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលគយទាំងពីរ ក្នុងវិសាលភាពនៃជំពូកនេះ។

## មាត្រា ៤.៣ កិច្ចសម្រួល

រដ្ឋបាលគយត្រូវអនុវត្តនីតិវិធីគយដែលមានប្រសិទ្ធិភាព ស្របតាមស្តង់ដារអន្តរជាតិ សំដៅកាត់បន្ថយចំណាយ និងការពន្យារពេលមិនចាំបាច់ក្នុងការធ្វើពាណិជ្ជកម្មរវាងភាគី ជាពិសេសស្តង់ដារនិងការអនុវត្តដែលបានណែនាំនៅក្នុងអនុសញ្ញាអន្តរជាតិរបស់អង្គការគយពិភពលោកស្តីពីការសម្រួលនិងការធ្វើសុខដុមនីយកម្មនីតិវិធីគយ (ដែលបានធ្វើវិសោធនកម្ម) ដែលត្រូវបានគេស្គាល់ថាជាអនុសញ្ញាក្យូតូដែលបានកែសម្រួល។

## មាត្រា ៤.៤ តម្លាភាព

១. រដ្ឋបាលគយនីមួយៗត្រូវបោះផ្សាយភ្លាមៗ រួមទាំងតាមប្រព័ន្ធអ៊ីនធើណែតតាមដែលអាចធ្វើទៅបាននូវច្បាប់ បទប្បញ្ញត្តិ វិធានការរដ្ឋបាល ឬនីតិវិធីនៃការអនុវត្តទូទៅពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មទំនិញរវាងភាគីទាំងពីរ។

២. រដ្ឋបាលគយនីមួយៗត្រូវចាត់តាំងមន្ត្រីទំនាក់ទំនងមួយឬច្រើនរូបដើម្បីឆ្លើយតបសំណួរពីអ្នកដែលមានចំណាប់អារម្មណ៍សាកសួរលើការងារគយ និងត្រូវផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធើណែត អំពីនីតិវិធីសម្រាប់ធ្វើការសាកសួរ។

## មាត្រា ៤.៥ តម្លៃគិតពន្ធគយ

រដ្ឋបាលគយត្រូវកំណត់តម្លៃគិតពន្ធគយនៃទំនិញដែលបានធ្វើពាណិជ្ជកម្មរវាងភាគីទាំងពីរ ដោយអនុលោមតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីការកំណត់តម្លៃគិតពន្ធគយ។

## មាត្រា ៤.៦ ចំណាត់ថ្នាក់ទំនិញ

រដ្ឋបាលគយត្រូវអនុវត្តអនុសញ្ញាអន្តរជាតិស្តីពីការធ្វើឱ្យស៊ីសង្វាក់គ្នានៃការកំណត់មុខទំនិញ និងប្រព័ន្ធលេខកូដសម្រាប់ទំនិញដែលបានធ្វើពាណិជ្ជកម្មរវាងភាគីទាំងពីរ។

## មាត្រា ៤.៧ កិច្ចសហប្រតិបត្តិការគយ

ក្នុងកម្រិតដែលត្រូវបានអនុញ្ញាតដោយច្បាប់និងបទប្បញ្ញត្តិក្នុងស្រុក រដ្ឋបាលគយត្រូវជួយគ្នាទៅវិញទៅមក ពាក់ព័ន្ធនឹង៖

(ក) ការអនុវត្តនិងប្រតិបត្តិការនៃជំពូកនេះ និងអនុស្សរណៈនៃការយោគយល់គ្នារវាងរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិន និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករនៃព្រះរាជាណាចក្រកម្ពុជាស្តីពីកិច្ចសហប្រតិបត្តិការនិងជួយគ្នាទៅវិញទៅមកលើការងារគយ និង

(ខ) បញ្ហាផ្សេងទៀតដែលភាគីទាំងពីរអាចព្រមព្រៀងគ្នា។

## មាត្រា ៤.៨ ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម

១. ក្នុងករណីដែលអាចអនុវត្តបាន រដ្ឋបាលគយនៃភាគីនីមួយៗត្រូវប្រើប្រាស់ប្រព័ន្ធរបស់ខ្លួនដែលគាំទ្រកិច្ចដំណើរការប្រតិបត្តិការគយតាមប្រព័ន្ធអេឡិចត្រូនិក។

២. ក្នុងការអនុវត្តគំនិតផ្តួចផ្តើម ដោយគិតគូរពីហេដ្ឋារចនាសម្ព័ន្ធនិងសមត្ថភាពដែលអាចធ្វើបានរបស់ភាគីនីមួយៗ រដ្ឋបាលគយនៃភាគីនីមួយៗត្រូវគិតគូរពីស្តង់ដារពាក់ព័ន្ធនិងការអនុវត្តល្អៗដែលបានណែនាំដោយអង្គការគយពិភពលោក។

## មាត្រា ៤.៩ វិធានបញ្ជាក់ជាមុន

១. រដ្ឋបាលគយនៃភាគីនីមួយៗត្រូវចេញវិធានបញ្ជាក់ជាមុន មុនពេលការនាំចូលទំនិញមកក្នុងដែនដីរបស់ខ្លួន តាមសំណើជាលាយលក្ខណ៍អក្សរដែលមានព័ត៌មានចាំបាច់ទាំងអស់ លើការដាក់ពាក្យសុំរបស់អ្នកនាំចេញ អ្នកនាំចូលឬបុគ្គលណាដែលមានមូលហេតុត្រឹមត្រូវ ឬអ្នកតំណាងដែលទទួលបានសិទ្ធិ[៥] នូវរាល់ព័ត៌មានដូចខាងក្រោម៖

(ក) ដើមកំណើតទំនិញ

(ខ) ចំណាត់ថ្នាក់ទំនិញ

(គ) វិធីឬលក្ខណៈវិនិច្ឆ័យសមស្រប និងពាក្យស្នើសុំដែលត្រូវបានប្រើប្រាស់សម្រាប់កំណត់តម្លៃគិតពន្ធគយក្រោមសំណុំជាក់លាក់នៃអង្គហេតុ ដោយអនុលោមតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីការកំណត់តម្លៃគិតពន្ធគយ និង

(ឃ) បញ្ហាផ្សេងទៀតតាមការសម្រេចរបស់ភាគីទាំងពីរ។

២. រដ្ឋបាលគយនៃភាគីនាំចូលត្រូវចេញវិធានបញ្ជាក់ជាមុនក្នុងអំឡុងពេលកៅសិប (៩០)ថ្ងៃ ចាប់ពីពេលទទួលបានព័ត៌មានចាំបាច់ទាំងអស់។

៣. រដ្ឋបាលគយនៃភាគីនីមួយៗត្រូវកំណត់សុពលភាពសម្រាប់វិធានបញ្ជាក់ជាមុនបី (៣)ឆ្នាំ គិតចាប់ពីពេលទទួលបានឯកសារចាំបាច់ទាំងអស់។

៤. រដ្ឋបាលគយនៃភាគីនាំចូលអាចកែប្រែឬនិរាករណ៍វិធានបញ្ជាក់ជាមុន៖

(ក) ប្រសិនបើការចេញវិធានបញ្ជាក់ជាមុនបានផ្អែកលើអង្គហេតុមិនត្រឹមត្រូវ

---

[៥] អ្នកដាក់ពាក្យសុំវិធានបញ្ជាក់ជាមុន ពីប្រទេសចិនត្រូវចុះបញ្ជីជាមួយរដ្ឋបាលគយចិន

(ខ) ប្រសិនបើមានការផ្លាស់ប្តូរខ្លឹមសារសំខាន់ៗនៃអង្គហេតុ ឬកាលៈទេសៈសម្រាប់ការចេញវិធានបញ្ជាក់ជាមុនត្រូវបានយកធ្វើជាមូលដ្ឋាន

(គ) ដើម្បីអនុលោមតាមការផ្លាស់ប្តូរច្បាប់ក្នុងស្រុក សេចក្តីសម្រេចរបស់តុលាការ ឬការកែប្រែនៃជំពូកនេះ ឬ

(ឃ) ប្រសិនបើព័ត៌មានមិនត្រឹមត្រូវ ត្រូវបានផ្តល់ឱ្យ ឬព័ត៌មានពាក់ព័ន្ធផ្សេងទៀតមិនត្រូវបានផ្តល់ឱ្យ។

## មាត្រា ៤.១០ ការបញ្ចេញទំនិញ

១. រដ្ឋបាលគយនៃភាគីនីមួយៗ ត្រូវអនុម័តឬរក្សាសាមញ្ញកម្មនីតិវិធីគយ សម្រាប់ការបញ្ចេញទំនិញ ឱ្យមានប្រសិទ្ធភាពដើម្បីសម្រួលពាណិជ្ជកម្មរវាងភាគីទាំងពីរ។ កថាខណ្ឌនេះមិនតម្រូវឱ្យភាគីណាមួយបញ្ចេញទំនិញទេ ប្រសិនបើមិនបានបំពេញតាមលក្ខខណ្ឌតម្រូវនៃការបញ្ចេញទំនិញ។

២. យោងតាមកថាខណ្ឌ ១ ភាគីនីមួយៗត្រូវអនុម័តឬរក្សានីតិវិធីដែលអនុញ្ញាតឱ្យទំនិញត្រូវបានបញ្ចេញពីគយក្នុងអំឡុងពេលមិនលើសពីការកំណត់ ដើម្បីធានាឱ្យមានអនុលោមភាពតាមច្បាប់គយនៃភាគីនីមួយៗ។

៣. ចំពោះទំនិញដែលបានជ្រើសរើសសម្រាប់ការត្រួតពិនិត្យបន្ថែម ការត្រួតពិនិត្យនេះត្រូវធ្វើឡើងចំពោះតែទំនិញដែលមានហេតុផលសមស្រប និងចាំបាច់ ដោយមិនមានការពន្យារពេល។

## មាត្រា ៤.១១ ការគ្រប់គ្រងហានិភ័យ

១. រដ្ឋបាលគយនៃភាគីនីមួយៗ ត្រូវអនុម័តវិធីសាស្ត្រគ្រប់គ្រងហានិភ័យ ក្នុងការកំណត់ទម្រង់ហានិភ័យនៃទំនិញដើម្បីសម្រួលការបញ្ចេញទំនិញដែលមានហានិភ័យទាប ខណៈពេលដែលផ្តោតលើវិធានការត្រួតពិនិត្យទំនិញដែលមានហានិភ័យខ្ពស់។

២. រដ្ឋបាលគយនៃភាគីនីមួយៗ ត្រូវកំណត់ថាបុគ្គល ទំនិញ ឬមធ្យោបាយដឹកជញ្ជូនណាខ្លះដែលត្រូវពិនិត្យ និងទំហំនៃការពិនិត្យនោះ ដោយផ្អែកលើការគ្រប់គ្រងហានិភ័យ។

៣. រដ្ឋបាលគយត្រូវដោះដូរការអនុវត្តល្អលើបច្ចេកទេសគ្រប់គ្រងហានិភ័យ។

## មាត្រា ៤.១២ សវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ

ដើម្បីពង្រឹងការត្រួតពិនិត្យគយ រដ្ឋបាលគយនៃភាគីនីមួយៗ ត្រូវអនុម័តឬរក្សាសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ដើម្បីធានាឱ្យមានអនុលោមភាពតាមច្បាប់គយនៃភាគីនីមួយៗ។

## មាត្រា ៤.១៣ ប្រតិបត្តិករសេដ្ឋកិច្ចដែលទទួលបានការអនុញ្ញាត

១. រដ្ឋបាលគយនៃភាគីនីមួយៗ ត្រូវខិតខំប្រឹងប្រែងអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចដែលទទួលបានការអនុញ្ញាត (តទៅនេះហៅថា "AEO") ដើម្បីលើកកម្ពស់អនុលោមភាពដែលបានជូនដំណឹង និងប្រសិទ្ធិភាពនៃការត្រួតពិនិត្យគយ។

២. រដ្ឋបាលគយនៃភាគីនីមួយៗ ត្រូវខិតខំប្រឹងប្រែងធ្វើកិច្ចការសំដៅឱ្យមានការទទួលស្គាល់គ្នាទៅវិញទៅមករបស់ AEO។

៣. រដ្ឋបាលគយត្រូវបានលើកទឹកចិត្តឱ្យសហការគ្នាតាមដែលអាចធ្វើទៅបាន និងពិចារណា ដើម្បីចាត់តាំងមន្ត្រីគយឱ្យធ្វើជាអ្នកសម្របសម្រួលសម្រាប់ប្រតិបត្តិករសេដ្ឋកិច្ចដែលទទួលបានការអនុញ្ញាតក្នុងការដោះស្រាយបញ្ហាគយ ក៏ដូចជាដើម្បីពង្រឹងអត្ថប្រយោជន៍នៃការអនុវត្តកម្មវិធីនេះ។

## មាត្រា ៤.១៤ ការពិគ្រោះយោបល់និងមន្ត្រីទំនាក់ទំនង

១. រដ្ឋបាលគយនៃភាគីនីមួយៗ អាចស្នើសុំការពិគ្រោះយោបល់ជាមួយរដ្ឋបាលគយនៃភាគីមួយទៀតនៅពេលមានបញ្ហាកើតឡើងពីការអនុវត្តឬប្រតិបត្តិការនៃជំពូកនេះ ក្នុងករណីដែលមានមូលហេតុសមស្រប ឬការពិតដែលផ្តល់ដោយភាគីស្នើសុំ។

២. ក្នុងករណីដែលការពិគ្រោះយោបល់នេះ មិនអាចដោះស្រាយបញ្ហាទាំងនោះបាន ភាគីស្នើសុំអាចបញ្ជូនបញ្ហានេះទៅគណៈកម្មាធិការនីតិវិធីគយនិងកិច្ចសម្រួលពាណិជ្ជកម្ម ដែលមានចែងក្នុងមាត្រា ៤.១៥ សម្រាប់ការពិចារណាបន្ថែម។

៣. សម្រាប់គោលបំណងនៃជំពូកនេះ រដ្ឋបាលគយនៃភាគីនីមួយៗត្រូវចាត់តាំងមន្ត្រីទំនាក់ទំនងមួយឬច្រើនរូប។ ព័ត៌មានរបស់មន្ត្រីទំនាក់ទំនងត្រូវផ្តល់ជូនទៅភាគីមួយទៀត និងរាល់ការកែប្រែព័ត៌មានអំពីមន្ត្រីទំនាក់ទំនង ត្រូវជូនដំណឹងឱ្យបានឆាប់រហ័ស។

## មាត្រា ៤.១៥ គណៈកម្មាធិការស្តីពីនីតិវិធីគយនិងកិច្ចសម្រួលពាណិជ្ជកម្ម

១. ក្នុងគោលបំណងនៃការអនុវត្តនិងប្រតិបត្តិការនៃជំពូកនេះប្រកបដោយប្រសិទ្ធិភាព គណៈកម្មាធិការនីតិវិធីគយនិងកិច្ចសម្រួលពាណិជ្ជកម្ម (តទៅនេះហៅថា "CPTF") ត្រូវបានបង្កើតឡើងក្រោមគណៈកម្មការរួមនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីចិន-កម្ពុជា។

២. មុខងាររបស់គណៈកម្មាធិការ CPTF មានដូចខាងក្រោម៖

(ក) ធានាឱ្យបាននូវមុខងារត្រឹមត្រូវនៃជំពូកនេះ និងដោះស្រាយរាល់បញ្ហាដែលកើតឡើងពីការអនុវត្តនេះ

(ខ) ពិនិត្យមើលលើការបកស្រាយនិងការអនុវត្តជំពូកនេះ

(គ) កំណត់ផ្នែកពាក់ព័ន្ធនៃជំពូកនេះដើម្បីកែលម្អឱ្យប្រសើរឡើង សម្រាប់កិច្ចសម្រួលពាណិជ្ជកម្មរវាងភាគីទាំងពីរ និង

(ឃ) ផ្តល់អនុសាសន៍និងរាយការណ៍ទៅគណៈកម្មការរួម

៣. គណៈកម្មាធិការ CPTF ត្រូវមានមន្ត្រីតំណាងមកពីរដ្ឋបាលគយនៃភាគីទាំងពីរ និងត្រូវជួបប្រជុំគ្នានៅពេលវេលានិងទីកន្លែង ដែលបានព្រមព្រៀងដោយភាគីទាំងពីរ។ មន្ត្រីទំនាក់ទំនងមួយឬច្រើនរូបត្រូវបានចាត់តាំងសម្រាប់គោលបំណងនេះ។

# ជំពូក ៥
# របាំងបច្ចេកទេសលើការធ្វើពាណិជ្ជកម្ម

## មាត្រា ៥.១ គោលបំណង

គោលបំណងរបស់ជំពូកនេះ មានដូចខាងក្រោម ៖

(ក) សម្រួល និងជំរុញពាណិជ្ជកម្មទំនិញរវាងភាគីទាំងពីរ ដោយធានាថាស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃអនុលោមភាព មិនត្រូវបង្កើតជារបាំងបច្ចេកទេសដែលមិនចាំបាច់ចំពោះការធ្វើពាណិជ្ជកម្ម

(ខ) ពង្រឹងកិច្ចសហប្រតិបត្តិការ រួមទាំង ការដោះដូរព័ត៌មានពាក់ព័ន្ធនឹងការរៀបចំ ការអនុម័ត និងការអនុវត្តស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃអនុលោមភាព

(គ) លើកកម្ពស់ការយោគយល់គ្នាទៅវិញទៅមកលើស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃអនុលោមភាពរបស់ភាគីនីមួយៗ និង

(ឃ) សម្រួលដល់ការអនុវត្តគោលការណ៍នានានៃកិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសលើការធ្វើពាណិជ្ជកម្ម (តទៅហៅថា "**កិច្ចព្រមព្រៀងTBT**") នៅក្នុងឧបសម្ព័ន្ធ ១ក នៃកិច្ចព្រមព្រៀងអង្គការWTO។

## មាត្រា ៥.២ វិសាលភាព

ជំពូកនេះត្រូវអនុវត្តលើរាល់ស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃអនុលោមភាពរបស់ភាគីនីមួយៗ ដែលអាចប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលដល់ពាណិជ្ជកម្មទំនិញរវាងភាគីទាំងពីរ។ ជំពូកនេះ លើកលែងចំពោះ៖

(ក) វិធានអនាម័យ និងភូតគាមអនាម័យ ដែលមានចែងក្នុងជំពូក៦ (វិធានការអនាម័យ និងភូតគាមអនាម័យ) និង

(ខ) យថាប្រភេទនៃការបញ្ជាទិញដែលបានរៀបចំដោយអង្គភាពរដ្ឋាភិបាល សម្រាប់តម្រូវការផលិតកម្ម ឬការប្រើប្រាស់ ដែលមិនមែនជាកម្មវត្ថុចំពោះបទប្បញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះ ប៉ុន្តែត្រូវបានចែងក្នុងកិច្ចព្រមព្រៀងស្តីពីលទ្ធកម្មរដ្ឋាភិបាល អាស្រ័យតាមវិសាលភាពរបស់កិច្ចព្រមព្រៀងនោះ។

## មាត្រា ៥.៣ និយមន័យ

សម្រាប់គោលបំណងនៃជំពូកនេះ រាល់និយមន័យដែលមានចែងក្នុងឧបសម្ព័ន្ធ១ នៃកិច្ចព្រមព្រៀង TBT ត្រូវយកមកអនុវត្ត។

## មាត្រា ៥.៤ បទប្បញ្ញត្តិទូទៅ

លើកលែងតែមានចែងក្នុងជំពូកនេះ កិច្ចព្រមព្រៀង TBT ត្រូវអនុវត្តរវាងភាគីទាំងពីរ ហើយត្រូវបានបញ្ចូលក្នុងកិច្ចព្រមព្រៀងនេះ និងបង្កើតជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ *ដោយយកមកអនុវត្តតាមទាំងស្រុង*។

## មាត្រា ៥.៥ ស្តង់ដារអន្តរជាតិ

សម្រាប់គោលបំណងនៃជំពូកនេះ ជាពិសេស ស្តង់ដារដែលមានសុពលភាពចេញដោយអង្គការអន្តរជាតិសម្រាប់ស្តង់ដារូបនីយកម្ម (ISO) គណៈកម្មការអេឡិចត្រូតិចនិកអន្តរជាតិ (IEC) សហភាពទូរគមនាគមន៍អន្តរជាតិ (ITU) និងគណៈកម្មការចំណីអាហារកូដិច (CAC) ត្រូវបានចាត់ទុកជាស្តង់ដារអន្តរជាតិពាក់ព័ន្ធនឹងខ្លឹមសារនៃមាត្រា២.៤ នៃកិច្ចព្រមព្រៀង TBT។

## មាត្រា ៥.៦ នីតិវិធីវាយតម្លៃអនុលោមភាព

១. ដោយឈរលើគោលជំហរក្នុងការបង្កើនស័ក្តសិទ្ធិភាព និងធានាប្រសិទ្ធភាពតម្លៃនៃការវាយតម្លៃអនុលោមភាព ភាគីទាំងពីរត្រូវបង្កើនកិច្ចសហប្រតិបត្តិការក្នុងការដោះដូរព័ត៌មាននៃប្រព័ន្ធវាយតម្លៃអនុលោមភាពទៅវិញទៅមករបស់ភាគីនីមួយៗ តាមរយៈដំណើរទស្សនកិច្ចទ្វេភាគី ការបណ្តុះបណ្តាលបច្ចេកទេស និងសិក្ខាសាលា ជាដើម។

២. នៅពេលធ្វើកិច្ចសហប្រត្តិបត្តិការក្នុងវិស័យវាយតម្លៃអនុលោមភាព ភាគីទាំងពីរត្រូវពិចារណានូវការចូលរួមរបស់ខ្លួននៅក្នុងអង្គការអន្តរជាតិពាក់ព័ន្ធ ។

## មាត្រា ៥.៧ វិធានការ នៅតាមមាត់ច្រក

នៅពេលដែលភាគីមួយឃាត់ទុកទំនិញដែលនាំចេញពីភាគីមួយទៀត នៅតាមច្រកដែលទំនិញចូលមក ដោយហេតុមិនបានបំពេញតាមអនុលោមភាព បទប្បញ្ញត្តិបច្ចេកទេស ឬនីតិវិធីវាយតម្លៃអនុលោមភាព ហេតុផលនៃការឃាត់ទុកនេះ ត្រូវជូនដំណឹងភ្លាមៗទៅអ្នកនាំចូល ឬអ្នកតំណាងដែលទទួលបានសិទ្ធិរបស់អ្នកនាំចូល។ វិធានផ្លូវការដែលដាក់ចេញពាក់ព័ន្ធនឹងទំនិញនោះ ត្រូវសមាមាត្រទៅនឹងហានិភ័យនានារបស់ទំនិញនោះ។

## មាត្រា ៥.៨ តម្លាភាពនិងការដោះដូរព័ត៌មាន

១. ភាគីនីមួយៗអះអាងពីការសន្យារបស់ខ្លួនដើម្បីធានាថាព័ត៌មានពាក់ព័ន្ធនឹងបទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃអនុលោមភាពដែលបានស្នើថ្មី ឬដែលបានធ្វើវិសោធនកម្ម ត្រូវអាចរកបានជាសាធារណៈ ដូចមានចែងក្នុងមាត្រា២.៩ និងមាត្រា៥.៦ នៃកិច្ចព្រមព្រៀង TBT។

២. ភាគីនីមួយៗ ត្រូវធ្វើឱ្យអត្ថបទទាំងស្រុងស្តីពីបទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃ អនុលោមដែលបានជូនដំណឹងរួចរាល់ សម្រាប់ភាគីស្នើសុំអាចរកបានជាសាធារណៈ ក្នុងរយៈពេល១៥ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសំណើជាលាយលក្ខណ៍អក្សរ។ ឯកសារជាភាសាអង់គ្លេស ត្រូវមានតម្លៃជាឯកសារគោលប្រសិនបើអាចរកបាន។

៣. ភាគីនីមួយៗត្រូវទុករយៈពេលយ៉ាងតិច ៦០ថ្ងៃ បន្ទាប់ពីការធ្វើសេចក្តីជូនដំណឹងអំពីបទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃអនុលោមភាពដែលស្នើសុំទៅអង្គការWTO ដើម្បីឱ្យភាគីមួយទៀតធ្វើការផ្តល់យោបល់ លើកលែងករណីហានិភ័យប៉ះពាល់ចំពោះសុខភាព សុវត្ថិភាព និងបរិស្ថានដែលកំពុងកើតឡើង ឬកំពុងគំរាមកំហែងឱ្យកើតឡើង ដែលទាមទារឱ្យមានវិធានការទប់ស្កាត់បន្ទាន់។

៤. ភាគីនីមួយៗអាចស្នើសុំព័ត៌មានពីភាគីមួយទៀត លើបញ្ហាដែលកើតឡើងនៅក្នុងជំពូកនេះ។ ភាគីដែលត្រូវបានស្នើសុំ ត្រូវខិតខំប្រឹងប្រែងផ្តល់ជូនភាគីស្នើសុំ នូវរាល់ព័ត៌មានដែលមានក្នុងរយៈពេលសមស្របណាមួយ។

## មាត្រា ៥.៩ ការប្រឹក្សាបច្ចេកទេស

១. នៅពេលភាគីមួយយល់ថា បទប្បញ្ញត្តិបច្ចេកទេស ឬនីតិវិធីវាយតម្លៃអនុលោមភាពពាក់ព័ន្ធ របស់ភាគីមួយទៀត បង្កើតជាឧបសគ្គមិនចាំបាច់ចំពោះការនាំចេញរបស់ខ្លួន ភាគីនោះអាចស្នើសុំឱ្យមានការប្រឹក្សាបច្ចេកទេស។ ភាគីដែលត្រូវបានស្នើសុំ ត្រូវឆ្លើយតបឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបានចំពោះសំណើនោះ។

២. ភាគីដែលត្រូវបានស្នើសុំត្រូវចូលរួមក្នុងការប្រឹក្សាបច្ចេកទេស ក្នុងថិរវេលាមួយដែលបានព្រមព្រៀងគ្នាដើម្បីរកដំណោះស្រាយមួយ។ ការប្រឹក្សាបច្ចេកទេសអាចត្រូវធ្វើឡើងតាមមធ្យោបាយណាមួយដែលបានព្រមព្រៀងគ្នាដោយភាគីទាំងពីរ។

## មាត្រា ៥.១០ កិច្ចសហប្រតិបត្តិការ

ដើម្បីបង្កើនការយោគយល់គ្នាទៅវិញទៅមកអំពីប្រព័ន្ធរៀងៗខ្លួន និងសម្រួលដល់ពាណិជ្ជកម្មទ្វេភាគី ភាគីទាំងពីរត្រូវពង្រឹងកិច្ចសហប្រតិបត្តិការបច្ចេកទេស ក្នុងវិស័យដូចខាងក្រោម៖

(ក) ការប្រាស័យទាក់ទងរវាងអាជ្ញាធរមានសមត្ថកិច្ចនៃភាគីទាំងពីរ

(ខ) ការដោះដូរព័ត៌មានពាក់ព័ន្ធនឹងស្តង់ដារ បទប្បញ្ញត្តិបច្ចេកទេស នីតិវិធីវាយតម្លៃអនុលោមភាព និងការអនុវត្តនិយតកម្មល្អៗ

(គ) ក្នុងករណីអាចធ្វើទៅបាន ការជំរុញកិច្ចសហប្រតិបត្តិការរវាងស្តង់ដារូបនីយកម្ម និងអង្គភាពវាយតម្លៃអនុលោមភាពរបស់ភាគីទាំងពីរ រួមមាន កម្មវិធីបណ្តុះបណ្តាល សិក្ខាសាលា និងសកម្មភាពពាក់ព័ន្ធនានា

(ឃ) កិច្ចសហប្រតិបត្តិការក្នុងវិស័យនានាដែលបម្រើផលប្រយោជន៍ទៅវិញទៅមកក្នុងក្របខណ្ឌនៃអង្គភាពតំបន់និងអន្តរជាតិពាក់ព័ន្ធលើការអភិវឌ្ឍនិងការអនុវត្តស្តង់ដារ និងនីតិវិធីវាយតម្លៃអនុលោមភាព

(ង) សកម្មភាពពាក់ព័ន្ធនានាក្នុងវាក្យសព្ទទូទៅ បានកំណត់ក្នុងស្តង់ដារ ISO/IEC Guide 2 និង

(ច) វិស័យផ្សេងៗទៀត ដែលបានឯកភាពដោយភាគីទាំងពីរ។

## មាត្រា ៥.១១ មន្ត្រីទំនាក់ទំនង

១. ភាគីនីមួយៗត្រូវចាត់តាំងមន្ត្រីទំនាក់ទំនងរបស់ខ្លួន ដែលត្រូវទទួលខុសត្រូវក្នុងការសម្របសម្រួលការអនុវត្តជំពូកនេះ។ មន្ត្រីទំនាក់ទំនង គឺជា៖
   (ក) សម្រាប់ភាគីចិន រដ្ឋបាលរដ្ឋសម្រាប់និយតកម្មទីផ្សារ និង
   (ខ) សម្រាប់ភាគីកម្ពុជា វិទ្យាស្ថានស្តង់ដារកម្ពុជា។

២. ភាគីនីមួយៗត្រូវជូនដំណឹងដល់ភាគីមួយទៀតនូវព័ត៌មានលម្អិតរបស់មន្ត្រីទំនាក់ទំនង រួមមាន លេខទូរស័ព្ទ ទូរសារ អ៊ីមែលនិងព័ត៌មានលម្អិតផ្សេងទៀត។

៣. ភាគីនីមួយៗត្រូវជូនដំណឹងទៅភាគីមួយទៀតភ្លាមៗនូវការផ្លាស់ប្តូរណាមួយរបស់មន្ត្រីទំនាក់ទំនងរបស់ខ្លួន ឬការកែសម្រួលព័ត៌មានលម្អិតរបស់មន្ត្រីពាក់ព័ន្ធដែលបំពេញមុខងារជា ឬក្នុងនាមតំណាងឱ្យមន្ត្រីទំនាក់ទំនង។

# ជំពូក ៦
# វិធានការអនាម័យ និងភូតគាមអនាម័យ

## មាត្រា ៦.១ គោលបំណង

គោលបំណងនៃជំពូកនេះគឺដើម្បី៖

(ក) សម្រួលពាណិជ្ជកម្មរវាងភាគីទាំងពីរ ទន្ទឹមនឹងការការពារជីវិត ឬសុខភាពមនុស្ស សត្វ ឬរុក្ខជាតិ នៅក្នុងដែនដីរបស់ខ្លួន

(ខ) ធ្វើឱ្យប្រសើរឡើងនូវតម្លាភាព និងការយោគយល់គ្នាទៅវិញទៅមកអំពីការអភិវឌ្ឍនិងការអនុវត្ត វិធានការអនាម័យ និងភូតគាមអនាម័យ ("វិធានការ SPS") របស់ភាគីនីមួយៗ និង

(គ) ពង្រឹងកិច្ចសហប្រតិបត្តិការ ការប្រាស្រ័យទាក់ទងគ្នា និងការពិគ្រោះយោបល់រវាងភាគីទាំងពីរ នៅក្នុងវិស័យវិធានការ SPS។

## មាត្រា ៦.២ និយមន័យ និងវិសាលភាព

សម្រាប់គោលបំណងនៃជំពូកនេះ៖

១. និយមន័យដែលមានចែងនៅក្នុងឧបសម្ព័ន្ធ A នៃកិច្ចព្រមព្រៀងស្តីពីការអនុវត្តវិធានការអនាម័យ និង ភូតគាមអនាម័យនៃអង្គការWTO (តទៅនេះហៅថាកិច្ចព្រមព្រៀងSPS) ត្រូវយកមកអនុវត្ត។

២. និយមន័យពាក់ព័ន្ធដែលកំណត់ដោយគណៈកម្មការ Codex Alimentarius ("Codex") អង្គការសុខភាពសត្វពិភពលោក ("OIE") និងអនុសញ្ញាអន្តរជាតិការពាររុក្ខជាតិ ("IPPC") ត្រូវយកមកគិតគូរពិចារណាផងដែរ។

៣. ជំពូកនេះត្រូវអនុវត្តចំពោះគ្រប់វិធានការ SPS របស់ភាគីទាំងពីរដែលអាចជះឥទ្ធិពលដោយផ្ទាល់ ឬដោយប្រយោលលើពាណិជ្ជកម្មរវាងភាគីទាំងពីរ ។

## មាត្រា ៦.៣ បទប្បញ្ញត្តិទូទៅ

១. ភាគីនីមួយៗអះអាងអំពីសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនចំពោះគ្នាទៅវិញទៅមក ដូចមានចែងក្នុង កិច្ចព្រមព្រៀង SPS ។

២. ភាគីទាំងពីរសន្យាអនុវត្តគោលការណ៍នៃកិច្ចព្រមព្រៀង SPS ក្នុងការអភិវឌ្ឍនិងការអនុវត្តវិធានការ SPS។

## មាត្រា ៦.៤ សុខដុមនីយកម្ម

ដើម្បីធ្វើឱ្យមានសុខដុមនីយកម្មវិធានការ SPS ឱ្យបានទូលំទូលាយតាមដែលអាចធ្វើទៅបាន ភាគីទាំងពីរត្រូវខិតខំធ្វើឱ្យបានល្អបំផុត ក្នុងការយកស្តង់ដារអន្តរជាតិ គោលការណ៍ណែនាំ ឬអនុសាសន៍នានាដែលដាក់ចេញដោយ Codex, OIE និង IPPC មកធ្វើជាមូលដ្ឋានបង្អែកនៃវិធានការ SPS របស់ខ្លួន។

### មាត្រា ៦.៥ សមមូលភាព

១. ភាគីទាំងពីរត្រូវពង្រឹងកិច្ចសហប្រតិបត្តិការលើសមមូលភាព ដោយអនុលោមតាមកិច្ចព្រមព្រៀង SPS ដោយពិចារណាលើសេចក្តីសម្រេចដែលពាក់ព័ន្ធនានារបស់គណៈកម្មការ SPS នៃអង្គការ WTO និង ស្តង់ដារ គោលការណ៍ណែនាំ និងអនុសាសន៍អន្តរជាតិ។

២. តាមការស្នើសុំ ភាគីទាំងពីរត្រូវខិតខំប្រឹងប្រែងចូលរួមកិច្ចពិគ្រោះយោបល់ ក្នុងគោលបំណងដើម្បី សម្រេចឱ្យបាននូវកិច្ចរៀបចំទទួលស្គាល់គ្នាទៅវិញទៅមកអំពីសមមូលភាពនៃវិធានការ SPS ដែលបាន កំណត់។

### មាត្រា ៦.៦ តំបន់នីយកម្ម

ភាគីទាំងពីរឯកភាពអនុវត្តគោលការណ៍តំបន់នីយកម្ម ដូចមានចែងក្នុងមាត្រា៦ នៃកិច្ចព្រមព្រៀង វិធានការ SPS នៃអង្គការ WTO ក្នុងការបង្កើត និងការអនុវត្តវិធានការ SPS របស់ខ្លួន ដោយយកចិត្ត ទុកដាក់លើគោលការណ៍ណែនាំដើម្បីបន្តការអនុវត្តលើមាត្រា៦ នៃកិច្ចព្រមព្រៀងវិធានការ SPS ដែលបាន អនុម័តដោយគណៈកម្មការ SPS នៃអង្គការ WTO ព្រមទាំងស្តង់ដារ និងគោលការណ៍ណែនាំអន្តរជាតិ។

### មាត្រា ៦.៧ តម្លាភាពនិងការដោះដូរព័ត៌មាន

១. ភាគីទាំងពីរទទួលស្គាល់សារៈសំខាន់នៃតម្លាភាពដែលមានចែងនៅក្នុងឧបសម្ព័ន្ធ B នៃកិច្ចព្រមព្រៀង វិធានការ SPS នៃអង្គការ WTO។

២. ភាគីនីមួយៗត្រូវជូនដំណឹងគ្នាទៅវិញទៅមកអំពីវិធានការថ្មីដែលស្នើឡើង ឬការផ្លាស់ប្តូរនានាចំពោះ វិធានការ SPS ដែលកំពុងមានជាធរមាន ដែលអាចជះឥទ្ធិពលខ្លាំងដល់ការធ្វើពាណិជ្ជកម្មរបស់ភាគី មួយទៀត តាមរយៈអង្គភាពផ្តល់ព័ត៌មាន និងមន្ត្រីទំនាក់ទំនងរបស់ WTO/SPS ដូចបានបង្កើតឡើង ក្នុងមាត្រា ៦.១០ នៃជំពូកនេះ។ ភាគីនីមួយៗត្រូវផ្តល់រយៈពេលយ៉ាងតិច ៦០ថ្ងៃ ឱ្យភាគីមួយទៀត ដើម្បីផ្តល់យោបល់លើការជូនដំណឹងនានា លើកលែងតែមានបញ្ហាជាបន្ទាន់លើការការពារសុខភាព ឬ ការគំរាមកំហែងណាមួយដែលអាចនឹងកើតមានឡើង។

៣. ភាគីនីមួយៗត្រូវផ្តល់អត្ថបទទាំងស្រុងនៃការជូនដំណឹងពីវិធានការ SPS ជាភាសាអង់គ្លេសទៅឱ្យភាគី មួយទៀតក្នុងរយៈពេល ៥ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសំណើជាលាយលក្ខណ៍អក្សរ។

៤. ភាគីនីមួយៗត្រូវដោះដូរព័ត៌មានទាក់ទងនឹងស្ថានភាពអនាម័យនិងភូតគាមអនាម័យនៅក្នុងដែនដី របស់ខ្លួន ហើយត្រូវផ្តល់ព័ត៌មានចាំបាច់ដើម្បីដំណើរការវាយតម្លៃហានិភ័យ និងសមមូលភាព។

៥. ភាគីទាំងពីរត្រូវប្រាស្រ័យទាក់ទងគ្នាឱ្យបានទាន់ពេលវេលាអំពីភាពមិនអនុលោមតាមលក្ខខណ្ឌតម្រូវ អនាម័យ និងភូតគាមអនាម័យ នៃការនាំចូលទំនិញ។

### មាត្រា ៦.៨ វិធានការនៅច្រកនាំចូល

នៅពេលដែលភាគីមួយបានឃាត់ទំនិញនាំចេញពីភាគីមួយទៀតនៅច្រកនាំចូល ដោយហេតុទំនិញ នោះមិនមានអនុលោមភាពតាមលក្ខខណ្ឌតម្រូវអនាម័យឬភូតគាមអនាម័យ មូលហេតុនៃការឃាត់ទុកនេះ ត្រូវជូនដំណឹងភ្លាមៗដល់អ្នកនាំចូលឬតំណាងរបស់ខ្លួន។

## មាត្រា ៦.៩ កិច្ចសហប្រតិបត្តិការ

ភាគីទាំងពីរឯកភាពក្នុងការស្វែងរកកាលានុវត្តភាពលើកិច្ចសហប្រតិបត្តិការជាមួយគ្នាលើរាល់បញ្ហាអនាម័យ និងភូតគាមអនាម័យ ដើម្បីពង្រឹងការយោគយល់គ្នាទៅវិញទៅមកនៃប្រព័ន្ធនិយតកម្មរបស់ភាគីទាំងពីរ និងសម្រួលពាណិជ្ជកម្មទ្វេភាគី។

## មាត្រា ៦.១០ អាជ្ញាធរមានសមត្ថកិច្ច និងមន្ត្រីទំនាក់ទំនង

១. អាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីទាំងពីរ គឺជាអាជ្ញាធរដែលទទួលខុសត្រូវក្នុងការអនុវត្តជំពូកនេះ។ មន្ត្រីទំនាក់ទំនងរបស់ភាគីទាំងពីរ គឺជាភ្នាក់ងារដែលទទួលខុសត្រូវក្នុងការទំនាក់ទំនង និងជូនដំណឹងរវាងភាគីទាំងពីរអំពីបញ្ហាពាក់ព័ន្ធនានារបស់ជំពូកនេះ។

២. ភាគីនីមួយៗត្រូវចាត់តាំងមន្ត្រីទំនាក់ទំនងដែលទទួលខុសត្រូវក្នុងការសម្របសម្រួលការអនុវត្តជំពូកនេះ។ មន្ត្រីទំនាក់ទំនងគឺជា៖

(ក) សម្រាប់ភាគីចិន គឺអគ្គរដ្ឋបាលគយ និង

(ខ) សម្រាប់ភាគីកម្ពុជា គឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៣. ភាគីទាំងពីរត្រូវជូនដំណឹងគ្នាទៅវិញទៅមកអំពីការផ្លាស់ប្តូរសំខាន់ៗក្នុងរចនាសម្ព័ន្ធ អង្គភាព និងការប្រគល់ភារកិច្ចទទួលខុសត្រូវនៅក្នុងអាជ្ញាធរមានសមត្ថកិច្ច ឬការផ្លាស់ប្តូរមន្ត្រីទំនាក់ទំនងរបស់ខ្លួន។

## មាត្រា ៦.១១ គណៈកម្មាធិការអនាម័យនិងភូតគាមអនាម័យ

១. ភាគីទាំងពីរឯកភាពបង្កើតគណៈកម្មាធិការអនាម័យនិងភូតគាមអនាម័យ ដែលមានសមាសភាពតំណាងរបស់ភាគីនីមួយៗទទួលខុសត្រូវលើវិធានការអនាម័យនិងភូតគាមអនាម័យ។ គណៈកម្មាធិការត្រូវសម្របសម្រួលដោយ៖

(ក) ករណីភាគីចិន អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចសហប្រតិបត្តិការអន្តរជាតិនៃ GACC ឬអ្នកដែលត្រូវបានចាត់តាំង និង

(ខ) ករណីភាគីកម្ពុជា ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬអ្នកដែលត្រូវបានចាត់តាំង។

២. គណៈកម្មាធិការនេះត្រូវជួបប្រជុំក្នុងរយៈពេលមួយឆ្នាំ ចាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ និងជួបប្រជុំជាបន្តបន្ទាប់ នៅពេលវេលា និងទីកន្លែងដែលកំណត់រួមដោយភាគីទាំងពីរ។

៣. មុខងាររបស់គណៈកម្មាធិការនេះ គឺដើម្បី៖

(ក) បង្កើនការយោគយល់គ្នាទៅវិញទៅមកអំពីវិធានការអនាម័យនិងអនាម័យ និងដំណើរការនិយតកម្មពាក់ព័ន្ធនឹងវិធានការទាំងនោះ

(ខ) សម្រួលដល់កិច្ចសហប្រតិបត្តិការបច្ចេកទេសលើវិធានការអនាម័យនិងភូតគាមអនាម័យ និង

(គ) ត្រួតពិនិត្យការអនុវត្តនិងប្រតិបត្តិការនៃជំពូកនេះ។

៤. គណៈកម្មាធិការនេះ អាចឯកភាពបង្កើតក្រុមការងារបច្ចេកទេសពិសេស ដោយអនុលោមតាមលក្ខខណ្ឌប្រតិបត្តិរបស់គណៈកម្មាធិការ។

៥. កិច្ចប្រជុំអាចប្រព្រឹត្តឡើងដោយជួបគ្នាផ្ទាល់ តាមទូរគមនាគមន៍ តាមរយៈសន្និសីទវីដេអូ ឬតាមរយៈមធ្យោបាយផ្សេងទៀតដែលបានឯកភាពដោយភាគីទាំងពីរ។

# ជំពូក ៧
# ពាណិជ្ជកម្មសេវាកម្ម

## មាត្រា ៧.១ និយមន័យ

សម្រាប់គោលបំណងនៃជំពូកនេះ៖

**វត្តមានពាណិជ្ជកម្ម** មានន័យថាជាប្រភេទធុរកិច្ច ឬការបង្កើតវិជ្ជាជីវៈណាមួយ រួមទាំងតាមរយៈ៖

(ក) ការបង្កើត ការទិញ ការរក្សាទុករបស់នីតិបុគ្គល ឬ

(ខ) ការបង្កើត ឬការរក្សាទុកនៃសាខា ឬការិយាល័យតំណាង នៅក្នុងដែនដីរបស់ភាគីមួយក្នុងគោលបំណងផ្គត់ផ្គង់សេវាកម្ម។

**នីតិបុគ្គល** គឺ៖

(i) «**ត្រូវបានកាន់កាប់កម្មសិទ្ធិ**» ដោយបុគ្គលនៃភាគីមួយ ប្រសិនបើច្រើនជាង៥០ភាគរយនៃដើមទុនគឺ ត្រូវបានកាន់កាប់ផលប្រយោជន៍ដោយបុគ្គលរបស់ភាគីនោះ។

(ii) «**ត្រូវបានគ្រប់គ្រង**» ដោយបុគ្គលនៃភាគីមួយ ប្រសិនបើបុគ្គលនោះមានសិទ្ធិអំណាចតែងតាំងសមាសភាពភាគច្រើននៃនាយកគ្រប់គ្រង ឬបើពុំនោះទេ មានសិទ្ធិដឹកនាំតាមផ្លូវច្បាប់។

(iii) «**ត្រូវបានចងសម្ព័ន្ធ**» ជាមួយបុគ្គលណាមួយផ្សេងទៀត នៅពេលដែលនីតិបុគ្គលនោះគ្រប់គ្រង ឬត្រូវ បានគ្រប់គ្រងដោយបុគ្គលណាមួយផ្សេងទៀតនោះ ឬនៅពេលដែលទាំងនីតិបុគ្គលនិងបុគ្គលផ្សេងទៀតនោះ ត្រូវបានគ្រប់គ្រងដោយបុគ្គលតែមួយ។

**នីតិបុគ្គលនៃភាគីមួយ** មានន័យថា ស្ថាប័នស្របច្បាប់ណាមួយ ដែលត្រូវបានបង្កើតឡើងត្រឹមត្រូវតាមច្បាប់ ឬ ត្រូវបានរៀបចំឡើងក្រោមច្បាប់ជាធរមានរបស់ភាគីមួយ ទោះបីជានីតិបុគ្គលនោះមានគោលដៅស្វែងរកប្រាក់ចំណេញ ឬដើម្បីគោលបំណងផ្សេងទៀត និងទោះបីជានីតិបុគ្គលនោះត្រូវបានកាន់កាប់ជាកម្មសិទ្ធិឯកជន ឬជាកម្មសិទ្ធិ របស់រដ្ឋាភិបាលក្តី ដែលរួមមាន ក្រុមហ៊ុនសាជីវកម្ម ក្រុមហ៊ុនបរធនបាលកិច្ច ក្រុមហ៊ុនសហកម្មសិទ្ធិ សហព័ន្ធជីវកម្ម ក្រុមហ៊ុនឯកកម្មសិទ្ធិ ឬសមាគម ដែលស្ថិតក្រោមលក្ខខណ្ឌណាមួយដូចខាងក្រោម៖

(ក) ត្រូវបានបង្កើត ឬ ត្រូវបានរៀបចំឡើងក្រោមច្បាប់របស់ភាគីនោះ ហើយបានចូលរួម នៅក្នុងប្រតិបត្តិការធុរកិច្ចជាដុំកំភួន នៅក្នុងដែនដីរបស់ភាគីនោះ ឬ

(ខ) ក្នុងករណីការផ្គត់ផ្គង់សេវាកម្មតាមរយៈវត្តមានពាណិជ្ជកម្ម ត្រូវបានកាន់កាប់កម្មសិទ្ធិ ឬគ្រប់គ្រងដោយ៖

(i) រូបវន្តបុគ្គលរបស់ភាគីនោះ ឬ

(ii) នីតិបុគ្គលនៃភាគីនោះ ដូចដែលមានចែងក្នុងវាក្យខណ្ឌ(ក)។

**វិធានការ** មានន័យថា វិធានការទាំងឡាយណា របស់ភាគីមួយ ទាំងក្នុងទម្រង់ជាច្បាប់ បទប្បញ្ញត្តិ វិធាន នីតិវិធី សេចក្តីសម្រេច បែបបទរដ្ឋបាល ឬក្នុងទម្រង់ផ្សេងទៀត ដែលត្រូវបានដាក់ឱ្យអនុវត្តដោយៈ

(ក) រដ្ឋាភិបាលនិងអាជ្ញាធរថ្នាក់កណ្តាល ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន និង

(ខ) អង្គភាពក្រៅរដ្ឋាភិបាលដែលអនុវត្តសិទ្ធិអំណាចបានពីប្រតិភូកម្មពីរដ្ឋាភិបាលនិងអាជ្ញាធរថ្នាក់កណ្តាល ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន។

**វិធានការនានាដែលធ្វើឡើង ដោយភាគីទាំងពីរ ដែលជះឥទ្ធិពលលើពាណិជ្ជកម្មសេវាកម្ម** រួមមានវិធានការទាំងឡាយពាក់ព័ន្ធនឹងៈ

(ក) ការទិញ ការទូរទាត់ ឬការប្រើប្រាស់សេវាកម្មណាមួយ។

(ខ) ទាក់ទងនឹងការផ្តត់ផ្គង់សេវាកម្មណាមួយ ការទទួលបាន និងការប្រើប្រាស់សេវាកម្មទាំងឡាយដែល ត្រូវបានកំណត់ដោយភាគីដើម្បីឱ្យមានការផ្គត់ផ្គង់ទូទៅដល់សាធារណជន។

(គ) ដោយរាប់បញ្ចូលទាំងវត្តមានពាណិជ្ជកម្ម វត្តមានរបស់បុគ្គលនៃភាគីមួយសម្រាប់ការផ្គត់ផ្គង់សេវាកម្មនៅក្នុងដែនដីរបស់ភាគីមួយផ្សេងទៀត។

**អ្នកផ្គត់ផ្គង់សេវាកម្មផ្តាច់មុខ** មានន័យថាបុគ្គលណាមួយ ជាសាធារណៈឬឯកជន ដែលពាក់ព័ន្ធនឹងទីផ្សារក្នុងដែនដីរបស់ភាគីមួយ ត្រូវបានផ្តល់សិទ្ធិឱ្យ ឬត្រូវបានបង្កើតឡើងជាផ្លូវការ ឬតាមច្បាប់ជាធរមាន ដោយភាគីនោះ ថាជាអ្នកផ្គត់ផ្គង់សេវាកម្មនោះផ្តាច់មុខ។

**រូបវន្តបុគ្គលនៃភាគីមួយ** មានន័យថាៈ

(ក) ចំពោះភាគីចិន រូបវន្តបុគ្គលដែលស្ថិតក្រោមច្បាប់ប្រទេសចិន គឺជាជនជាតិចិន

(ខ) ចំពោះភាគីកម្ពុជា រូបវន្តបុគ្គលដែលស្ថិតក្រោមច្បាប់ប្រទេសកម្ពុជា គឺជាជនជាតិកម្ពុជា។

**បុគ្គលនៃភាគីមួយ** មានន័យថាជារូបវន្តបុគ្គលឬនីតិបុគ្គលនៃភាគីមួយ។

**សេវាកម្ម** សំដៅលើសេវាកម្មណាមួយនៅក្នុងវិស័យណាមួយ លើកលែងតែសេវាកម្មដែលបានផ្គត់ផ្គង់ដោយប្រើប្រាស់សិទ្ធិអំណាចផ្តល់ដោយរដ្ឋាភិបាល។

**វិស័យសេវាកម្ម** មានន័យថាៈ

(ក) ដោយអនុលោមតាមតារាងសន្យាតាមវិស័យ អនុវិស័យសេវាកម្មមួយឬច្រើន ឬទាំងអស់ ដូចមានចែងនៅក្នុងតារាងសន្យាតាមវិស័យរបស់ភាគីនោះ ។

(ខ) ឬ វិស័យសេវាកម្មទាំងអស់ រួមទាំងអនុវិស័យទាំងអស់របស់វា។

**អ្នកប្រើប្រាស់សេវាកម្ម** មានន័យថាបុគ្គលដែលទទួល ឬប្រើប្រាស់សេវាកម្មណាមួយ។

**សេវាកម្មផ្គត់ផ្គង់ដោយប្រើប្រាស់សិទ្ធិអំណាចផ្តល់ដោយរដ្ឋាភិបាល** មានន័យថា ជាសេវាកម្មណាមួយដែលត្រូវបានផ្គត់ផ្គង់ដោយមិនឈរលើមូលដ្ឋានពាណិជ្ជកម្ម ឬដោយគ្មានការប្រកួតប្រជែងជាមួយនឹងអ្នកផ្គត់ផ្គង់សេវាកម្មមួយឬច្រើន។

**អ្នកផ្គត់ផ្គង់សេវាកម្ម** មានន័យថា ជាបុគ្គលណាមួយនៃភាគី ដែលផ្គត់ផ្គង់សេវាកម្ម[១០]។

**ការផ្គត់ផ្គង់សេវាកម្ម** រួមបញ្ចូលទាំងការផលិត ការចែកចាយ ការធ្វើទីផ្សារ ការលក់ និងការផ្តល់សេវាកម្ម។

**ពាណិជ្ជកម្មសេវាកម្ម** ត្រូវបានកំណត់និយមន័យថាជាការផ្គត់ផ្គង់សេវាកម្ម៖

(ក) ចេញពីដែនដីរបស់ភាគីមួយ ទៅក្នុងដែនដីរបស់ភាគីមួយទៀត (ម៉ូតនៃការផ្គត់ផ្គង់ឆ្លងកាត់ព្រំដែន)

(ខ) នៅក្នុងដែនដីរបស់ភាគីមួយ ទៅកាន់អ្នកប្រើប្រាស់សេវាកម្មរបស់ភាគីមួយទៀត (ម៉ូតនៃការប្រើប្រាស់នៅបរទេស)

(គ) ដោយអ្នកផ្គត់ផ្គង់សេវាកម្មរបស់ភាគីមួយ តាមរយៈវត្តមានពាណិជ្ជកម្ម នៅក្នុងដែនដីរបស់ភាគីមួយទៀត (ម៉ូតនៃវត្តមានពាណិជ្ជកម្ម)

(ឃ) ដោយអ្នកផ្គត់ផ្គង់សេវាកម្មរបស់ភាគីមួយ តាមរយៈវត្តមានរូបវន្តបុគ្គលរបស់ភាគីមួយ នៅក្នុងដែនដីរបស់ភាគីមួយទៀត (ម៉ូតនៃវត្តមានរូបវន្តបុគ្គល)។

## មាត្រា ៧.២ វិសាលភាព

១. ជំពូកនេះត្រូវអនុវត្តចំពោះ វិធានការទាំងឡាយណាដែលត្រូវបានអនុម័ត ឬរក្សាទុកដោយភាគីមួយដែលជះឥទ្ធិពលលើពាណិជ្ជកម្មសេវាកម្ម។

២. ជំពូកនេះមិនត្រូវបានអនុវត្តចំពោះ៖

(ក) ច្បាប់ បទប្បញ្ញត្តិ គោលនយោបាយ ឬនីតិវិធីដែលកំណត់ការអនុវត្តទូទៅគ្រប់គ្រងលើលទ្ធកម្មដោយភ្នាក់ងាររដ្ឋាភិបាលទាក់ទងនឹងសេវាកម្មទិញក្នុងគោលបំណងរបស់រដ្ឋាភិបាល ហើយមិនមែនក្នុងគោលបំណងដើម្បីជួញដូរបន្ត ឬក្នុងបំណងប្រើប្រាស់ដើម្បីផ្គត់ផ្គង់សេវាកម្មសម្រាប់ការជួញដូរ។

(ខ) សេវាកម្មផ្គត់ផ្គង់ដោយប្រើប្រាស់សិទ្ធិអំណាចផ្តល់ដោយរដ្ឋាភិបាល

(គ) ឧបត្ថម្ភធន ឬជំនួយផ្តល់ដោយភាគីមួយ

---

[១០] ក្នុងករណីដែលសេវាកម្មមិនត្រូវបានផ្គត់ផ្គង់ផ្ទាល់ដោយនីតិបុគ្គលណាមួយនៃភាគី ប៉ុន្តែផ្គត់ផ្គង់តាមទម្រង់ផ្សេងៗនៃវត្តមានពាណិជ្ជកម្ម ដូចជាសាខា ឬការិយាល័យតំណាង ផ្ទុយមកវិញតាមរយៈវត្តមានពាណិជ្ជកម្ម នោះអ្នកផ្គត់ផ្គង់សេវាកម្ម (ឧទាហរណ៍ នីតិបុគ្គល) តាមទម្រង់វត្តមានពាណិជ្ជកម្មបែបនោះត្រូវទទួលបានប្រព្រឹត្តិកម្មដែលផ្តល់សម្រាប់អ្នកផ្គត់ផ្គង់សេវាកម្មនៅក្រោមជំពូកនេះ។ ប្រព្រឹត្តិកម្មនេះត្រូវផ្តល់ឱ្យតែវត្តមានពាណិជ្ជកម្មដែលសេវាកម្មត្រូវបានផ្គត់ផ្គង់ប៉ុណ្ណោះ និងមិនចាំបាច់ផ្តល់ដល់ផ្នែកផ្សេងទៀតរបស់អ្នកផ្គត់ផ្គង់នោះដែលមាននិវេសនដ្ឋានក្រៅដែនដីដែលសេវាកម្ម នោះត្រូវបានផ្គត់ផ្គង់។

(ឃ) រាល់វិធានការដែលជះឥទ្ធិពលលើរូបវន្តបុគ្គលដែលព្យាយាមចូលទៅកាន់ទីផ្សារការងាររបស់ភាគីមួយ

(ង) តីរនាវាចរណ៍នៅក្នុងសេវាដឹកជញ្ជូនតាមផ្លូវសមុទ្រ។

៣. ជំពូកនេះមិនត្រូវអនុវត្តចំពោះវិធានការទាំងឡាយណាដែលជះឥទ្ធិពលលើៈ

(ក) សិទ្ធិធ្វើចរាចរផ្លូវអាកាស បើទោះបីជាមានការអនុញ្ញាតក៏ដោយ ឬ

(ខ) សេវាកម្មទាំងឡាយណាដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការអនុវត្តសិទ្ធិធ្វើចរាចរផ្លូវអាកាស លើកលែងតែវិធានការ ដែលជះឥទ្ធិពលលើៈ

(i) សេវាកម្មជួសជុល និងថែទាំអាកាសយាន

(ii) ការលក់ និងការធ្វើទីផ្សាររបស់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស

(iii) សេវាកម្មបម្រុងទុក តាមប្រព័ន្ធកុំព្យូទ័រ ("CRS") ។

## មាត្រា ៧.៣ ប្រព្រឹត្តិកម្មជាតិ

១. ចំពោះវិស័យសេវាកម្មទាំងឡាយដែលបានចែងក្នុងតារាងសន្យាតាមវិស័យរបស់ខ្លួន ដោយអាស្រ័យទៅតាមលក្ខខណ្ឌនិងគុណវុឌ្ឍិដែលបានចែងក្នុងនោះ ដោយគោរពតាមវិធានការទាំងឡាយដែលជះឥទ្ធិពលលើការផ្គត់ផ្គង់សេវាកម្ម ភាគីនីមួយៗត្រូវផ្តល់ទៅឱ្យសេវាកម្ម និងអ្នកផ្គត់ផ្គង់សេវាកម្មនៃភាគីផ្សេងទៀតនូវប្រព្រឹត្តិកម្មមិនឱ្យតិចជាងភាពអនុគ្រោះដែលខ្លួនបានផ្តល់ទៅឱ្យសេវាកម្មនិងអ្នកផ្គត់ផ្គង់សេវាកម្មដូចគ្នារបស់ជាតិខ្លួនឡើយ[១១]។

២. ភាគីមួយអាចបំពេញតាមលក្ខខណ្ឌតម្រូវនៃកថាខណ្ឌ ១ ដោយផ្តល់ទៅឱ្យសេវាកម្មនិងអ្នកផ្គត់ផ្គង់សេវាកម្មនៃភាគីផ្សេងទៀត ទាំងទ្រង់ទ្រាយប្រព្រឹត្តិកម្មដូចគ្នា ឬក៏ខុសគ្នាទៅនឹងប្រព្រឹត្តិកម្មដែលខ្លួនបានផ្តល់សេវាកម្មនិងអ្នកផ្គត់ផ្គង់សេវាកម្មដូចគ្នារបស់ជាតិខ្លួន។

៣. ប្រព្រឹត្តិកម្មដូចគ្នាឬក៏ខុសគ្នាជាផ្លូវការណាមួយត្រូវចាត់ទុកថាមានភាពអនុគ្រោះតិចជាង ប្រសិនបើប្រព្រឹត្តិកម្មនោះបានកែប្រែលក្ខខណ្ឌប្រកួតប្រជែងជាគុណប្រយោជន៍ដល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់សេវាកម្មនានារបស់ភាគីមួយ ធៀបនឹងសេវាកម្មឬអ្នកផ្គត់ផ្គង់សេវាកម្មដូចគ្នានៃភាគីមួយផ្សេងទៀត។

## មាត្រា ៧.៤ ការបើកទីផ្សារ

១. ចំពោះការបើកទីផ្សារតាមម៉ូដនៃការផ្គត់ផ្គង់សេវាកម្មដែលបានកំណត់ក្នុងនិយមន័យនៃពាណិជ្ជកម្មសេវាកម្ម ដែលមានក្នុងមាត្រា៧.១ (និយមន័យ) ភាគីមួយត្រូវផ្តល់ឱ្យសេវាកម្មនិងអ្នកផ្គត់ផ្គង់សេវាកម្មរបស់ភាគីផ្សេងទៀតនូវប្រព្រឹត្តិកម្មដែលមានភាពអនុគ្រោះមិនតិចជាងអ្វីដែលត្រូវបានផ្តល់ឱ្យនៅ

---

[១១] ការសន្យាតាមវិស័យដែលសន្មតនៅក្រោមមាត្រានេះ មិនត្រូវបានបកស្រាយ ដើម្បីទាមទារឱ្យភាគីណាមួយទូទាត់សំណងចំពោះការបាត់បង់ផលប្រយោជន៍ប្រកួតប្រជែងណាមួយដែលមានស្រាប់បណ្តាលមកពីចរិតលក្ខណៈនៃសេវាកម្ម ឬអ្នកផ្គត់ផ្គង់សេវាកម្មពាក់ព័ន្ធរបស់បរទេសនោះទេ។

ក្រោមលក្ខខណ្ឌកំណត់ ការរឹតត្បិត និងលក្ខខណ្ឌនានាដែលបានព្រមព្រៀងគ្នា និងដែលបានចែងនៅក្នុងតារាងសន្យាតាមវិស័យរបស់ខ្លួន[១២]។

២. ក្នុងវិស័យសេវាកម្មទាំងឡាយណាដែលការសន្យាលើការបើកទីផ្សារត្រូវបានអនុវត្ត នោះវិធានការនានាដែលភាគីមួយមិនត្រូវរក្សាទុក ឬមិនត្រូវអនុម័ត បើទោះជាក្នុងមូលដ្ឋាននៃដែនដីតំបន់ណាមួយ ឬក្នុងមូលដ្ឋាននៃដែនដីទាំងមូលរបស់ខ្លួនក្តី លើកលែងតែបានចែងក្នុងតារាងសន្យាតាមវិស័យរបស់ខ្លួនគឺត្រូវបានកំណត់ដូចខាងក្រោម៖

(ក) ការរឹតត្បិតលើចំនួនអ្នកផ្គត់ផ្គង់សេវាកម្មក្នុងទម្រង់ជាចំនួនកូតា ការផ្តាច់មុខ អ្នកផ្គត់ផ្គង់សេវាកម្មផ្តាច់មុខ(ដែលមានឯកសិទ្ធិពិសេស) ឬគុណវុឌ្ឍិនៃការសាកល្បងតម្រូវការសេដ្ឋកិច្ច

(ខ) ការរឹតត្បិតលើតម្លៃសរុបនៃប្រតិបត្តិការសេវាកម្ម ឬលើទ្រព្យសកម្មក្នុងទម្រង់ជាចំនួនកូតា ឬគុណវុឌ្ឍិនៃការសាកល្បងតម្រូវការសេដ្ឋកិច្ច

(គ) ការរឹតត្បិតលើចំនួនសរុបនៃប្រតិបត្តិការសេវាកម្ម ឬលើបរិមាណសរុបនៃទិន្នផលសេវាកម្មគិតជាឯកតាលេខ ក្នុងទម្រង់ជាចំនួនកូតា ឬគុណវុឌ្ឍិនៃការសាកល្បងតម្រូវការសេដ្ឋកិច្ច[១៣]

(ឃ) ការរឹតត្បិតលើចំនួនសរុបនៃរូបវ័ន្តបុគ្គលដែលអាចនឹងត្រូវបានជួលមកធ្វើការក្នុងវិស័យសេវាកម្មជាក់លាក់ណាមួយ ឬការរឹតត្បិតដែលអ្នកផ្គត់ផ្គង់សេវាកម្មអាចនឹងជួល មកធ្វើការ ហើយជាបុគ្គលណាដែលចាំបាច់សម្រាប់ និងពាក់ព័ន្ធផ្ទាល់ទៅនឹងការផ្គត់ផ្គង់សេវាកម្មជាក់លាក់ណាមួយក្នុងទម្រង់ជាចំនួនកូតា ឬគុណវុឌ្ឍិនៃការសាកល្បងតម្រូវការសេដ្ឋកិច្ច

(ង) វិធានការទាំងឡាយដែលរឹតត្បិត ឬតម្រូវឱ្យមានប្រភេទជាក់លាក់នៃនីតិបុគ្គល ឬក្រុមហ៊ុនចម្រុះទុន ដែលតាមរយៈវិធានការទាំងនោះ ទើបអ្នកផ្គត់ផ្គង់សេវាកម្មអាចផ្តល់សេវាកម្មណាមួយបាន និង

(ច) ការរឹតត្បិតលើការចូលរួមទុនរបស់បរទេស ក្នុងទម្រង់ជាភាគរយអតិបរមាលើភាគហ៊ុនបរទេស ឬលើតម្លៃសរុបនៃការវិនិយោគបរទេសដោយបុគ្គលឯកត្តជន ឬដោយការចូលរួមហ៊ុន។

## មាត្រា ៧.៥ តារាងសន្យាតាមវិស័យ

១. ភាគីនីមួយៗត្រូវសរសេរនៅក្នុងតារាងមួយនូវការសន្យាតាមវិស័យដែលខ្លួនធ្វើឡើងនៅក្រោម មាត្រា៧.៣ (ប្រព្រឹត្តិកម្មជាតិ) មាត្រា៧.៤ (ការបើកទីផ្សារ) និងមាត្រា៧.៦ (ការសន្យាបន្ថែម)។ ចំពោះវិស័យទាំងឡាយណាដែលការសន្យាទាំងនោះត្រូវបានធ្វើឡើង តារាងសន្យាតាមវិស័យនីមួយៗត្រូវបញ្ជាក់ដូចតទៅ៖

---

[១២] ប្រសិនបើភាគីមួយធ្វើការសន្យាចំពោះការបើកទីផ្សារទាក់ទងទៅនឹងការផ្គត់ផ្គង់សេវាកម្មតាមម៉ូតនៃការផ្គត់ផ្គង់សេវាកម្ម ដូចមានចែងក្នុងវាក្យខណ្ឌ(ក) អំពីនិយមន័យពាណិជ្ជកម្ម សេវាកម្មចែងក្នុងមាត្រា(X.១) និងប្រសិនបើចលនាមូលធនឆ្លងកាត់ព្រំដែន គឺជាផ្នែកសំខាន់មួយនៃសេវាកម្មរបស់ខ្លួន ភាគីនោះត្រូវសន្យាអនុញ្ញាតឱ្យមាន ចលនាមូលធននោះ។ ប្រសិនបើភាគីមួយធ្វើការសន្យាចំពោះការបើកទីផ្សារទាក់ទងទៅនឹងការផ្គត់ផ្គង់សេវាកម្មតាមម៉ូតនៃការផ្គត់ផ្គង់សេវាកម្មដូចមានចែងក្នុងវាក្យខណ្ឌ(គ) អំពីនិយមន័យពាណិជ្ជកម្មសេវាកម្មដែលមានក្នុងមាត្រា(X.១) ដោយហេតុនេះ ភាគីនោះបានសន្យាអនុញ្ញាតឱ្យមានការផ្ទេរមូលធនពាក់ព័ន្ធនោះចូលក្នុងដែនដីរបស់ខ្លួន។

[១៣] វាក្យខណ្ឌ២(គ) មិនគ្របដណ្តប់លើរាល់វិធានការរបស់ភាគីមួយដែលរឹតត្បិតធាតុចូលសម្រាប់ការផ្គត់ផ្គង់សេវាកម្មទាំងនោះ។

(ក) លក្ខខណ្ឌកំណត់ ការរឹតត្បិត និងលក្ខខណ្ឌនានាស្ដីពីការបើកទីផ្សារ

(ខ) លក្ខខណ្ឌ និងគុណវុឌ្ឍិនានានៃប្រព្រឹត្តិកម្មជាតិ

(គ) ការអនុវត្តនានាពាក់ព័ន្ធនឹងការសន្យាបន្ថែម និង

(ឃ) ក្របខណ្ឌពេលវេលាសម្រាប់ការអនុវត្តការសន្យាទាំងនោះ ប្រសិនបើសមស្រប។

២. វិធានការនានាដែលមិនស្របទាំងនៅក្នុងមាត្រា៧.៣ (ប្រព្រឹត្តិកម្មជាតិ) និងមាត្រា៧.៤ (ការបើកទីផ្សារ) ត្រូវសរសេរចូលក្នុងតារាងជួរឈរដែលពាក់ព័ន្ធនឹងមាត្រា៧.៤ (ការបើកទីផ្សារ)។ ក្នុងករណីនេះ ការសរសេរចូលនោះត្រូវពិចារណាកំណត់លក្ខខណ្ឌនិងគុណវុឌ្ឍិចំពោះមាត្រា៧.៣ (ប្រព្រឹត្តិកម្មជាតិ)។

៣. តារាងសន្យាតាមវិស័យត្រូវបានបញ្ចូលក្នុងកិច្ចព្រមព្រៀងនេះ ជាឧបសម្ព័ន្ធ៤ (តារាងសន្យាតាមវិស័យ)។

## មាត្រា ៧.៦ ការសន្យាបន្ថែម

ភាគីទាំងពីរអាចចរចាលើការសន្យាពាក់ព័ន្ធនឹងវិធានការនានា ដែលជះឥទ្ធិពលលើពាណិជ្ជកម្មសេវាកម្ម ដែលមិនមានក្នុងតារាងសន្យា ដែលធ្វើឡើងនៅក្រោមមាត្រា៧.៣ (ប្រព្រឹត្តិកម្មជាតិ) ឬមាត្រា៧.៤ (ការបើកទីផ្សារ) រួមបញ្ចូលទាំងប៉ុន្តែមិនសំដៅចំពោះតែវិធានការនានាពាក់ព័ន្ធនឹងគុណវុឌ្ឍិ ស្តង់ដារ ឬអាជ្ញាបណ្ណ។ ការសន្យានោះត្រូវបានសរសេរចូលក្នុងតារាងសន្យារបស់ភាគីមួយ។

## មាត្រា ៧.៧ បទប្បញ្ញត្តិក្នុងស្រុក

១. ចំពោះវិស័យសេវាកម្មដែលបានសន្យាក្រោមតារាងសន្យាតាមវិស័យ ភាគីនីមួយៗត្រូវធានាថា រាល់វិធានការនៃការអនុវត្តទូទៅទាំងអស់ដែលជះឥទ្ធិពលលើពាណិជ្ជកម្មសេវាកម្ម ត្រូវបានគ្រប់គ្រងដោយសមហេតុផល សត្យានុម័ត និងមិនលម្អៀង។

២. (ក) តាមសំណើរបស់អ្នកផ្គត់ផ្គង់សេវាកម្មដែលទទួលរងផលប៉ះពាល់ ភាគីនីមួយៗត្រូវរក្សាឬបង្កើតឱ្យបានឆាប់តាមដែលអាចធ្វើបាននូវអង្គជំនុំជម្រះ ឬនីតិវិធីផ្នែកយុត្តិធម៌ មជ្ឈត្តកម្ម ឬរដ្ឋបាលដើម្បីពិនិត្យឡើងវិញឱ្យបានឆាប់រហ័ស និងត្រឹមត្រូវនូវដំណោះស្រាយសមស្របសម្រាប់ការសម្រេចផ្នែករដ្ឋបាលដែលជះឥទ្ធិពលលើការធ្វើពាណិជ្ជកម្មសេវាកម្ម។ ក្នុងករណី នីតិវិធីនោះមិនស្ថិតក្រោមភ្នាក់ងារដែលត្រូវបានប្រគល់ភារកិច្ចលើសេចក្តីសម្រេចផ្នែករដ្ឋបាលពាក់ព័ន្ធ ភាគីនោះត្រូវធានាថា នីតិវិធីនោះត្រូវបានពិនិត្យឡើងវិញដោយលក្ខណៈសត្យានុម័តនិងមិនលម្អៀង។

(ខ) បទប្បញ្ញត្តិនៃវាក្យខណ្ឌ (ក) មិនត្រូវបានបកស្រាយដើម្បីតម្រូវឱ្យភាគីណាមួយបង្កើតអង្គជំនុំជម្រះឬនីតិវិធី ដែលមិនស្របតាមរចនាសម្ព័ន្ធរដ្ឋធម្មនុញ្ញ ឬលក្ខណៈនៃប្រព័ន្ធច្បាប់របស់ខ្លួនឡើយ។

៣. នៅពេលដែលតម្រូវឱ្យសុំសិទ្ធិអនុញ្ញាត ដើម្បីផ្គត់ផ្គង់សេវាកម្មលើវិស័យដែលបានសន្យាក្រោមជំពូកនេះ អាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីនីមួយៗត្រូវ៖

(ក) ក្នុងករណីដែលពាក្យស្នើសុំមិនមានលក្ខណៈគ្រប់គ្រាន់ ដោយយោងតាមសំណូមពររបស់អ្នកស្នើសុំ ត្រូវបង្ហាញពីព័ត៌មានបន្ថែមចាំបាច់នានា ដើម្បីបំពេញការដាក់ពាក្យស្នើសុំនោះ និងផ្តល់ឱកាសដើម្បីដោះស្រាយបញ្ហាខ្វះខាតក្នុងរយៈពេលសមរម្យ។

(ខ) ផ្តល់ព័ត៌មានអំពីបច្ចុប្បន្នភាពរបស់ពាក្យស្នើសុំដោយគ្មានការពន្យារពេលមិនសមស្របណាមួយ យោងតាមសំណើរបស់អ្នកដាក់ពាក្យស្នើសុំ និង

(គ) ប្រសិនបើពាក្យស្នើសុំត្រូវបានបញ្ចប់ឬបដិសេធ ត្រូវជូនដំណឹងដល់អ្នកដាក់ពាក្យជាលាយលក្ខណ៍អក្សរ និងមានហេតុផលនៃការបញ្ចប់ឬបដិសេធនោះ ដោយគ្មានការពន្យារពេល។ អ្នកដាក់ពាក្យស្នើសុំនឹងមានលទ្ធភាពដាក់ពាក្យស្នើសុំសារជាថ្មីម្តងទៀត ដោយឆន្ទានុសិទ្ធិរបស់ខ្លួន។

៤. ក្នុងគោលបំណងធានាថា វិធានការទាក់ទងលក្ខខណ្ឌតម្រូវនិងនីតិវិធីលើគុណវុឌ្ឍិ លក្ខខណ្ឌតម្រូវផ្នែកស្តង់ដារបច្ចេកទេសនិងការផ្តល់អាជ្ញាបណ្ណមិនបង្កើតជារបាំងមិនចាំបាច់ចំពោះពាណិជ្ជកម្មសេវាកម្ម ភាគីទាំងពីរត្រូវរួមគ្នាពិនិត្យឡើងវិញ នូវលទ្ធផលនៃការចរចាលើគោលការណ៍លើវិធានការទាំងនេះ អនុលោមតាមកថាខណ្ឌ ៤ នៃមាត្រាVI (បទប្បញ្ញត្តិក្នុងស្រុក) របស់កិច្ចព្រមព្រៀង GATS ដើម្បីដាក់បញ្ចូលគោលការណ៍ទាំងនោះទៅក្នុងកិច្ចព្រមព្រៀងនេះ។ ភាគីទាំងពីរកត់សម្គាល់ថារាល់គោលការណ៍ទាំងនោះមានគោលបំណងធានាថា ក្នុងចំណោមលក្ខខណ្ឌដទៃទៀត រាល់លក្ខខណ្ឌតម្រូវការទាំងនោះគឺ៖

(ក) ផ្អែកលើលក្ខណវិនិច្ឆ័យមិនលំអៀងនិងតម្លាភាព ដូចជាសមត្ថភាពនិងលទ្ធភាពដើម្បីផ្គត់ផ្គង់សេវាកម្ម

(ខ) មិនដាក់បន្ទុកដែលមិនចាំបាច់ ក្នុងការធានាដល់គុណភាពនៃសេវាកម្ម និង

(គ) មិនមែនជាការរឹតត្បិតដល់ការផ្គត់ផ្គង់សេវាកម្ម ក្នុងករណីមាននីតិវិធីផ្តល់អាជ្ញាបណ្ណ។

៥. (ក) ចំពោះវិស័យសេវាកម្មនានា ដែលភាគីមួយបានសន្យាតាមវិស័យនិងដោយអាស្រ័យលើការបញ្ចូលនូវគោលការណ៍ដែលមានចែងក្នុងកថាខណ្ឌ ៤ ភាគីនោះមិនត្រូវអនុវត្តលក្ខខណ្ឌតម្រូវនៃការចេញអាជ្ញាបណ្ណនិងគុណវុឌ្ឍិ និងបទដ្ឋានបច្ចេកទេស ដែលធ្វើមោឃភាព ឬធ្វើឱ្យប៉ះពាល់ដល់ការសន្យាតាមវិស័យទាំងនោះ ក្នុងលក្ខណៈមួយដែល៖

(i) មិនស្របតាមលក្ខណវិនិច្ឆ័យដែលមានចែងក្នុងវាក្យខណ្ឌ៤ (ក) (ខ) ឬ(គ) របស់មាត្រានេះ និង

(ii) មិនអាចត្រូវបានរំពឹងទុកដោយសមហេតុផលពីសំណាក់ភាគីនោះ នៅខណៈពេលដែលការសន្យាតាមវិស័យទាំងនោះត្រូវបានធ្វើឡើង។

(ខ) ដើម្បីកំណត់ថាតើភាគីមួយអនុវត្តកាតព្វកិច្ចសមស្របតាមវាក្យខណ្ឌ៥ (ក) ឬអត់ ត្រូវពិចារណាដល់ស្តង់ដារអន្តរជាតិនៃអង្គការអន្តរជាតិពាក់ព័ន្ធ[១៥] ដែលភាគីនោះបានអនុវត្តជាមួយ។

---

[១៥] វាក្យសព្ទ "អង្គការអន្តរជាតិពាក់ព័ន្ធ" សំដៅលើ អង្គភាពអន្តរជាតិដែលមានសមាជិកភាពបើកចំហដល់អង្គភាពពាក់ព័ន្ធរបស់ភាគីទាំងពីរនៃកិច្ចព្រមព្រៀងនេះ។

៦. ចំពោះវិស័យដែលបានសន្យាពាក់ព័ន្ធនឹងសេវាកម្មជំនាញវិជ្ជាជីវៈ ភាគីនីមួយៗត្រូវផ្តល់នីតិវិធីគ្រប់គ្រាន់ដើម្បីផ្ទៀងផ្ទាត់សមត្ថភាពរបស់អ្នកជំនាញវិជ្ជាជីវៈរបស់ភាគីមួយផ្សេងទៀត។

## មាត្រា ៧.៨ ការទទួលស្គាល់

១. ក្នុងគោលបំណងបំពេញតាមស្តង់ដារឬលក្ខណវិនិច្ឆ័យនានារបស់ភាគីនីមួយៗឱ្យបានទាំងស្រុង ឬដោយផ្នែក ក្នុងការផ្តល់សិទ្ធិអនុញ្ញាត ការចេញអាជ្ញាបណ្ណឬវិញ្ញាបនបត្រដល់អ្នកផ្គត់ផ្គង់សេវាកម្ម និងអាស្រ័យលើលក្ខខណ្ឌតម្រូវនៃកថាខណ្ឌ ៣ ក្នុងមាត្រានេះ ភាគីទាំងនោះអាចនឹងទទួលស្គាល់ចំណេះដឹងឬបទពិសោធន៍ ដែលទទួលបានលក្ខខណ្ឌតម្រូវផ្សេងៗ ឬអាជ្ញាបណ្ណឬវិញ្ញាបនបត្រ ដែលត្រូវបានផ្តល់ជូននៅក្នុងភាគីមួយទៀត។ ការទទួលស្គាល់បែបនេះ ដែលអាចសម្រេចបានតាមរយៈសុខដុមនីយកម្ម ឬម៉្យាងទៀត អាចផ្អែកលើកិច្ចព្រមព្រៀង ឬការព្រមព្រៀងរវាងភាគីទាំងពីរ ឬអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធរបស់ភាគីទាំងពីរ ឬអាចត្រូវបានផ្តល់ដោយស្វ័យភាព។

២. ភាគីមួយដែលជាភាគីនៃកិច្ចព្រមព្រៀងឬការព្រមព្រៀងដែលមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ មិនថាពេលបច្ចុប្បន្នឬអនាគត ត្រូវផ្តល់ឱកាសគ្រប់គ្រាន់ដល់ភាគីពាក់ព័ន្ធដែលមានចំណាប់អារម្មណ៍ចរចាលើការចូលរួមក្នុងកិច្ចព្រមព្រៀង ឬការព្រមព្រៀងបែបនោះ ឬការចរចាកិច្ចព្រមព្រៀង ឬការព្រមព្រៀងផ្សេងទៀត ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា។ នៅពេលដែលភាគីមួយទទួលស្គាល់ដោយស្វ័យភាព ភាគីនោះត្រូវផ្តល់ឱកាសគ្រប់គ្រាន់ដល់ភាគីផ្សេងទៀតដើម្បីបង្ហាញថា ការអប់រំ បទពិសោធន៍ អាជ្ញាបណ្ណ ឬវិញ្ញាបនបត្រ ដែលទទួលបានឬដែលបំពេញបានតាមលក្ខខណ្ឌតម្រូវនោះរបស់ភាគីផ្សេងទៀត ក៏ត្រូវបានទទួលស្គាល់ផងដែរ។

៣. ភាគីមួយមិនត្រូវយល់ព្រមលើការទទួលស្គាល់ក្នុងលក្ខណៈមួយ ដែលអាចបង្កើតបានជាកម្មវត្ថុនៃការរើសអើងរវាងភាគី ក្នុងការអនុវត្តស្តង់ដារ ឬលក្ខណវិនិច្ឆ័យនៃការផ្តល់សិទ្ធិអនុញ្ញាត ការផ្តល់អាជ្ញាបណ្ណ ឬការចេញវិញ្ញាបនបត្រដល់អ្នកផ្គត់ផ្គង់សេវាកម្ម ឬការរឹតត្បិតលើការក្លែងបន្លំការធ្វើពាណិជ្ជកម្មសេវាកម្ម។

## មាត្រា ៧.៩ កិច្ចសហប្រតិបត្តិការទទួលស្គាល់គុណវុឌ្ឍិ

ភាគីទាំងពីរខិតខំប្រឹងប្រែងលើកទឹកចិត្តដល់អាជ្ញាធររបស់ខ្លួនដែលទទួលបន្ទុកចេញអាជ្ញាបណ្ណ និងទទួលស្គាល់គុណវុឌ្ឍិផ្នែកជំនាញនិងវិជ្ជាជីវៈ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការរិះរកលទ្ធភាពដើម្បីទទួលស្គាល់គុណវុឌ្ឍិ ព្រមទាំងអាជ្ញាបណ្ណខាងផ្នែកជំនាញនិងវិជ្ជាជីវៈដទៃទៀត។

## មាត្រា ៧.១០ ការទូទាត់និងការផ្ទេរ

១. លើកលែងតែស្ថិតនៅក្រោមកាលៈទេសៈដែលមានចែងក្នុងមាត្រា១៥.៦ (វិធានការការពារជញ្ជីងទូទាត់) នៃជំពូក ១៥ (ការលើកលែង) ភាគីមួយមិនត្រូវដាក់របាំងលើការផ្ទេរនិងការទូទាត់ជាលក្ខណៈអន្តរជាតិសម្រាប់ប្រតិបត្តិការចរន្តទាំងឡាយ ដែលពាក់ព័ន្ធនឹងការសន្យាតាមវិស័យរបស់ខ្លួនឡើយ។

២. ពុំមានប្រការណាមួយនៅក្នុងជំពូកនេះ ត្រូវប៉ះពាល់ដល់សិទ្ធិនិងកាតព្វកិច្ចរបស់ភាគីណាមួយ ដែលជាសមាជិកនៃអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ ដូចដែលមានចែងក្នុងមាត្រានៃកិច្ចព្រមព្រៀងមូលនិធិ

រូបិយវត្ថុអន្តរជាតិ("មាត្រានៃកិច្ចព្រមព្រៀង") រួមទាំងការប្រើប្រាស់សកម្មភាពដោះដូរដែលស្របតាមមាត្រានៃកិច្ចព្រមព្រៀង ក្នុងន័យនេះ ភាគីមួយមិនត្រូវដាក់ការរឹតត្បិតលើប្រតិបត្តិការមូលធនទាំងឡាយណាដែលមិនសមស្របតាមការសន្យាតាមវិស័យរបស់ខ្លួនពាក់ព័ន្ធនឹងប្រតិបត្តិការទាំងនោះ លើកលែងតែមានចែងក្នុងមាត្រា១៥.៦ (វិធានការការពារតុល្យភាពជញ្ជីងទូទាត់) នៃជំពូក ១៥ (ការលើកលែង) ឬតាមសំណើរបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ។

## មាត្រា ៧.១១ ការបដិសេធផលប្រយោជន៍

ភាគីមួយអាចបដិសេធផលប្រយោជន៍នៃជំពូកនេះ៖

(ក) ចំពោះការផ្គត់ផ្គង់សេវាកម្ម ប្រសិនបើភាគីនោះរកឃើញថា សេវាកម្មនេះត្រូវបានផ្គត់ផ្គង់ចេញពីឬនៅក្នុងដែនដីនៃភាគីមួយទៀតដែលមិនមែនជាភាគីនៃកិច្ចព្រមព្រៀងនេះ

(ខ) ក្នុងករណីការផ្គត់ផ្គង់សេវាកម្មដឹកជញ្ជូនតាមផ្លូវសមុទ្រ ប្រសិនបើភាគីនោះរកឃើញថា សេវាកម្មនេះត្រូវបានផ្គត់ផ្គង់សេវាកម្ម៖

(i) ដោយនាវាដែលបានចុះបញ្ជីក្រោមច្បាប់របស់ភាគីមួយ ដែលមិនមែនជាភាគីនៃកិច្ចព្រមព្រៀងនេះ និង

(ii) ដោយបុគ្គលណាម្នាក់ មិនមែនជាភាគីនៃកិច្ចព្រមព្រៀងនេះ ដែលធ្វើប្រតិបត្តិការ និង/ឬ ប្រើប្រាស់នាវាទាំងស្រុងឬដោយផ្នែក

(គ) ចំពោះអ្នកផ្គត់ផ្គង់សេវាកម្មដែលជានីតិបុគ្គល ប្រសិនបើភាគីនោះរកឃើញថា នីតិបុគ្គលនោះមិនមែនជាអ្នកផ្គត់ផ្គង់សេវាកម្មរបស់ភាគីមួយទៀតឡើយ។

## មាត្រា ៧.១២ តម្លាភាព

១. ភាគីទាំងពីរទទួលស្គាល់ថាវិធានការតម្លាភាពដែលគ្រប់គ្រងពាណិជ្ជកម្មសេវាកម្មមានសារៈសំខាន់ក្នុងការជួយសម្រួលអ្នកផ្គត់ផ្គង់សេវាកម្មឱ្យមានលទ្ធភាពទទួលបាន និងធ្វើប្រតិបត្តិការក្នុងទីផ្សាររបស់ភាគីទាំងពីរ។ ភាគីនីមួយៗត្រូវជំរុញឱ្យមានតម្លាភាពខាងបទប្បញ្ញត្តិក្នុងការធ្វើពាណិជ្ជកម្មសេវាកម្ម។

២. លើកលែងតែក្នុងគ្រាអាសន្ន ភាគីនីមួយៗត្រូវធ្វើការបោះពុម្ពផ្សាយឱ្យបានឆាប់និងយ៉ាងហោចណាស់ត្រឹមពេលចូលជាធរមាននៃកិច្ចព្រមព្រៀងនូវ៖

(ក) រាល់វិធានការពាក់ព័ន្ធនៃការអនុវត្តជាទូទៅដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម និង

(ខ) រាល់កិច្ចព្រមព្រៀងអន្តរជាតិដែលអនុវត្តចំពោះ ឬជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្មដែលភាគីជាហត្ថលេខី។

៣. ក្នុងករណីដែលអាចធ្វើបាន ភាគីនីមួយៗត្រូវផ្សព្វផ្សាយជាសាធារណៈតាមអ៊ីនធើណែតនូវរាល់វិធានការ និងកិច្ចព្រមព្រៀងអន្តរជាតិដែលមានចែងក្នុងកថាខណ្ឌ ២ នៃមាត្រានេះ។

៤. ករណីការបោះពុម្ពផ្សាយដែលមានចែងក្នុងកថាខណ្ឌ ២ និងកថាខណ្ឌ ៣ នៃមាត្រានេះ មិនអាចអនុវត្តបាន ព័ត៌មានទាំងនោះ[១៥] អាចរកបានជាសាធារណៈ។

៥. ក្នុងករណីមានចែងក្រោមក្របខណ្ឌច្បាប់នៅក្នុងប្រទេសរបស់ខ្លួន ភាគីនីមួយៗត្រូវខិតខំប្រឹងប្រែងផ្តល់ឱកាសសមស្របដល់បុគ្គលពាក់ព័ន្ធរបស់ភាគីទាំងពីរក្នុងការផ្តល់យោបល់លើរាល់វិធានការដែលមានចែងក្នុងវាក្យខណ្ឌ២(ក) មុនពេលមានការអនុម័ត។

៦. ភាគីនីមួយៗត្រូវឆ្លើយតបឱ្យបានឆាប់ចំពោះគ្រប់សំណើដោយភាគីណាមួយដែលស្នើសុំព័ត៌មានជាក់លាក់អំពី៖

(ក) វិធានការណាមួយដែលមានចែងក្នុងវាក្យខណ្ឌ២(ក) នៃមាត្រានេះ ឬកិច្ចព្រមព្រៀងអន្តរជាតិនានាដែលមាន ចែងក្នុងវាក្យខណ្ឌ២(ខ) នៃមាត្រានេះ និង

(ខ) ច្បាប់ បទប្បញ្ញត្តិ ឬសេចក្តីណែនាំផ្នែករដ្ឋបាលថ្មីៗ ឬការកែប្រែណាមួយលើច្បាប់ បទប្បញ្ញត្តិ ឬសេចក្តីណែនាំផ្នែករដ្ឋបាលជាធរមានដែលជះឥទ្ធិពលគួរឱ្យកត់សម្គាល់ដល់ពាណិជ្ជកម្មសេវាកម្មដែលបានសន្យាក្រោមតារាងសន្យាតាមវិស័យរបស់ភាគីក្រោមជំពូកនេះ ទោះបីជាភាគីមួយទៀតត្រូវបាន ឬមិនត្រូវបានជូនដំណឹងជាមុនក៏ដោយអំពីច្បាប់ បទប្បញ្ញត្តិ ឬសេចក្តីណែនាំផ្នែករដ្ឋបាលថ្មីៗ ឬដែលត្រូវបានកែប្រែនោះ។

៧. ក្នុងករណីអាចអនុវត្តបាន ប្រសិនបើមានការតម្រូវឱ្យមានអាជ្ញាបណ្ណសម្រាប់ការផ្គត់ផ្គង់សេវាកម្មដែលបានសន្យាក្រោមជំពូកនេះ ភាគីនីមួយៗត្រូវធានាថា រាល់វិធានការពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណនៃសេវាកម្មទាំងនោះ អាចរកបានជាសាធារណៈ។

៨. អនុលោមតាមច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួន នៅពេលមានការស្នើសុំ ភាគីនីមួយៗត្រូវធានាថា បុគ្គលដែលបានដាក់ពាក្យស្នើសុំទទួលបានមូលហេតុចំពោះការបដិសេធ ការទុកជាមោឃៈ ការមិនព្រមបន្ត ឬការកំណត់លក្ខខណ្ឌ ឬការកែប្រែលក្ខខណ្ឌលើអាជ្ញាបណ្ណ។ ក្នុងករណីដែលអាចធ្វើបាន ភាគីនីមួយៗត្រូវខិតខំប្រឹងប្រែងផ្តល់ព័ត៌មានដូចនោះ ជាលាយលក្ខណ៍អក្សរ។

## មាត្រា ៧.១៣ អាជីវកម្មផ្តាច់មុខ និងអ្នកផ្គត់ផ្គង់សេវាកម្មផ្តាច់មុខ

១. ក្នុងការផ្គត់ផ្គង់សេវាកម្មផ្តាច់មុខក្នុងទីផ្សារពាក់ព័ន្ធ ភាគីនីមួយៗត្រូវធានាថាអ្នកផ្គត់ផ្គង់សេវាកម្មផ្តាច់មុខនៅក្នុងដែនដីរបស់ខ្លួន មិនប្រព្រឹត្តក្នុងលក្ខណៈមិនសមស្របតាមកាតព្វកិច្ចរបស់ខ្លួន ដោយអនុលោមតាមការសន្យាតាមវិស័យ។

២. នៅពេលដែលអ្នកផ្គត់ផ្គង់ផ្តាច់មុខរបស់ភាគីមួយ ប្រកួតប្រជែងដោយផ្ទាល់ឬតាមរយៈក្រុមហ៊ុនបុត្រសម្ព័ន្ធក្នុងការផ្គត់ផ្គង់សេវាកម្មដែលស្ថិតនៅក្រៅវិសាលភាពនៃសិទ្ធិផ្តាច់មុខរបស់ខ្លួន និងកម្មវត្ថុនៃការសន្យាតាមវិស័យរបស់ភាគីនោះ ភាគីនោះត្រូវធានាថាអ្នកផ្គត់ផ្គង់ផ្តាច់មុខនេះ មិនបំពានតួនាទីផ្តាច់មុខរបស់ខ្លួនក្នុងការផ្គត់ផ្គង់នៅក្នុងដែនដីរបស់ខ្លួនក្នុងលក្ខណៈដែលមិនស្របតាមការសន្យានោះ។

---

[១៥] ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ ភាគីទាំងពីរព្រមព្រៀងថា ព័ត៌មានទាំងនោះអាចបោះផ្សាយជាភាសាដែលត្រូវបានជ្រើសរើសដោយភាគី។

៣. ប្រសិនបើភាគីណាមួយមានមូលហេតុដែលជឿថាអ្នកផ្គត់ផ្គង់សេវាកម្មផ្តាច់មុខរបស់ភាគីផ្សេងទៀត កំពុងតែប្រព្រឹត្តមិនស្របនឹងបទប្បញ្ញត្តិដែលមានចែងក្នុងកថាខណ្ឌ ១ ឬកថាខណ្ឌ ២ នៃមាត្រានេះ ភាគីនោះអាចស្នើភាគីពាក់ព័ន្ធផ្សេងទៀត ដែលបង្កើត រក្សាទុក ឬផ្តល់សិទ្ធិអនុញ្ញាតឱ្យអ្នកផ្គត់ផ្គង់សេវាកម្មនោះ ផ្តល់ព័ត៌មានជាក់លាក់ អំពីប្រតិបត្តិការពាក់ព័ន្ធរបស់ខ្លួន។

៤. បទប្បញ្ញត្តិនានានៃមាត្រានេះ ត្រូវអនុវត្តផងដែរ ចំពោះករណីដែលអ្នកផ្គត់ផ្គង់សេវាកម្មផ្តាច់មុខទាំងឡាយ ដែលភាគីណាមួយ ជាផ្លូវការ(ក) ផ្តល់សិទ្ធិ ឬបង្កើតអ្នកផ្គត់ផ្គង់សេវាមួយចំនួនតូច និង (ខ) រារាំងដល់ការប្រកួតប្រជែងគួរឱ្យកត់សម្គាល់ក្នុងចំណោមអ្នកផ្គត់ផ្គង់ទាំងនោះក្នុងដែនដីរបស់ខ្លួន។

## មាត្រា ៧.១៤ ការអនុវត្តធុរកិច្ច

១. ក្រៅពីការអនុវត្តដែលស្ថិតក្រោមមាត្រា៧.១៣ (ការផ្គត់ផ្គង់ផ្តាច់មុខនិងអ្នកផ្គត់ផ្គង់សេវាកម្មផ្តាច់មុខ) ភាគីទាំងពីរទទួលស្គាល់ថា ការអនុវត្តធុរកិច្ចមួយចំនួនរបស់អ្នកផ្គត់ផ្គង់សេវាកម្ម អាចជារបាំងដល់ការប្រកួតប្រជែង និងជាលទ្ធផលបង្កើតបានជារបាំងដល់ពាណិជ្ជកម្មសេវាកម្ម។

២. ផ្អែកតាមសំណើរបស់ភាគីមួយទៀត ("ភាគីស្នើសុំ") ភាគីនីមួយៗត្រូវចូលរួមពិគ្រោះយោបល់ ក្នុងគោលបំណងលុបបំបាត់ការអនុវត្តនានា ដូចមានចែងក្រោមកថាខណ្ឌ ១ នៃមាត្រានេះ។ ភាគីដែលត្រូវបានស្នើសុំ ("ភាគីដែលត្រូវបានស្នើសុំ") ត្រូវពិចារណាឱ្យបានពេញលេញ និងប្រកបដោយសមានចិត្តចំពោះសំណើដែលត្រូវបានលើក ហើយត្រូវសហការតាមរយៈការផ្តល់ព័ត៌មានដែលមិនសម្ងាត់ពាក់ព័ន្ធនឹងបញ្ហានោះ។ ភាគីដែលត្រូវបានស្នើសុំ ក៏ត្រូវផ្តល់ផងដែរនូវព័ត៌មានដែលអាចរកបានផ្សេងទៀតដល់ភាគីស្នើសុំ ដោយអនុលោមតាមច្បាប់ក្នុងស្រុករបស់ខ្លួននិងអាស្រ័យលើការព្រមព្រៀងគ្នាពាក់ព័ន្ធនឹងការការពារកិច្ចការសម្ងាត់របស់ខ្លួន។

## មាត្រា ៧.១៥ បទប្បញ្ញត្តិផ្សេងៗ

ឧបសម្ព័ន្ធស្តីពីបំលាស់ទីរូបវន្តបុគ្គលដើម្បីផ្គត់ផ្គង់សេវាកម្ម ឧបសម្ព័ន្ធស្តីពីសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ឧបសម្ព័ន្ធស្តីពីសេវាកម្មហិរញ្ញវត្ថុ និងឧបសម្ព័ន្ធស្តីពីទូរគមនាគមន៍ក្រោមកិច្ចព្រមព្រៀង GATS ត្រូវអនុវត្តនៅក្នុងកិច្ចព្រមព្រៀងនេះ ហើយអាចអនុវត្តតាមការកែប្រែនានានៃឧបសម្ព័ន្ធទាំងនោះ ប្រសិនបើមានការចាំបាច់ ។

# ជំពូក ៨
# កិច្ចសហប្រតិបត្តិការវិនិយោគ

## មាត្រា ៨.១ ទំនាក់ទំនងទៅនឹងកិច្ចព្រមព្រៀងដទៃទៀត និងការរៀបចំដទៃទៀត

១. ភាគីទាំងពីរ ទទួលស្គាល់នូវសារៈសំខាន់នៃកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីអំពីការជំរុញនិងការការពារវិនិយោគដែលបានចុះហត្ថលេខា ក្នុងឆ្នាំ១៩៩៦ និងកិច្ចព្រមព្រៀងស្តីពីការវិនិយោគនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋប្រជាមានិតចិនដែលបានចុះហត្ថលេខា ក្នុងឆ្នាំ២០០៩ ក្នុងការបង្កើតលក្ខខណ្ឌអនុគ្រោះសម្រាប់ការវិនិយោគរវាងភាគីទាំងពីរ ហើយដូច្នេះ បញ្ជាក់អះអាងជាថ្មីពីការប្តេជ្ញាចិត្ត ក្រោមកិច្ចព្រមព្រៀង និងការរៀបចំដទៃទៀតទាក់ទងនឹងការវិនិយោគរវាងភាគីទាំងពីរ។

២. ភាគីទាំងពីរទទួលស្គាល់នូវប្រសិទ្ធិភាពនៃការរៀបចំស្ថាប័នដែលមានស្រាប់ និងតួនាទីដ៏សំខាន់របស់ស្ថាប័នទាំងនេះ ដើម្បីធ្វើប្រត្យក្សកម្មកិច្ចសហប្រតិបត្តិការសមត្ថភាពផលិត និងការវិនិយោគទ្វេភាគី ហើយប្តេជ្ញាពង្រឹងនិងធ្វើឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការទាំងនេះ។

## មាត្រា ៨.២ ការជំរុញវិនិយោគ

១. ភាគីទាំងពីរទទួលស្គាល់នូវសារៈសំខាន់នៃការជំរុញលំហូរវិនិយោគឆ្លងកាត់ព្រំដែន ដែលជាមធ្យោបាយមួយដើម្បីសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍ។ យោងតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន ភាគីទាំងពីរត្រូវសហការ ជំរុញការវិនិយោគ រវាង ចិន និងកម្ពុជា តាមរយៈ៖

(ក) កំណត់នូវកាលានុវត្តភាពវិនិយោគ

(ខ) បង្កើនឱ្យកាន់តែខ្លាំងឡើងនូវយុទ្ធនាការនៃការជំរុញវិនិយោគ

(គ) ចែករំលែកព័ត៌មានស្តីពីវិធានការនានាដើម្បីជំរុញវិនិយោគក្រៅប្រទេស

(ឃ) ផ្លាស់ប្តូរព័ត៌មានស្តីពីច្បាប់វិនិយោគ, បទប្បញ្ញត្តិ, និងគោលនយោបាយពាក់ព័ន្ធនានា

(ង) ជួយអ្នកវិនិយោគឱ្យយល់ដឹងពីបទប្បញ្ញត្តិ និងបរិស្ថានវិនិយោគរបស់ភាគីទាំងពីរ

(ច) កែលម្អបរិស្ថានប្រកបដោយលក្ខណៈអនុគ្រោះដើម្បីបង្កើនលំហូរវិនិយោគ;

(ឆ) ជំរុញសន្ទានកម្មរវាងស្ថាប័នរបស់ចិន និងកម្ពុជា ក្នុងគោលដៅជំរុញការវិនិយោគទ្វេភាគី

២ .ដោយទទួលស្គាល់ថា ការផ្តល់កិច្ចសម្រួលដល់កិច្ចខិតខំប្រឹងប្រែង "ទៅសកល - Go Global" នៃសហគ្រាសចិន គឺជាសសរស្តម្ភគន្លឹះនៃកិច្ចសហប្រតិបត្តិការទ្វេភាគី ភាគីទាំងពីរត្រូវបង្កើនឱ្យកាន់តែខ្លាំងឡើងនូវកិច្ចសហការក្នុងបរិវេណនេះ។ ដើម្បីបានប្រសិទ្ធភាពនេះ ភាគីទាំងពីរត្រូវខិតខំប្រឹងប្រែងកំណត់ និងចែករំលែកព័ត៌មានស្តីពីសកម្មភាព និងវិស័យវិនិយោគដែលមានសក្តានុពលទៅក្រៅប្រទេស ហើយជំរុញលើកទឹកចិត្តសហគ្រាសទាំងនេះឱ្យទៅវិនិយោគនៅប្រទេសនៃភាគីមួយទៀត។

## មាត្រា ៨.៣ កិច្ចសម្រួលវិនិយោគ

១. យោងទៅតាមច្បាប់និងបទប្បញ្ញត្តិរបស់ខ្លួន ភាគីនីមួយៗ ត្រូវផ្តល់កិច្ចសម្រួលវិនិយោគពីភាគីមួយទៀត តាមរយៈ ៖

(ក) កែលម្អតម្លាភាព និងប្រសិទ្ធិភាពនៃបរិស្ថានវិនិយោគក្នុងស្រុករបស់ខ្លួន ជាមួយនឹងគោលដៅផ្តល់កិច្ចសម្រួលការវិនិយោគប្រកបដោយគុណភាពរវាងភាគីទាំងពីរ។

(ខ) បង្កើតបរិស្ថានចាំបាច់សម្រាប់គ្រប់ទម្រង់នៃការវិនិយោគ រាប់បញ្ចូលទាំង ប៉ុន្តែមិនកំណត់ត្រឹមការបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់ការផ្ទេររូបិយប័ណ្ណសម្រាប់គម្រោងវិនិយោគណាមួយ។

(គ) ធ្វើសាមញ្ញកម្មនីតិវិធីសម្រាប់ការស្នើសុំវិនិយោគ និងការអនុម័តវិនិយោគ

(ឃ) ជំរុញការផ្សព្វផ្សាយនៃព័ត៌មានវិនិយោគ រាប់បញ្ចូលទាំង ប៉ុន្តែមិនកំណត់ត្រឹម វិធាននៃការវិនិយោគ បទប្បញ្ញត្តិ គោលនយោបាយ កិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី និងពហុភាគី និងនីតិវិធីដទៃទៀត និង

(ង) ធ្វើឱ្យប្រសើរឡើងនូវការរៀបចំច្រកចេញ-ចូលសម្រាប់ការវិនិយោគតែមួយ នៅក្នុងភាគីម្ចាស់ផ្ទះ ដើម្បីផ្តល់សេវាកម្មប្រឹក្សាយោបល់ និងជួយដល់វិស័យធុរកិច្ច រួមទាំងផ្តល់កិច្ចសម្រួលនៃការទទួលបានអាជ្ញាប័ណ្ណប្រតិបត្តិការ និងលិខិតអនុញ្ញាតផ្សេងៗ។

២. យោងទៅតាមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុក, ភាគីមួយត្រូវផ្តល់វិធានការនានាដែលចែងអំពីបែបបទនៃការបង្កើតការវិនិយោគដល់អ្នកវិនិយោគ និងការវិនិយោគរបស់អ្នកវិនិយោគរបស់ខ្លួននៅក្នុងភាគីមួយទៀត។ ភាគីមួយ ត្រូវការពារព័ត៌មានធុរកិច្ចសម្ងាត់ពីការបញ្ចេញណាមួយដែលនាំឱ្យខូចខាតដល់ជំហរប្រកួតប្រជែងរបស់អ្នកវិនិយោគឬការវិនិយោគ។ គ្មានអ្វីនៅក្នុងកថាខណ្ឌនេះត្រូវបានបកស្រាយដើម្បីរារាំង ភាគីណាមួយ ពីការទទួលបាន ឬបញ្ចេញព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តច្បាប់ក្នុងស្រុករបស់ខ្លួនប្រកបដោយសមធម៌និងសុចរិត។

៣. ភាគីទាំងពីរត្រូវផ្តល់កិច្ចសម្រួលដល់អ្នកវិនិយោគនិងការវិនិយោគរបស់ពួកគេ ដើម្បីបំពេញអនុលោមភាពជាមួយនឹងស្តង់ដារតម្រូវ ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ការវាយតម្លៃហេតុប៉ះពាល់សង្គម និងដំណើរការវាយតម្លៃដែលអាចអនុវត្តបានចំពោះសំណើវិនិយោគដែលបានស្នើសុំមុនការបង្កើត ដូចបានតម្រូវដោយច្បាប់របស់ភាគីម្ចាស់ផ្ទះចំពោះការវិនិយោគទាំងនេះ។

## មាត្រា ៨.៤ វិធានការការពារបរិស្ថាន

ដោយទទួលស្គាល់ពីសារៈសំខាន់នៃការជំរុញវិនិយោគសម្រាប់កំណើនបៃតង ភាគីទាំងពីរត្រូវជៀសវាងពីការជំរុញលើកទឹកចិត្តដល់ការវិនិយោគដោយអ្នកវិនិយោគនៃភាគីមួយទៀត ដោយបន្ធូរបន្ថយវិធានការបរិស្ថាន។ ដើម្បីបានប្រសិទ្ធភាពនេះ ភាគីនីមួយៗមិនគួរលើកលែងឬធ្វើបដិបញ្ញត្តិអំពីវិធានការបរិស្ថានទាំងនេះ ជាការជំរុញលើកទឹកចិត្តសម្រាប់ការបង្កើត ការទទួលបាន ឬការពង្រីកនៃការវិនិយោគនៅក្នុងដែនដីរបស់ខ្លួនឡើយ។

## មាត្រា ៨.៥. គណៈកម្មាធិការស្ដីពីកិច្ចសហប្រតិបត្តិការវិនិយោគ

១. ភាគីទាំងពីរ ត្រូវបង្កើតគណៈកម្មាធិការស្ដីពីកិច្ចសហប្រតិបត្តិការវិនិយោគ (តទៅនេះហៅកាត់ថា "គណៈកម្មាធិការ") សំដៅសម្រេចឱ្យបាននូវគោលបំណងនៃជំពូកនេះ។ មុខងាររបស់គណៈកម្មាធិការនេះ ត្រូវ៖

(ក). ដើរតួនាទីជាមន្ត្រីទំនាក់ទំនងនៃបញ្ហាវិនិយោគដែលលើកឡើងក្នុងជំពូកនៃកិច្ចសហប្រតិបត្តិការវិនិយោគ

(ខ). ពិភាក្សា និងពិនិត្យឡើងវិញនូវការអនុវត្ត និងប្រតិបត្តិការនៃជំពូកនេះ

(គ). ពិភាក្សាលើបញ្ហាពាក់ព័ន្ធនឹងការវិនិយោគដែលទាក់ទងនឹងជំពូកនេះ, និង

(ឃ). ពិភាក្សាលើវិធានការដែលបានអនុម័ត ឬរក្សាទុក ក្នុងគោលបំណងជំរុញលើកទឹកចិត្តដល់លក្ខខណ្ឌអនុគ្រោះសម្រាប់អ្នកវិនិយោគនៃភាគីទាំងពីរ។

២. តាមភាពចាំបាច់ គណៈកម្មាធិការនេះ អាចផ្ដល់អនុសាសន៍សមស្របដោយកុងសង់ស៊ីសឱ្យភាគីទាំងពីរសម្រាប់បំពេញភារកិច្ចកាន់តែមានប្រសិទ្ធិភាពឬការសម្រេចបាននូវគោលបំណងនៃកិច្ចព្រមព្រៀងនេះ។

៣. គណៈកម្មាធិការនេះ ត្រូវមានសមាសភាពពីតំណាងនៃភាគីទាំងពីរ។ គណៈកម្មាធិការត្រូវកំណត់វិធាននៃនីតិវិធីធ្វើការដើម្បីអនុវត្តនូវមុខងាររបស់ខ្លួន។

៤. តាមការយល់ព្រមទៅវិញទៅមកនៅភាគីទាំងពីរ គណៈកម្មាធិការនេះអាចរៀបចំកិច្ចប្រជុំរួមជាមួយផ្នែកឯកជន។

## មាត្រា ៨.៦. ការមិនអនុវត្តចំពោះការដោះស្រាយវិវាទ

គ្មានភាគីណាមួយ ត្រូវមានឧបាស្រ័យចំពោះជំពូក ១៤ (ការដោះស្រាយវិវាទ) សម្រាប់បញ្ហាណាមួយដែលកើតឡើង ឬពាក់ព័ន្ធនឹងជំពូកនេះឡើយ។

# ជំពូក ៩
# កិច្ចសហប្រតិបត្តិការក្រោមគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវ

## មាត្រា ៩.១ បទប្បញ្ញត្តិទូទៅ

១. ភាគីទាំងពីរមានភាពពេញចិត្តចំពោះវឌ្ឍនភាពដែលទទួលបានក្នុងក្របខណ្ឌសហប្រតិបត្តិការក្រោមគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវ ជាពិសេសលទ្ធផលដែលទទួលបាននៅក្នុងវិស័យដែលមានចែងនៅក្នុងចំណុចគោលនៃផែនការកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីរួមគ្នាកសាងកិច្ចសហប្រតិបត្តិការខ្សែក្រវាត់សេដ្ឋកិច្ចផ្លូវសូត្រ និងកិច្ចសហប្រតិបត្តិការផ្លូវសមុទ្រសតវត្សរ៍ទី២១ រវាងសាធារណរដ្ឋប្រជាមានិតចិន និងព្រះរាជាណាចក្រកម្ពុជា និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នៃរាជរដ្ឋាភិបាលកម្ពុជា។

២. ភាគីទាំងពីរនឹងពង្រឹងតួនាទីរបស់គំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវ ទៅជាឧបករណ៍សំខាន់មួយ និងប្រឹងប្រែងពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការខ្សែក្រវាត់ និងផ្លូវដែលមានគុណភាពខ្ពស់ ដើម្បីជំរុញការសម្របសម្រួលគោលនយោបាយ ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ ការធ្វើពាណិជ្ជកម្មដោយមិនមានការរាំងស្ទះ ការធ្វើសមាហរណកម្មហិរញ្ញវត្ថុ និងមិត្តភាពរវាងប្រជាជននិងប្រជាជន ក្នុងគោលបំណងលើកកម្ពស់កិច្ចសហប្រតិបត្តិការជាក់ស្តែង សម្រាប់សុខុមាលភាពរបស់ប្រជាជននៃប្រទេសទាំងពីរ និងគាំទ្រដល់ការអនុវត្តកិច្ចព្រមព្រៀងនេះ។

៣. ភាគីទាំងពីរយល់ស្របអំពីតម្រូវការនៃភាពជាដៃគូយុទ្ធសាស្ត្រស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ នៅក្រោមវិសាលភាព និងភាពគ្របដណ្តប់នៃកិច្ចព្រមព្រៀងនេះ ដែលដឹកនាំដោយគោលការណ៍នៃការពិគ្រោះយោបល់ទូលំទូលាយ ការប្រឹងប្រែង និងផលប្រយោជន៍រួមគ្នា និងអភិក្រមស្តីពីកិច្ចសហប្រតិបត្តិការបើកទូលាយ និងស្អាតស្អំ ឈោងទៅរកការទទួលបាននូវកម្រិតស្តង់ដារខ្ពស់ ការអភិវឌ្ឍន៍ដែលផ្តោតទៅលើប្រជាជនជាគោល និងប្រកបដោយចីរភាព។ ភាគីទាំងពីរ ព្រមព្រៀងក្នុងការអនុវត្តសកម្មភាពដទៃទៀត ដើម្បីអនុវត្តវត្ថុធាតុនៅក្រោម ចំណុចគោលនៃផែនការកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីរួមគ្នាកសាងកិច្ចសហប្រតិបត្តិការខ្សែក្រវាត់សេដ្ឋកិច្ចផ្លូវសូត្រ និងកិច្ចសហប្រតិបត្តិការផ្លូវសមុទ្រសតវត្សរ៍ទី២១ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤។

៤. ភាគីទាំងពីរព្រមព្រៀងក្នុងការពង្រឹងបន្ថែមកិច្ចសហប្រតិបត្តិការទៅលើវិស័យគន្លឹះដូចជា ហេដ្ឋារចនាសម្ព័ន្ធ វិនិយោគ ច្រករបៀងសេដ្ឋកិច្ច តំបន់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច កសិកម្ម ការកសាងសមត្ថភាព សួនឧស្សាហកម្ម តំបន់បណ្តុំ វប្បធម៌និងទេសចរណ៍និងហិរញ្ញវត្ថុ និងការការពារបរិស្ថាន។ កិច្ចសហប្រតិបត្តិការទាំងនោះនឹងស្រាវជ្រាវអំពីប្រភពនៃកំណើនថ្មីៗ និងពិនិត្យដើម្បីផ្តល់ជូននូវកាលានុវត្តភាពសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម និងរួមចំណែកដល់កិច្ចសហប្រតិបត្តិការឈ្នះ-ឈ្នះ និងវិបុលភាពរួម។ ភាគីទាំងពីរនឹងពិនិត្យលើវិស័យសហប្រតិបត្តិការសក្តានុពលក្នុងគោលបំណងលើកកម្ពស់ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ ពង្រឹងភាពស៊ីសង្វាក់នៃគោលនយោបាយសម្រាប់ការអភិវឌ្ឍន៍ និងជំរុញការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

៥. ភាគីទាំងពីរនឹងរួមគ្នាជំរុញកិច្ចសហប្រតិបត្តិការ ក្រោមគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ តាមរយៈយន្តការសហប្រតិបត្តិការទ្វេភាគីដែលមានស្រាប់ ដូចជាក្រុមប្រឹក្សាចម្រុះចិន-កម្ពុជាសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគី និងយន្តការពហុភាគីដែលភាគីទាំងពីរចូលរួម រួមមានកិច្ចប្រជុំកំពូលអាស៊ីខាងកើត កិច្ចសហប្រតិបត្តិការឡានចាង-មេគង្គ កិច្ចប្រជុំអាស៊ី-អឺរ៉ុប និងមហាអនុតំបន់មេគង្គ ដើម្បីស្វែងរកវិស័យសហប្រតិបត្តិការសក្តានុពល។

៦. ភាគីទាំងពីរព្រមព្រៀងនឹងប្រើប្រាស់ឱ្យបានពេញលេញនូវឧត្តមភាពភូមិសាស្ត្ររបស់កម្ពុជា ដើម្បីធ្វើឱ្យប្រសើរឡើងនៃកម្រិតតភ្ជាប់ និងលើកទឹកចិត្តដល់សហគ្រាសនៃប្រទេសទាំងពីរក្នុងការធ្វើពាណិជ្ជកម្ម វិនិយោគ សមត្ថភាពផលិតកម្ម និងសហការការពារបរិស្ថានជាមួយគ្នា ក្នុងគោលបំណងរួមចំណែកដល់ការធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍពាណិជ្ជកម្ម និងសេដ្ឋកិច្ចប្រកបដោយចីរភាពនៃប្រទេសទាំងពីរ។

៧. ភាគីទាំងពីរព្រមព្រៀងជំរុញការប្រើប្រាស់ធនធានដែលមានស្រាប់ក្រោមគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវតាមភាពសមស្រប ដើម្បីទាញយកផលប្រយោជន៍ជាអតិបរមាពីកិច្ចព្រមព្រៀងនេះ និងលើកទឹកចិត្តឱ្យមានការចូលរួមផងដែរពីវិស័យឯកជន គ្រឹះស្ថានសិក្សា និងអង្គការមិនមែនរដ្ឋាភិបាល សំដៅលើកកម្ពស់ជំនាញ និងចំណេះដឹងគ្រប់គ្រងដែលពាក់ព័ន្ធ នវានុវត្តន៍ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ភាពប្រកួតប្រជែង និងកាលានុវត្តភាពពាណិជ្ជកម្ម និងវិនិយោគ។

៨. ភាគីទាំងពីរយល់ស្របលើភាពសំខាន់នៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជាតិ ដើម្បីទាញយកឱ្យបានជាអតិបរមានូវផលប្រយោជន៍ និងកាលានុវត្តភាពដែលបង្កើតឡើងដោយកិច្ចព្រមព្រៀងនេះ។

## មាត្រា ៩.២. ការមិនអនុវត្តចំពោះការដោះស្រាយវិវាទ

គ្មានភាគីណាមួយ ត្រូវមានឧបាស្រ័យចំពោះជំពូក ១៤ (ការដោះស្រាយវិវាទ) សម្រាប់បញ្ហាណាមួយដែលកើតឡើង ឬពាក់ព័ន្ធនឹងជំពូកនេះឡើយ។

# ជំពូក១០

# ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

## មាត្រា ១០.១ និយមន័យ

សម្រាប់គោលបំណងនៃជំពូកនេះ៖

**យថាភូតភាពអេឡិចត្រូនិក** សំដៅដល់ដំណើរការបញ្ជាក់ឬធ្វើតេស្តប្រយោគឬអំណះអំណាងអេឡិចត្រូនិក ដើម្បីបង្កើតនូវកម្រិតជំនឿទុកចិត្តមួយទៅលើភាពគួរអោយទុកចិត្តបាននៃប្រយោគឬអំណះអំណាងនោះ។

**ហត្ថលេខាអេឡិចត្រូនិក** គឺមានន័យដូចបានកំណត់នៅក្នុងច្បាប់និងប្បញ្ញត្តិរបស់ភាគីនីមួយៗ ។

**ឯកសារក្នុងទម្រង់អេឡិចត្រូនិក** សំដៅដល់ទម្រង់នៃព័ត៌មាន ទិន្នន័យ ឬឯកសារដែលបានបង្កើត ផ្ញើ/បញ្ជូន ទទួល ឬរក្សាទុកនៅក្នុងប្រព័ន្ធអេឡិចត្រូនិក។

**ព័ត៌មានឯកជន** សំដៅដល់ព័ត៌មានទាំងឡាយណា រួមទាំងទិន្នន័យ អំពីអត្តសញ្ញាណ ឬអាចកំណត់អត្តសញ្ញាណបុគ្គលម្នាក់បាន។

**ឯកសាររដ្ឋបាលពាណិជ្ជកម្ម** សំដៅដល់ទម្រង់ដែលចេញដោយ ឬគ្រប់គ្រងដោយភាគីនីមួយៗ ដែលត្រូវតែបំពេញដោយឬសម្រាប់អ្នកនាំចេញឬអ្នកនាំចូល ទាក់ទងនឹងការនាំចេញឬនាំចូលទំនិញ។

## មាត្រា ១០.២ វិសាលភាព និងបទប្បញ្ញត្តិទូទៅ

១. ភាគីទាំងពីរ ទទួលស្គាល់ពីកំណើនសេដ្ឋកិច្ច និងកាលានុវត្តភាពពាណិជ្ជកម្មដែលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកផ្តល់ឱ្យ និងសារៈសំខាន់នៃការជំរុញនិងការសម្រួលការប្រើប្រាស់ និងការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករវាងភាគីទាំងពីរ។

២. គោលបំណងនៃជំពូកនេះគឺដើម្បីជំរុញកិច្ចសហប្រតិបត្តិការរវាងភាគីទាំងពីរ ទាក់ទងនឹងការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីរួមចំណែកដល់ការបង្កើតបរិយាកាសនៃជំនឿចិត្តនិងទំនុកចិត្ត ក្នុងការប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងដើម្បីលើកកម្ពស់ការប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឱ្យបានកាន់តែទូលំទូលាយទូទាំងសកលលោក។

៣. ជាគោលការណ៍ ភាគីទាំងពីរ នឹងប្រឹងប្រែងដើម្បីធានាបានថា ពាណិជ្ជកម្មទ្វេភាគីតាមរយៈពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មិនត្រូវបានរឹតបន្តឹងជាងពាណិជ្ជកម្មទ្វេភាគីមិនតាមប្រព័ន្ធអេឡិចត្រូនិកដែលមានភាពប្រហាក់ប្រហែលនោះទេ។

៤. ជំពូកនេះមិនត្រូវបានអនុវត្តចំពោះ៖

(ក) លទ្ធកម្មរដ្ឋាភិបាល ឬ

(ខ) ព័ត៌មានត្រូវបានរក្សាទុកឬដំណើរការដោយឬតំណាងឱ្យភាគីនីមួយៗ ឬវិធានការណ៍ទាក់ទងនឹងព័ត៌មានបែបនេះ រួមទាំងវិធានការណ៍ទាក់ទងនឹងការប្រមូលព័ត៌មាន។

## មាត្រា ១០.៣ ពន្ធគយ

១. ភាគីនីមួយៗ គួររក្សាការអនុវត្តការមិនដាក់ពន្ធគយលើការបញ្ជូនព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិករវាងភាគីទាំងពីរ ដែលអនុលោមតាមសេចក្តីសម្រេចថ្នាក់រដ្ឋមន្ត្រីរបស់អង្គការ WTO នាថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ ទាក់ទងនឹងកម្មវិធីការងារលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ((WT/MIN(17)/65))។

២. ភាគីនីមួយៗ រក្សាសិទ្ធិក្នុងការកែប្រែការអនុវត្តដែលមាននៅក្នុងកថាខណ្ឌ ១ អនុលោមតាមសេចក្តីសម្រេចថ្នាក់រដ្ឋមន្ត្រីរបស់អង្គការ WTO ទាក់ទងនឹងកម្មវិធីការងារលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

## មាត្រា ១០.៤ យថាភូតភាពអេឡិចត្រូនិក និងហត្ថលេខាអេឡិចត្រូនិក

១. គ្មានភាគីណាមួយអាចបដិសេធសុពលភាពស្របច្បាប់នៃហត្ថលេខាដោយផ្អែកលើមូលដ្ឋានថាហត្ថលេខាមានទម្រង់ជាអេឡិចត្រូនិកតែមួយមុខឡើយ លើកលែងតែក្នុងកាលៈទេសៈដែលមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិនៃភាគីនីមួយៗ។

២. ភាគីនីមួយៗ ត្រូវរក្សាច្បាប់និងវិធានការណ៍ក្នុងស្រុកសម្រាប់ហត្ថលេខាអេឡិចត្រូនិកដែលអនុញ្ញាតឱ្យៈ

(ក) អ្នកចូលរួមក្នុងប្រតិបត្តិការអេឡិចត្រូនិកធ្វើការកំណត់បច្ចេកវិទ្យាយថាភូតភាព និងគំរូអនុវត្តដែលសមស្រប សម្រាប់ប្រតិបត្តិការអេឡិចត្រូនិករបស់ពួកគេ និង

(ខ) អ្នកចូលរួមក្នុងប្រតិបត្តិការអេឡិចត្រូនិកមានឱកាសបញ្ជាក់ថាប្រតិបត្តិការអេឡិចត្រូនិករបស់ពួកគេ អនុលោមតាមច្បាប់និងប្បញ្ញត្តិក្នុងស្រុករបស់ភាគីនីមួយៗពាក់ព័ន្ធនឹងយថាភូតភាព។

៣. ភាគីនីមួយៗ ត្រូវបំពេញភារកិច្ចសំដៅការទទួលស្គាល់ទៅវិញទៅមកនៃលិខិតបញ្ជាក់ឌីជីថល និងហត្ថលេខាអេឡិចត្រូនិក។

៤. ភាគីនីមួយៗ ត្រូវជំរុញឱ្យមានការប្រើប្រាស់លិខិតបញ្ជាក់ឌីជីថលនៅក្នុងវិស័យឯកជន។

## មាត្រា១០.៥ កិច្ចការពារអ្នកប្រើប្រាស់តាមអនឡាញ

ក្នុងករណីដែលធ្វើទៅបាននិងមានលក្ខណៈសមស្រប ភាគីនីមួយៗត្រូវបង្កើតឬរក្សាវិធានការណ៍ដែលផ្តល់នូវកិច្ចការពារសម្រាប់អ្នកប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលយ៉ាងហោចណាស់មានលក្ខណៈដូចទៅនឹងវិធានការណ៍ដែលផ្តល់នូវកិច្ចការពារ សម្រាប់អ្នកប្រើប្រាស់ពាណិជ្ជកម្មក្រោមទម្រង់ផ្សេងៗទៀត។

## មាត្រា ១០.៦ កិច្ចការពារព័ត៌មានឯកជនតាមអនឡាញ

ដោយទទួលស្គាល់សារសំខាន់នៃកិច្ចការពារព័ត៌មានឯកជនក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ភាគីនីមួយៗត្រូវប្រើប្រាស់ឬរក្សាច្បាប់ក្នុងស្រុកនិងវិធានការណ៍ផ្សេងៗទៀតដែលធានាដល់កិច្ចការពារនៃព័ត៌មានឯកជននៃអ្នកប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

## មាត្រា ១០.៧ ពាណិជ្ជកម្មដោយពុំប្រើក្រដាសស្នាម

១. ភាគីនីមួយៗ ត្រូវប្រឹងប្រែងសំដៅទៅធ្វើឱ្យឯកសាររដ្ឋបាលពាណិជ្ជកម្ម បានទៅដល់សាធារណៈជនក្រោមទម្រង់អេឡិចត្រូនិក។

២. ភាគីនីមួយៗ ត្រូវប្រឹងប្រែងសំដៅទៅទទួលស្គាល់ទម្រង់អេឡិចត្រូនិកនៃឯកសាររដ្ឋបាលពាណិជ្ជកម្មឱ្យមានតម្លៃស្មើនឹងឯកសារជាក្រដាសក្នុងផ្លូវច្បាប់ លើកលែងតែៈ

(ក) ផ្ទុយទៅនឹងលក្ខខណ្ឌរបស់ច្បាប់ក្នុងស្រុកនិងច្បាប់អន្តរជាតិ ឬ

(ខ) ធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធិភាពនៃដំណើរការរដ្ឋបាលពាណិជ្ជកម្ម។

## មាត្រា ១០.៨ ឧបករណ៍បណ្តាញ

១. ភាគីទាំងពីរ ទទួលស្គាល់សារៈសំខាន់នៃឧបករណ៍បណ្តាញ និងផលិតផលទាក់ទងនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីធានាភាពរឹងមាំនៃការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

២. ភាគីទាំងពីរ ត្រូវប្រឹងប្រែងសំដៅទៅបង្កើតបរិយាកាសអំណោយផលដល់បណ្តាញទូរគមនាគមន៍សាធារណៈ បុគ្គលផ្តល់សេវា ឬបុគ្គលផ្តល់សេវាដែលមានតម្លៃបន្ថែម ដើម្បីមានឯករាជ្យភាពក្នុងការជ្រើសរើសឧបករណ៍បណ្តាញ ផលិតផល និងបច្ចេកវិទ្យា។

## មាត្រា ១០.៩ កិច្ចសហប្រតិបត្តិការលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

១. ភាគីទាំងពីរ យល់ព្រមចែករំលែកព័ត៌មាន និងបទពិសោធន៍ទាក់ទងនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក រួមមាន ច្បាប់និងបទប្បញ្ញត្តិ វិធាននិងស្តង់ដារ និងឧត្តមានុវត្តន៍។

២. ភាគីទាំងពីរ ត្រូវលើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តិការលើសកម្មភាពស្រាវជ្រាវនិងបណ្តុះបណ្តាលដើម្បីជំរុញការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

៣. ភាគីទាំងពីរ ត្រូវជំរុញការផ្លាស់ប្តូរធុរកិច្ច សកម្មភាពសហប្រតិបត្តិការ និងគម្រោងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករួមគ្នា។

៤. ភាគីទាំងពីរ ត្រូវចូលរួមយ៉ាងសកម្មក្នុងវេទិកាតំបន់និងពហុភាគី ដើម្បីលើកកម្ពស់ការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងលក្ខណៈសហប្រតិបត្តិការ។

## មាត្រា ១០.១០ ការមិនអនុវត្តការដោះស្រាយវិវាទ

គ្មានភាគីណាមួយអាចពឹងផ្អែកលើការដោះស្រាយវិវាទក្រោមជំពូក១៤ (ដោះស្រាយវិវាទ)សម្រាប់បញ្ហាណាក៏ដោយដែលកើតឡើងក្រោមជំពូកនេះ។

# ជំពូក ១១

# កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស

## មាត្រា ១១.១ កម្មវត្ថុ និងបញ្ញត្តិទូទៅ

១. គោលបំណងនៃជំពូកនេះគឺដើម្បីបង្កើតក្របខ័ណ្ឌមួយសម្រាប់លើកកម្ពស់សកម្មភាពពាណិជ្ជកម្ម វិនិយោគ និងសកម្មភាពទាក់ទងនឹងពាណិជ្ជកម្មដទៃទៀតដែលគាំទ្រគ្នាទៅវិញទៅមក តាមរយៈកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសក្រោមកិច្ចព្រមព្រៀងនេះ។

២. ភាគីទាំងពីរនឹងពង្រឹងសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស ដើម្បីរួមចំណែកដល់ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនៃកិច្ចព្រមព្រៀងនេះ និងការអនុវត្តជំពូកនានាក្រោមកិច្ចព្រមព្រៀងនេះ។

៣. ភាគីទាំងពីរព្រមព្រៀងអនុវត្តកម្មវិធីកសាងសមត្ថភាពនានា និងជំនួយបច្ចេកទេស ជាពិសេសសកម្មភាពរួម ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់លាក់ ដែលមានសង្គតភាពទៅនឹងវិស័យអាទិភាពនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស ក្រោមកិច្ចព្រមព្រៀងនេះ។

៤. ភាគីទាំងពីរទទួលស្គាល់កម្រិតខុសគ្នានៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់ភាគីនីមួយៗ និងព្រមព្រៀងប្រើប្រាស់ប្រភពហិរញ្ញវត្ថុដែលមានស្រាប់ ឬធនធានផ្សេងៗទៀតដែលអាចមាននាពេលអនាគតសម្រាប់សកម្មភាពសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសក្រោមកិច្ចព្រមព្រៀងនេះ ។

## មាត្រា ១១.២ វិសាលភាព និងវិស័យអាទិភាព

កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេសក្រោមជំពូកនេះនឹងគាំទ្រដល់ការអនុវត្ត និងប្រើប្រាស់កិច្ចព្រមព្រៀងនេះឱ្យមានប្រសិទ្ធិភាព ប្រសិទ្ធផល និងបរិយាប័ន្ន តាមរយៈការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងពាណិជ្ជកម្ម ឬវិនិយោគ រួមទាំងការកសាងសមត្ថភាព ជំនួយបច្ចេកទេស និងការគាំទ្រផ្នែកហិរញ្ញវត្ថុពីប្រភពនានាដែលអាចរកបាន ដោយផ្តោតលើចំណុចដូចខាងក្រោម៖

(ក) **ការជំរុញពាណិជ្ជកម្ម៖** ជំរុញ និងពង្រីកពាណិជ្ជកម្មជាបន្តបន្ទាប់តាមរយៈការលើកកម្ពស់ពាណិជ្ជកម្ម និងសកម្មភាពសម្របសម្រួល ការផ្លាស់ប្តូរ និងការផ្គូរផ្គងធុរកិច្ច។ ភាគីទាំងពីរនឹងបន្តពង្រឹងបន្ថែមនូវយន្តការរដ្ឋាភិបាលនិងរដ្ឋាភិបាល បង្កើនកិច្ចសហប្រតិបត្តិការលើវេទិកាផ្សេងៗ រួមមាន ពិព័រណ៌អន្តរជាតិផលិតផលនាំចូលចិន និងពិព័រណ៌ចិន-អាស៊ាន ចលនាភូមិមួយផលិតផល ក៏ដូចជាប្រើប្រាស់ឱ្យបានពេញលេញនូវតួនាទីរបស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានាដែលមានស្រាប់រវាងភាគីទាំងពីរក្នុងការលើកកម្ពស់ពាណិជ្ជកម្មទ្វេភាគី។

(ខ) **ពាណិជ្ជកម្មសេវាកម្ម៖** ភាគីទាំងពីរនឹងពង្រឹងកិច្ចខិតខំសហប្រតិបត្តិការនៅក្នុងវិស័យសេវាកម្មដែលត្រូវបានព្រមព្រៀងរួមគ្នា រួមមានប៉ុន្តែមិនមានកំណត់តែចំពោះ ការអភិវឌ្ឍធនធានមនុស្ស

ការស្រាវជ្រាវ និងការអភិវឌ្ឍ និងការកសាងសមត្ថភាពស្ថាប័ន ដើម្បីលើកកម្ពស់សមត្ថភាពក្នុងស្រុក ប្រសិទ្ធភាព និងភាពប្រកួតប្រជែងរបស់ពួកគេ។

(គ) **ការជំរុញទេសចរណ៍៖** ភាគីទាំងពីរនឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការលើការជំរុញ និងការផ្លាស់ប្តូរទេសចរណ៍ តាមរយៈការសន្ទនាជាប្រក្រតី និងការបង្កើតកម្មវិធីជំរុញ ដើម្បីពង្រីក និងធ្វើឱ្យស៊ីជម្រៅនៃវិស័យទេសចរណ៍ ដោយធ្វើការស្រាវជ្រាវពីផ្លូវ និងគំនិតផ្តួចផ្តើមផ្សេងៗ ដើម្បីធ្វើឱ្យរឹតតែមានភាពងាយស្រួលសម្រាប់អ្នកដំណើរ ប្រតិបត្តិករដំណើរកម្សាន្ត និងភ្នាក់ងារទេសចរណ៍។

(ឃ) **សហប្រតិបត្តិការឧស្សាហកម្ម៖** ភាគីទាំងពីរនឹងបង្កើនការធ្វើផែនការ និងការតភ្ជាប់នៃកិច្ចសហប្រតិបត្តិការឧស្សាហកម្មរវាងប្រទេសទាំងពីរ ព្រមទាំងអភិវឌ្ឍ និងអនុវត្តគម្រោងសក្តានុពលនានា និងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ក៏ដូចជាផ្តល់ជំនួយដើម្បីរក្សាបានការគាំទ្រដល់សហគ្រាសនានា ក្នុងតំបន់ដូចជា ការបង្កើតធុរកិច្ចថ្មីដោយជោគជ័យ ការអភិវឌ្ឍនវានុវត្តន៍ចំពោះសហគ្រាសធុនតូចនិងមធ្យម និងការបង្កើត និងប្រតិបត្តិនូវសួនឧស្សាហកម្ម ដើម្បីជួយឱ្យសហគ្រាសទាំងនោះលោតផ្លោះទៅកាន់ឧស្សាហកម្ម ៤.០។

(ង) **ការដឹកជញ្ជូន និងភស្តុភារកម្ម៖** ភាគីទាំងពីរនឹងបង្កើនកិច្ចសហប្រតិបត្តិការលើវិស័យដឹកជញ្ជូន និងភស្តុភារកម្មតាមផ្លូវគោក ផ្លូវអាកាស និងផ្លូវសមុទ្រ តាមរយៈការធ្វើឱ្យមានភាពសាមញ្ញ និងសុខដុមនីយកម្មបទប្បញ្ញត្តិស្តីពីការដឹកជញ្ជូន និងពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគុណភាពនៃសេវាកម្មភស្តុភារកម្ម គាំទ្រដល់ការអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែន (CBTA) នៃមហាអនុតំបន់មេគង្គ (GMS) ដើម្បីបង្កើនកម្រិតនៃការតភ្ជាប់រវាងប្រទេសទាំងពីរ។

(ច) **កសិកម្ម៖** ភាគីទាំងពីរនឹងបង្កើនការផ្លាស់ប្តូរជាន់ខ្ពស់ក្នុងវិស័យកសិកម្ម និងពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យអាទិភាព ដូចជា ការផ្លាស់ប្តូរស្ថាប័នស្រាវជ្រាវ និងបុគ្គលិកក្នុងវិស័យកសិកម្ម ការអភិវឌ្ឍធនធានមនុស្ស ជំរុញការធ្វើពាណិជ្ជកម្មលើផលិតផលកសិកម្មតាមរយៈការសម្រួលនីតិវិធីនាំចូល-នាំចេញ និងការបង្កើតវេទិកានានាសម្រាប់សហគ្រាសកសិកម្ម និងជំរុញកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មកសិកម្ម។

(ឆ) **វិធានមិនមែនពន្ធគយ៖** ភាគីទាំងពីរនឹងលើកកម្ពស់តម្លាភាពនៃច្បាប់ បទប្បញ្ញត្តិទាក់ទងនឹងពាណិជ្ជកម្ម នីតិវិធីនាំចេញនាំចូល និងគោលនយោបាយពាណិជ្ជកម្មដោយដាក់ឱ្យរកបានឯកសារទាំងនោះតាមអនឡាញ ដើម្បីសម្រួលដល់នីតិវិធីឆ្លងកាត់ព្រំដែន និងបន្សុីគ្នានូវវិធានការសម្រួលពាណិជ្ជកម្មឱ្យស្របតាមឧត្តមានុវត្តន៍អន្តរជាតិ។

(ជ) **បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍៖** ភាគីទាំងពីរនឹងជំរុញកិច្ចសហប្រតិបត្តិការលើវិស័យព័ត៌មាននិងទូរគមនាគមន៍ និងនវានុវត្តន៍តាមរយៈការផ្លាស់ប្តូរបុគ្គលិក កិច្ចសហប្រតិបត្តិការក្នុងការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងការអភិវឌ្ឍធនធានមនុស្ស។

(ញ) ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក៖ ភាគីទាំងពីរនឹងសហការគ្នាក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកលើផ្នែកដូចជាការសិក្សារួម ការបង្កើតក្របខ័ណ្ឌ និងការអនុវត្តច្បាប់ ការចែករំលែកបទពិសោធន៍ក្នុងការធ្វើគោលនយោបាយ និងការគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដោយរដ្ឋាភិបាល ការពង្រឹងសមត្ថភាពសម្រាប់អ្នកផ្គត់ផ្គង់ឱ្យចូលទីផ្សារដោយផ្ទាល់។

(ដ) វិស័យផ្សេងៗទៀតដូចដែលភាគីទាំងពីរបានឯកភាពគ្នា។

## មាត្រា ១១.៣ កម្មវិធីការងារ

១. ដោយពិចារណាលើវិស័យអាទិភាពនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស កម្មវិធីការងារនឹងត្រូវបង្កើតឡើងដោយគណៈកម្មការសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស ដោយមានការពិគ្រោះយោបល់ជាមួយគណៈកម្មការដទៃទៀត ដែលបានបង្កើតឡើងក្រោមកិច្ចព្រមព្រៀងនេះ។

២. ដើម្បីលើកទឹកចិត្តដល់ការអនុវត្ត និងការប្រើប្រាស់កិច្ចព្រមព្រៀងនេះប្រកបដោយប្រសិទ្ធភាព អាទិភាពនឹងត្រូវផ្តល់សម្រាប់សកម្មភាពរួម ដែលផ្តោតលើការពង្រឹងសមត្ថភាព និងជំនួយបច្ចេកទេស និងជំនួយហិរញ្ញវត្ថុពីធនធានដែលមាននៅក្នុងវិស័យនានា ដែលបានព្រមព្រៀងដោយភាគីទាំងពីរ។

៣. កម្មវិធីការងារអាចធ្វើការកែសម្រួលដោយគណៈកម្មការនៅពេលដែលចាំបាច់ និងត្រូវមានការយល់ព្រមពីភាគីទាំងពីរ។

## មាត្រា ១១.៤ គណៈកម្មការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេស

១. សម្រាប់គោលបំណងនៃការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃជំពូកនេះ ភាគីទាំងពីរនឹងបង្កើតគណៈកម្មាធិការមួយសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស ដែលមានតំណាងរដ្ឋាភិបាលនៃភាគីនីមួយៗ។

២. គណៈកម្មាធិការនឹងបង្កើត និងសម្របសម្រួលកម្មវិធីការងារ និងយន្តការអនុវត្តន៍ ព្រមទាំងធ្វើការជាមួយគណៈកម្មាធិការដទៃទៀត ដើម្បីបង្កើត និងរក្សាទំនាក់ទំនង និងសម្របសម្រួលប្រកបដោយប្រសិទ្ធភាពលើសកម្មភាពសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស និងបញ្ហាពាក់ព័ន្ធ។ គណៈកម្មាធិការត្រូវពិនិត្យវឌ្ឍនភាពនៃកម្មវិធីការងារ និងផ្តល់អនុសាសន៍ក្នុងករណីចាំបាច់ សម្រាប់ធ្វើការកែលម្អការអនុវត្តសកម្មភាពរួម។

៣. ភាគីនីមួយៗនឹងចាត់តាំងមន្ត្រីពាក់ព័ន្ធជាមន្ត្រីទំនាក់ទំនង សម្រាប់សម្របសម្រួលការអនុវត្តកម្មវិធីការងារ បន្ទាប់ពីកិច្ចព្រមព្រៀងនេះត្រូវបានចូលជាធរមាន។ ភាគីនីមួយៗនឹងផ្តល់ព័ត៌មានទំនាក់ទំនងលម្អិតរបស់មន្ត្រីពាក់ព័ន្ធនៅក្នុងមន្ត្រីទំនាក់ទំនងរៀងៗខ្លួន ហើយជូនដំណឹងជាបន្ទាន់ប្រសិនបើមានការផ្លាស់ប្តូរមន្ត្រីទំនាក់ទំនងរបស់ខ្លួន ឬការផ្លាស់ប្តូរណាមួយចំពោះព័ត៌មានលម្អិតរបស់មន្ត្រីពាក់ព័ន្ធដែលជួសមុខឱ្យអ្នកទំនាក់ទំនងរបស់ខ្លួន។

## មាត្រា ១១.៥ ការមិនអនុវត្តការដោះស្រាយវិវាទ

គ្មានភាគីណាមួយអាចពឹងផ្អែកលើការដោះស្រាយវិវាទក្រោមជំពូក១៤ (ដោះស្រាយវិវាទ)សម្រាប់បញ្ហាណាក៏ដោយដែលកើតឡើងក្រោមជំពូកនេះ។

# ជំពូក ១២
# តម្លាភាព

## មាត្រា ១២.១ ការបោះពុម្ពផ្សាយ

១. ភាគីនីមួយៗត្រូវធានាថា ច្បាប់ បទប្បញ្ញត្តិ នីតិវិធី និងសេចក្តីសម្រេចរដ្ឋបាលនានា សម្រាប់ការអនុវត្តទូទៅពាក់ព័ន្ធនឹងបញ្ហាទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបោះពុម្ពផ្សាយយ៉ាងឆាប់រហ័ស រាប់បញ្ចូលទាំងនៅលើអ៊ីនធឺណិតក្នុងករណីដែលអាចធ្វើទៅបាន ឬក្នុងទម្រង់ណាមួយដែលអាចឱ្យបុគ្គលពាក់ព័ន្ធនិងភាគីមួយទៀតនៃកិច្ចព្រមព្រៀងនេះ បានដឹង ពីច្បាប់ បទប្បញ្ញត្តិ នីតិវិធី និងវិធានរដ្ឋបាលទាំងនេះ។

២. ក្នុងករណីដែលអាចធ្វើទៅបាន និងអាចអនុវត្តបាន និងដោយយោងលើកាលៈទេសៈនៃច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុក ភាគីនីមួយៗត្រូវ ៖

ក. បោះពុម្ពផ្សាយជាមុន នូវច្បាប់ បទប្បញ្ញត្តិ នីតិវិធី និងសេចក្តីសម្រេចរដ្ឋបាលសម្រាប់ការអនុវត្តទូទៅពាក់ព័ន្ធនឹងបញ្ហាទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ដែលខ្លួនរៀបចំអនុម័ត និង

ខ. ក្នុងកាលៈទេសៈសមស្រប ផ្តល់ឱ្យបុគ្គលពាក់ព័ន្ធ និងភាគីមួយទៀតនៃកិច្ចព្រមព្រៀងនេះ នូវឱកាស សមរម្យ ក្នុងការផ្តល់មតិយោបល់លើច្បាប់ បទប្បញ្ញត្តិ នីតិវិធី និងសេចក្តី សម្រេចរដ្ឋបាលសម្រាប់ការអនុវត្តទូទៅពាក់ព័ន្ធនឹងបញ្ហាទាំងឡាយដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ។

## មាត្រា ១២.២ ការជូនដំណឹង និងការផ្តល់ព័ត៌មាន

១. ក្នុងករណីដែលអាចធ្វើទៅបាន និងអាចអនុវត្ត និងដោយយោងលើកាលៈទេសៈនៃច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុក ភាគីនីមួយៗ ត្រូវជូនដំណឹងទៅភាគីមួយទៀតនៃកិច្ចព្រមព្រៀងនេះ អំពីវិធានការដែលត្រូវបានស្នើឡើង ឬវិធានការដាក់ស្តែងដែលភាគីមួយទៀតគិតថាអាចប៉ះពាល់ យ៉ាងខ្លាំងដល់ប្រតិបត្តិការកិច្ចព្រមព្រៀងនេះ ឬដល់ផលប្រយោជន៍ស្របច្បាប់របស់ភាគីមួយទៀត ក្រោមកិច្ចព្រមព្រៀងនេះ។

២. ក្នុងករណីដែលអាចធ្វើទៅបាន និងអាចអនុវត្តបាន តបតាមសំណើរបស់ភាគីមួយទៀត ក្នុងអំឡុងពេល ៣០ ថ្ងៃ បន្ទាប់ពីបានទទួលសំណើ ភាគីមួយត្រូវផ្តល់ព័ត៌មាន និងឆ្លើយតបទៅនឹងសំណួរដែលទាក់ទងទៅនឹងវិធានការដែលត្រូវបានស្នើឡើងឬវិធានការដាក់ស្តែងដែលភាគីមួយទៀតគិតថាអាចប៉ះពាល់ដល់យ៉ាងខ្លាំងដល់ប្រតិបត្តិការកិច្ចព្រមព្រៀងនេះ បើទោះបីជា ភាគីមួយទៀតបាន ឬមិនបានជូនដំណឹងអំពីវិធានការនោះ ជាមុនក៏ដោយ។

៣. ព័ត៌មានដែលបានលើកឡើងក្នុងមាត្រានេះ ត្រូវចាត់ទុកថាបានផ្ដល់ជូនរួច នៅពេលដែលព័ត៌មានទាំងនេះ ត្រូវបានជូនដំណឹងទៅអង្គការ WTO ឬនៅពេលដែលវាអាចរកបាននៅលើគេហទំព័រផ្លូវការរបស់ភាគីពាក់ព័ន្ធដែលអាចចូលមើលបានជាសាធារណៈ ។

៤. ការជូនដំណឹង ការស្នើសុំ ឬព័ត៌មាននានា នៅក្នុងមាត្រានេះ ត្រូវបញ្ជូនទៅភាគីមួយទៀតតាមរយៈមន្ត្រីទំនាក់ទំនងនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា ១២.៣ ដំណើរការនីតិវិធីរដ្ឋបាល

១. ភាគីនីមួយៗ ត្រូវធានាថា ច្បាប់ បទប្បញ្ញត្តិ នីតិវិធី និងសេចក្ដីសម្រេចរដ្ឋបាលសម្រាប់ការអនុវត្តទូទៅទាំងឡាយដែលស្ថិតក្រោមវិសាលភាពនៃកិច្ចព្រមព្រៀងនេះ ត្រូវបានគ្រប់គ្រងក្នុងទម្រង់ប្រកបដោយសង្គតិភាព មិនលម្អៀង ច្បាស់លាស់ និងសមហេតុផល។

២. ដើម្បីគ្រប់គ្រងច្បាប់ បទប្បញ្ញត្តិ នីតិវិធី និងសេចក្ដីសម្រេចរដ្ឋបាលសម្រាប់ការអនុវត្តទូទៅពាក់ព័ន្ធនឹងបញ្ហាទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ប្រកបដោយសង្គតិភាព មិនលម្អៀង ច្បាស់លាស់ និងសមហេតុផល នៅក្នុងកិច្ចដំណើរការនីតិវិធីរដ្ឋបាលដោយអនុវត្តនូវវិធានការទាំងនេះចំពោះបុគ្គល ទំនិញ ឬសេវាកម្មណាមួយរបស់ភាគីមួយទៀត ភាគីនីមួយៗត្រូវធានាថា ៖

(ក) ក្នុងករណីដែលអាចធ្វើទៅបាន បុគ្គលនៃភាគីម្ខាងទៀតដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ពីដំណើរការនីតិវិធីរដ្ឋបាលនេះ ទទួលបាននូវការជូនដំណឹងសមស្រប ដោយអនុលោមតាមនីតិវិធីក្នុងស្រុករបស់ខ្លួន នៅពេលដំណើរការនោះបានចាប់ផ្ដើម រួមទាំង សេចក្ដីពណ៌នាអំពីលក្ខណៈនៃដំណើរការនីតិវិធី សេចក្ដីបញ្ជាក់របស់អាជ្ញាធរច្បាប់ដែលអនុវត្តដំណើរការនីតិវិធី និងសេចក្ដីពណ៌នាជាទូទៅនៃបញ្ហាដែលកំពុងកើតមាន។

(ខ) បុគ្គលខាងលើនេះ ត្រូវបានផ្ដល់ឱកាសសមស្រប ដើម្បីបង្ហាញពីអង្គហេតុ និងអំណះ អំណាងក្នុងការគាំទ្រដល់ជំហររបស់ពួកគេ នៅមុនសកម្មភាពរដ្ឋបាលស្ថាពរណាមួយ ប្រសិនបើពេលវេលា ចរិកលក្ខណៈ និងផលប្រយោជន៍សាធារណៈ អាចអនុញ្ញាតធ្វើបែបនោះ។

(គ) ភាគីនោះ អនុវត្តតាមនីតិវិធីដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន។

## មាត្រា ១២.៤ ការពិនិត្យឡើងវិញ និងឧបាស្រ័យ

១. ភាគីនីមួយៗ ត្រូវបង្កើត ឬរក្សាទុកនូវសាលាជម្រះក្ដីតាមប្រព័ន្ធតុលាការ ប្រព័ន្ធប្រហាក់ប្រហែលតុលាការ ឬតាមប្រព័ន្ធរដ្ឋបាល ឬនីតិវិធីសម្រាប់ការពិនិត្យឡើងវិញជាបន្ទាន់ និងការកែតម្រូវនៃសកម្មភាពរដ្ឋបាលស្ថាពរនានាពាក់ព័ន្ធនឹងបញ្ហានានាដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ បើមានការទាមទារ។ សាលាជម្រះក្ដីទាំងនេះ ត្រូវមិនលម្អៀង និងមានភាពឯករាជ្យ ដាច់ពីអង្គភាព ឬអាជ្ញាធរដែលត្រូវបានប្រគល់សិទ្ធិឱ្យអនុវត្តនីតិវិធីរដ្ឋបាល ហើយមិនត្រូវមានផលប្រយោជន៍ជាដុំកំភួនលើសេចក្ដីសម្រេចនៃបញ្ហាទាំងនេះឡើយ។

២. ភាគីនីមួយៗ ត្រូវធានាថា នៅក្នុងសាលាជម្រះក្តី ឬនីតិវិធីខាងលើ ភាគីវិវាទនីមួយៗក្នុងដំណើរការនីតិវិធីត្រូវបានផ្តល់ជូននូវសិទ្ធិទទួលបាន៖

(ក) ឱកាសសមស្រប ក្នុងការគាំទ្រ ឬការពារជំហររបស់ខ្លួន និង

(ខ) សេចក្តីសម្រេច ដែលផ្អែកលើភស្តុតាង និងការដាក់កំណត់ហេតុនានា ឬក្នុងករណីតម្រូវដោយច្បាប់របស់ភាគី កំណត់ត្រាដែលចងក្រងដោយអាជ្ញាធររដ្ឋបាល។

៣. ក្រោមលក្ខខណ្ឌឧបាស្រ័យ ឬការពិនិត្យឡើងវិញដូចដែលមានចែងក្នុងច្បាប់របស់ខ្លួន ភាគីនីមួយៗត្រូវធានាថាសេចក្តីសម្រេចនេះ ត្រូវបានអនុវត្តដោយ និងត្រូវគ្រប់គ្រងចំពោះការអនុវត្ត របស់អង្គភាព ឬអាជ្ញាធរពាក់ព័ន្ធនឹងសកម្មភាពរដ្ឋបាលដែលជាកម្មវត្ថុ។

# ជំពូក ១៣
# បទប្បញ្ញត្តិស្តីពីរដ្ឋបាល និងស្ថាប័ន

## មាត្រា ១៣.១ ការបង្កើតគណៈកម្មការរួមនៃតំបន់ពាណិជ្ជកម្មសេរីកម្ពុជា-ចិន

ភាគីទាំងពីរ បង្កើតគណៈកម្មការរួមនៃតំបន់ពាណិជ្ជកម្មសេរីកម្ពុជា-ចិន ហៅកាត់ថា "គណៈកម្មការរួម" ដែលមានអ្នកតំណាងមកពី ភាគីទាំងពីរ ដូចខាងក្រោម៖

(ក)ក្នុងករណីភាគីចិន ក្រសួងពាណិជ្ជកម្ម (MOFCOM); និង

(ខ)ក្នុងករណីភាគីកម្ពុជា ក្រសួងពាណិជ្ជកម្ម (MOC)។

## មាត្រា ១៣.២ មុខងាររបស់គណៈកម្មការរួម

១. គណៈកម្មការរួមត្រូវ៖

(ក)ពិនិត្យឡើងវិញ តាមដាន ពិនិត្យមើល មើលការខុសត្រូវ និងសម្របសម្រួលការអនុវត្ត និងប្រតិបត្តិការនៃកិច្ចព្រមព្រៀងនេះ និងលិខិតូបករណ៍គតិយុត្តទាំងអស់ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងនេះ

(ខ)ពិចារណា និងផ្តល់អនុសាសន៍ ចំពោះការធ្វើវិសោធនកម្មនានាលើកិច្ចព្រមព្រៀងនេះ និងលិខិតូបករណ៍គតិយុត្តទាំងអស់ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងនេះ

(គ)ចរចាលើការធ្វើវិសោធនកម្ម ឬបញ្ហាណាមួយដែលកើតឡើងពីប្រតិបត្តិការនៃកិច្ចព្រមព្រៀងនេះ និងរាល់លិខិតូបករណ៍គតិយុត្តនានាដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀង នេះ;

(ឃ)មើលការខុសត្រូវ និងសម្របសម្រួលការងាររបស់គណៈកម្មាធិការជំនាញក្រោមកិច្ចព្រមព្រៀង នេះ និងរាល់លិខិតូបករណ៍គតិយុត្តនានាដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀង នេះ;

(ង)អនុម័ត ក្នុងករណីសមស្រប សេចក្តីសម្រេច និងអនុសាសន៍នានារបស់គណៈកម្មាធិការ ជំនាញស្របតាមកិច្ចព្រមព្រៀងនេះ និងលិខិតូបករណ៍គតិយុត្តទាំងអស់ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងនេះ

(ច)ពិចារណាបញ្ហាផ្សេងទៀតដែលអាចប៉ះពាល់ដល់ប្រតិបត្តិការនៃកិច្ចព្រមព្រៀងនេះ និងរាល់លិខិតូបករណ៍គតិយុត្តនានាដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងនេះ ឬដែលត្រូវបានប្រគល់ឱ្យដោយភាគីទាំងពីរ និង

(ឆ)អនុវត្តមុខងារផ្សេងទៀតដូចដែលភាគីទាំងពីរអាចយល់ព្រម។

## មាត្រា ១៣.៣ វិធាននីតិវិធីនៃគណៈកម្មការរួម

១. គណៈកម្មការរួម នឹងកោះប្រជុំជាលើកដំបូងក្នុងអំឡុងពេលមួយឆ្នាំ ចាប់ពីការចូលជាធរមាន នៃកិច្ចព្រមព្រៀងនេះ និងកិច្ចប្រជុំបន្តបន្ទាប់ទៀត យ៉ាងហោចរៀងរាល់ពីរឆ្នាំម្តង ដោយទៀងទាត់ ឬអាចត្រូវបានកំណត់ដោយភាគីទាំងពីរ។

២. នៅពេលមានកាលៈទេសៈពិសេសកើតឡើង តបតាមការស្នើសុំរបស់ភាគីម្ខាងទៀត ភាគីទាំងពីរត្រូវជួបប្រជុំនៅពេលណាក៏បាន តាមការព្រមព្រៀងពីភាគីទាំងពីរ។

៣. ការប្រជុំទៀងទាត់នៃគណៈកម្មការរួម ត្រូវធ្វើឡើងជាប្រចាំ នៅលើទឹកដីនៃភាគីនីមួយៗ ដោយឆ្លាស់វេនគ្នា ហើយត្រូវដឹកនាំដោយភាគីនីមួយៗដោយបន្តពីគ្នា។

## មាត្រា ១៣.៤ ការបង្កើតគណៈកម្មាធិការ

១. គណៈកម្មាធិការខាងក្រោម ត្រូវបានបង្កើតឡើងក្រោមការគ្រប់គ្រងរបស់គណៈកម្មការរួម ៖

(ក)គណៈកម្មាធិការពាណិជ្ជកម្មទំនិញ

(ខ)គណៈកម្មាធិការពាណិជ្ជកម្មសេវាកម្ម

(គ)គណៈកម្មាធិការវិធានប្រភពដើមទំនិញ

(ឃ)គណៈកម្មាធិការនីតិវិធីគយ និងកិច្ចសម្រួលពាណិជ្ជកម្ម

(ង)គណៈកម្មាធិការវិធានការអនាម័យនិង និងភូតគាមអនាម័យ

(ច)គណៈកម្មាធិការកិច្ចសហប្រតិបត្តិការវិនិយោគ

(ឆ)គណៈកម្មាធិការ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស។

២. ការសម្រេចទាំងអស់ដែលធ្វើឡើងដោយគណៈកម្មាធិការត្រូវទទួលការអនុម័តដោយគណៈកម្មការរួម។

៣. គណៈកម្មាធិការ ត្រូវកោះប្រជុំជាទៀងទាត់រៀងរាល់ ២ ឆ្នាំម្តង ក្នុងពេលតែមួយជាមួយគណៈកម្មការរួមកោះប្រជុំ។ នៅពេលមានកាលៈទេសៈពិសេសកើតឡើង ភាគីទាំងពីរត្រូវជួប ប្រជុំគ្នានៅពេលណាក៏បាន តាមការព្រមព្រៀងតបតាមសំណើរបស់ភាគីមួយ។ ការប្រជុំទៀងទាត់ នៃគណៈកម្មាធិការជំនាញ ត្រូវដឹកនាំដោយភាគីនីមួយៗដោយបន្តពីគ្នា។ កិច្ចប្រជុំផ្សេងទៀត នៃគណៈកម្មាធិការជំនាញ ត្រូវដឹកនាំដោយភាគីដែលធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំនេះ។

## មាត្រា ១៣.៥ មុខងាររបស់គណៈកម្មាធិការ

គណៈកម្មាធិការត្រូវអនុវត្តដូចខាងក្រោម ៖

(ក)ធានានូវភាពត្រឹមត្រូវក្នុងការប្រតិបត្តិមុខងារនៃជំពូកនីមួយៗនៅក្នុងកិច្ចព្រមព្រៀងនេះ និង ដោះស្រាយបញ្ហាដែលកើតឡើងពីការអនុវត្តក្នុងផ្នែកនីមួយៗ

(ខ)ពិនិត្យឡើងវិញនូវការបកស្រាយ និងការអនុវត្តជំពូកនីមួយៗ

(គ)កំណត់ផ្នែកដែលត្រូវធ្វើឱ្យប្រសើរឡើងនៃជំពូកនីមួយៗនៅក្នុងកិច្ចព្រមព្រៀងនេះ

(ឃ)ផ្តល់អនុសាសន៍ និងរាយការណ៍ទៅគណៈកម្មការរួម

(ង)អនុវត្តមុខងារផ្សេងៗទៀតដូចដែលត្រូវបានធ្វើប្រតិភូកម្មដោយគណៈកម្មការរួម។

# ជំពូក ១៤

# ការដោះស្រាយវិវាទ

## មាត្រា ១៤.១ កិច្ចសហប្រតិបត្តិការ

ភាគីទាំងពីរត្រូវខិតខំគ្រប់ពេលវេលាក្នុងការឯកភាពលើការបកស្រាយ និងអនុវត្តន៍កិច្ចព្រមព្រៀងនេះ និងត្រូវព្យាយាមសហការរកដំណោះស្រាយរួម ចំពោះបញ្ហានានាដែលបង្កផលប៉ះពាល់ដល់ប្រតិបត្តិការកិច្ចព្រមព្រៀងនៅពេលវិវាទកើតឡើង។

## មាត្រា ១៤. ២ វិសាលភាពនៃការអនុវត្ត

លើកលែងតែត្រូវបានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ រាល់វិធានការទាំងឡាយដែលត្រូវបានអនុម័តដោយភាគីណាមួយ ហើយមិនអនុលោមតាមកាតព្វកិច្ចនៅក្រោមកិច្ចព្រមព្រៀងនេះ ឬប្រសិនបើភាគីណាមួយខកខានបំពេញកាតព្វកិច្ចរបស់ខ្លួន នៅក្រោមកិច្ចព្រមព្រៀងនេះ បទប្បញ្ញត្តិស្តីពីការដោះស្រាយវិវាទនៃជំពូកនេះត្រូវអនុវត្ត។

បទប្បញ្ញត្តិស្តីពីការដោះស្រាយវិវាទនៃកិច្ចព្រមព្រៀងនេះ ត្រូវយកមកប្រើប្រាស់ចំពោះវិធានការ ដែលប៉ះពាល់ដល់ប្រតិបត្តិការរបស់ភាគីមួយធ្វើឡើងដោយរដ្ឋាភិបាលមូលដ្ឋាន ឬក៏អាជ្ញាធរមូលដ្ឋាននៃភាគីមួយទៀត។

## មាត្រា ១៤.៣ ជម្រើសនៃវេទិកា

១. នៅពេលមានវិវាទមួយកើតឡើងក្រោមកិច្ចព្រមព្រៀងនេះ និងក្រោមកិច្ចព្រមព្រៀងផ្សេងទៀតណាមួយ ដែលភាគីទាំងពីរទាំងពីរជាភាគី រួមមានកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មពិភពលោក ភាគីតវ៉ាអាចធ្វើបណ្តឹងទៅតាមនីតិវិធីដោះស្រាយវិវាទដែលមានស្រាប់នៅក្នុងកិច្ចព្រមព្រៀងណាមួយ ដើម្បីដោះស្រាយវិវាទ។

២. នៅពេលដែលភាគីតវ៉ាបានស្នើសុំបង្កើតគណៈកម្មការ ឬសាលាជម្រះក្តី ក្រោមកិច្ចព្រមព្រៀងណាមួយដូចដែលមានចែងនៅក្នុងកថាខណ្ឌ១ វេទិកាដែលបានជ្រើសរើសនោះ គឺជាវេទិកាចុងក្រោយហើយតែមួយគត់ដែលមានយុត្តាធិការ។

## មាត្រា ១៤.៤ ការពិគ្រោះយោបល់

១. ភាគីទាំងពីរត្រូវខិតខំប្រឹងប្រែងដោះស្រាយវិវាទ តាមរយៈការពិគ្រោះយោបល់ដែលមានចែងនៅក្រោមមាត្រានេះ ដើម្បីបានដំណោះស្រាយដែលអាចទទួលយកបានទាំងអស់គ្នា។

២. សំណើសុំការពិគ្រោះយោបល់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវបញ្ជាក់ពីមូលហេតុនៃការស្នើសុំ រួមទាំងការកំណត់អត្តសញ្ញាណនៃវិធានការដែលមានបញ្ហា និងការចង្អុលបង្ហាញ អំពីមូលដ្ឋានគតិយុត្ត

សម្រាប់បណ្តឹងផងដែរ។ ភាគីតវ៉ាត្រូវបញ្ជូនសំណើសុំទៅភាគីឆ្លើយតប។ នៅពេលទទួលបានសំណើសុំ ភាគីឆ្លើយតបត្រូវជូនដំណឹងថាបានទទួលសំណើសុំទៅភាគីតវ៉ា ឬក៏នៅថ្ងៃដែលសំណើសុំដែលត្រូវបានធ្វើឡើងត្រូវបានចាត់ទុកថាជាថ្ងៃដែលភាគីឆ្លើយតបបាន ទទួលសំណើសុំ។

៣. ប្រសិនបើសំណើសុំការពិគ្រោះយោបល់ត្រូវបានធ្វើឡើង ភាគីឆ្លើយតបត្រូវឆ្លើយតបទៅនឹងសំណើសុំក្នុងរយៈពេល ២០ ថ្ងៃ បន្ទាប់ពីថ្ងៃដែលទទួលសំណើសុំ និងត្រូវចាប់ផ្តើមចូលការពិគ្រោះយោបល់ដោយស្មោះត្រង់ ជាមួយនឹងគោលបំណងឈានដល់ដំណោះស្រាយមួយដែលអាចទទួលយកបានទាំងសងខាងក្នុងរយៈពេលមួយមិនលើសពី៖

(ក)២០ ថ្ងៃ បន្ទាប់ពីថ្ងៃនៃការទទួលបានសំណើសុំ សម្រាប់បញ្ហាបន្ទាន់ដែលទាក់ទងនឹងទំនិញងាយខូច ឬ

(ខ)៣០ ថ្ងៃ បន្ទាប់ពីថ្ងៃនៃការទទួលបានសំណើសុំ សម្រាប់គ្រប់បញ្ហាទាំងអស់។

៤. ការពិគ្រោះយោបល់នឹងត្រូវរក្សាជាការសម្ងាត់ និងដោយពុំមានប៉ះពាល់ដល់សិទ្ធិនៃភាគីណា មួយនៅក្នុងកិច្ចដំណើរការនីតិវិធីណាមួយនាពេលខាងមុខឡើយ។

៥. ប្រសិនបើភាគីឆ្លើយតបមិនបានឆ្លើយតប ឬមិនចាប់ផ្តើមការពិគ្រោះយោបល់ក្នុងរយៈពេលដែលបានកំណត់ក្នុងកថាខណ្ឌ ៣ ភាគីតវ៉ាអាចប្តឹងដោយផ្ទាល់ដើម្បីស្នើសុំបង្កើតវេទិកាមជ្ឈត្តកម្ម មួយ។

## មាត្រា ១៤.៥ អន្តរការី ការផ្សះផ្សា និងសន្ធានកម្ម

១.នៅគ្រប់ពេលទាំងអស់ ភាគីទាំងពីរអាចព្រមព្រៀងគ្នាដោយស្ម័គ្រចិត្តធ្វើការសម្របសម្រួល ការផ្សះផ្សា និងសន្ធានកម្ម។ នីតិវិធីទាំងនេះ អាចចាប់ផ្តើមនៅពេលវេលាណាមួយ និងអាចត្រូវបានបញ្ចប់នៅគ្រប់ពេលដោយរួមទាំងពេលដែលដំណើរការនីតិវិធីអាជ្ញាកណ្តាលកំពុងដំណើរការផងដែរ។

២.ដំណើរការដែលពាក់ព័ន្ធនឹងការសម្របសម្រួល ការផ្សះផ្សា និងសន្ធានកម្ម និងក្នុងស្ថានភាព ពិសេសដែលធ្វើឡើងដោយភាគីទាំងពីរក្នុងអំឡុងពេលដំណើរការនីតិវិធីទាំងនោះ នឹងត្រូវរក្សាជាការសម្ងាត់ និងដោយពុំមានប៉ះពាល់ដល់សិទ្ធិនៃភាគីណាមួយនៅក្នុងកិច្ចដំណើរការនីតិវិធីណាមួយ ឬដំណើរការផ្សេងនៅពេលខាងមុខឡើយ។

## មាត្រា ១៤.៦ ការបង្កើតវេទិកាមជ្ឈត្តកម្ម

១. ករណីការពិគ្រោះយោបល់ដែលមានចែងនៅក្នុងមាត្រា ១៤.៤ (ការពិគ្រោះយោបល់) មិនអាចដោះស្រាយបញ្ហាបាន ក្នុងរយៈពេល ៦០ ថ្ងៃ ឬ ៣០ ថ្ងៃ ក្នុងករណីបញ្ហាបន្ទាន់ដែលទាក់ទងនឹងទំនិញងាយខូច បន្ទាប់ពី ទទួលបានសំណើសុំការពិគ្រោះយោបល់ ភាគីតវ៉ាអាចស្នើសុំជាលាយលក្ខណ៍អក្សរឱ្យបង្កើតវេទិកាមជ្ឈត្តកម្ម ដើម្បីពិចារណាលើបញ្ហានេះ។

២. ភាគីតវ៉ាត្រូវបញ្ជាក់នៅក្នុងសំណើសុំរបស់ខ្លួន ថាតើការពិគ្រោះយោបល់ត្រូវបានរៀបចំឡើង ឬមិនត្រូវបានរៀបចំឡើង ចង្អុលបង្ហាញនូវវិធានការដែលមានបញ្ហា និងផ្តល់នូវសេចក្តីសង្ខេបលើ អង្គច្បាប់នៃបណ្តឹង

ឱ្យបានគ្រប់គ្រាន់ ដើម្បីបង្ហាញឱ្យបានជាក់លាក់នូវបញ្ហា និងត្រូវបញ្ជូនសំណើ ទៅភាគីឆ្លើយតប។ វេទិកាមជ្ឈត្តកម្មត្រូវបានបង្កើតឡើងនៅពេលទទួលបានសំណើសុំ។

៣. ភាគីឆ្លើយតបត្រូវជូនដំណឹង ថាបានទទួលសំណើសុំបង្កើតវេទិកាមជ្ឈត្តកម្មដែលធ្វើឡើងដោយអនុលោមនឹងកថាខណ្ឌ ៥ នៃមាត្រា ១៤.៤ (ការពិគ្រោះយោបល់) និងកថាខណ្ឌ ១ នៃមាត្រានេះ ដែលបញ្ជាក់ពីថ្ងៃដែលសំណើសុំត្រូវបានទទួល បើមិនដូច្នោះទេ នៅថ្ងៃដែលសំណើសុំដែលត្រូវបានធ្វើឡើងត្រូវបានចាត់ទុកថាជាថ្ងៃដែលភាគីឆ្លើយតបបានទទួលសំណើសុំ។

## មាត្រា ១៤.៧ សមាសភាពនៃវេទិកាមជ្ឈត្តកម្ម

១. វេទិកាមជ្ឈត្តកម្មត្រូវមានសមាជិក ៣ រូប។

២. ក្នុងរយៈពេល ១៥ ថ្ងៃ បន្ទាប់ពីបង្កើតវេទិកាមជ្ឈត្តកម្ម ភាគីនីមួយៗត្រូវតែងតាំងមជ្ឈត្តករមួយរូបនៃវេទិកាមជ្ឈត្តកម្មនីមួយៗ។

៣. ភាគីទាំងពីរត្រូវតែងតាំងដោយមានការព្រមព្រៀងជាឯកច្ឆ័ន្ទមជ្ឈត្តករទីបី (៣) ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីការបង្កើតវេទិកាមជ្ឈត្តកម្ម។ មជ្ឈត្តករទីបី (៣) នេះ ត្រូវធ្វើជាប្រធាននៃវេទិកាមជ្ឈត្តកម្ម។

៤.ប្រសិនបើមជ្ឈត្តករណាមួយនៃវេទិកាមជ្ឈត្តកម្មមិនត្រូវបានតែងតាំងក្នុងរយៈពេល ៣០ ថ្ងៃបន្ទាប់ពីការបង្កើតវេទិកាមជ្ឈត្តកម្ម ភាគីនីមួយៗអាចស្នើសុំអគ្គលេខាធិការអង្គការ WTO ឱ្យចាត់តាំងមជ្ឈត្តករមួយ ក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃស្នើសុំ។ ប្រសិនបើ មជ្ឈត្តករមួយ ឬច្រើន ត្រូវបានចាត់តាំងស្របតាមកថាខណ្ឌនេះ អគ្គលេខាធិការអង្គការពាណិជ្ជកម្ម ពិភពលោកត្រូវបានអនុញ្ញាតឱ្យចាត់តាំងជាប្រធាននៃវេទិកាមជ្ឈត្តកម្ម។

៥. ប្រធាននៃវេទិកាមជ្ឈត្តកម្មត្រូវ៖

(ក)មិនមែនជាប្រជាជននៃភាគីនីមួយៗឡើយ;

(ខ) មិនមាននិវេសនដ្ឋាន របស់ខ្លួនក្នុងទឹកដីនៃភាគីនីមួយៗឡើយ; និង

(គ) មិនមានជាប់ពាក់ព័ន្ធជាមួយបញ្ហា/វិវាទ ទោះក្នុងឋានៈខ្លួនជាអ្វីក៏ដោយ។

៦. មជ្ឈត្តករទាំងអស់ត្រូវ៖

(ក)មានជំនាញ ឬបទពិសោធន៍ផ្នែកច្បាប់ ពាណិជ្ជកម្មអន្តរជាតិ បញ្ហាផ្សេងៗទៀតដែលត្រូវបានគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះ ឬសេចក្តីសម្រេចដោះស្រាយវិវាទដែលកើតឡើង ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិ

(ខ)ត្រូវបានជ្រើសរើសយ៉ាងតឹងរ៉ឹងដោយផ្អែកលើមូលដ្ឋានគោលបំណង ភាពអាចជឿទុកចិត្តបាន និងការវិនិច្ឆ័យដែលត្រឹមត្រូវ

(គ)មានឯករាជ្យភាព, និងមិនត្រូវបានជួលដោយ, មិនត្រូវមានទំនាក់ទំនងជាមួយ ឬទទួលបទបញ្ជាពីភាគីនីមួយៗឡើយ

(ឃ)បង្ហាញជូនភាគីទាំងពីរនូវវិវាទ អំពីព័ត៌មានដែលអាចនាំឱ្យមានការសង្ស័យអំពីភាពឯករាជ្យ ឬ ភាពមិនលម្អៀងរបស់ខ្លួន និង

(ង)អនុវត្តតាមក្រមសីលធម៌ដោយអនុលោមតាមវិធានដែលត្រូវបានចែងនៅក្នុងឯកសារ WT/DSB/RC/1 នៃអង្គការ WTO។

៧. ប្រសិនបើមជ្ឈត្តករដែលត្រូវបានតែងតាំងក្រោមមាត្រានេះបានលាលែង ឬមិនអាចធ្វើសកម្មភាពបាន មជ្ឈត្តករជំនួស នឹងត្រូវបានតែងតាំងតាមបែប និងក្នុងថិរវេលាដូចបានរៀបរាប់ សម្រាប់ការតែងតាំងមជ្ឈត្តករដើម ហើយមជ្ឈត្តករជំនួសត្រូវមានអំណាច និងកាតព្វកិច្ចទាំងអស់ នៃមជ្ឈត្តករដើម។ ការងារវេទិកាមជ្ឈត្តកម្មត្រូវបានពន្យាពេលក្នុងអំឡុងពេលនៃការដាក់ជំនួសមជ្ឈត្តករជំនួស។

## មាត្រា ១៤.៨ មុខងារនៃវេទិកាមជ្ឈត្តកម្ម

១. មុខងារនៃវេទិកាមជ្ឈត្តកម្ម គឺដើម្បីវាយតម្លៃគោលបំណងនៃបញ្ហាចំពោះមុខ រួមទាំងការពិនិត្យអង្គហេតុនៃរឿងក្តី និងភាពអាចអនុវត្តបាននៃកិច្ចព្រមព្រៀងនេះ និងអនុលោមភាពជាមួយកិច្ចព្រមព្រៀងនេះ។

២. លើកលែងតែភាគីទាំងពីរព្រមព្រៀងគ្នាដោយឡែកផ្សេងទៀត ក្នុងរយៈពេល ២០ ថ្ងៃគិតចាប់ពីថ្ងៃនៃការបង្កើតវេទិកាមជ្ឈត្តកម្ម តួនាទី និងភារកិច្ចរបស់វេទិកាមជ្ឈត្តកម្មគឺ៖

> "ពិនិត្យ ដោយផ្អែកលើបទប្បញ្ញត្តិពាក់ព័ន្ធនៃកិច្ចព្រមព្រៀងនេះ បញ្ហាដែលបានលើកឡើងនៅក្នុងសំណើសុំបង្កើតវេទិកាមជ្ឈត្តកម្ម ស្របតាមមាត្រា១៤.៦ (ការបង្កើតវេទិកាមជ្ឈត្តកម្ម) និងដើម្បីស្វែងរកអង្គច្បាប់ និងអង្គហេតុ រួមជាមួយនឹងសេចក្តីសម្អាង ក៏ដូចជាអនុសាសន៍ ប្រសិនបើមាន សម្រាប់ដោះស្រាយវិវាទ។"

៣. វេទិកាមជ្ឈត្តកម្មអាចពិគ្រោះយោបល់ជាមួយភាគីវិវាទ និងផ្តល់នូវឱកាសគ្រប់គ្រាន់ សម្រាប់ភាគីវិវាទស្វែងរកនូវដំណោះស្រាយតាមការព្រមព្រៀងទៅវិញទៅមកនៅគ្រប់ពេល។

៤. នៅពេលដែលវេទិកាមជ្ឈត្តកម្មសម្រេចថា វិធានការមួយមិនមានសង្គតិភាពជាមួយកិច្ចព្រមព្រៀងនេះ វេទិកាមជ្ឈត្តកម្មត្រូវផ្តល់អនុសាសន៍ថា ភាគីឆ្លើយតបត្រូវធ្វើឱ្យវិធានការនោះមានអនុលោមភាពជាមួយកិច្ចព្រមព្រៀងនេះ។

៥. វេទិកាមជ្ឈត្តកម្មត្រូវពិចារណាកិច្ចព្រមព្រៀងនេះដោយអនុលោមទៅតាមវិធានទំនៀមទម្លាប់ នៃការបកស្រាយនៃច្បាប់អន្តរជាតិសាធារណៈ។ វេទិកាមជ្ឈត្តកម្ម ក្នុងការស្វែងរក និងអនុសាសន៍ មិនអាចបន្ថែម ឬបន្ថយសិទ្ធិ និងកាតព្វកិច្ចដូចដែលបានផ្តល់ឱ្យក្នុងកិច្ចព្រមព្រៀងនេះឡើយ។

## មាត្រា ១៤.៩ វិធាននៃនីតិវិធីនៃវេទិកាមជ្ឈត្តកម្ម

១. លើកលែងតែភាគីទាំងពីរព្រមព្រៀងគ្នាផ្សេងពីនេះ វេទិកាមជ្ឈត្តកម្ម ត្រូវអនុវត្តតាមវិធាន នៃនីតិវិធីដែលមានចែងនៅក្នុងឧបសម្ព័ន្ធទី៥ (វិធាននៃនីតិវិធីនៃវេទិកាមជ្ឈត្តកម្ម) និងអាចអនុម័តបន្ថែមវិធាននៃនីតិវិធី

ដែលមិនមានសង្គតិភាពជាមួយឧបសម្ព័ន្ធទី៥ (វិធាននៃនីតិវិធីនៃវេទិកាមជ្ឈត្តកម្ម) បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយភាគីទាំងពីរ។

២. លើកលែងតែភាគីទាំងពីរព្រមព្រៀងផ្សេងពីនេះ សោហ៊ុយចំណាយចំពោះមជ្ឈត្តករ និងការចំណាយផ្សេងទៀតដែលពាក់ព័ន្ធនឹងកិច្ចដំណើរការវេទិកាមជ្ឈត្តកម្មត្រូវទទួលបន្ទុកដោយភាគីទាំងពីរក្នុងចំណែកស្មើៗគ្នា។

## មាត្រា ១៤.១០ ការព្យួរ ឬការបញ្ចប់ដំណើរការ

១. វេទិកាមជ្ឈត្តកម្ម អាចព្យួរការងាររបស់ខ្លួនបាននៅពេលដែលមានសំណើសុំពីភាគី ឆ្លើយតប សម្រាប់រយៈពេលមិនលើសពី ១២ ខែ។ វេទិកាមជ្ឈត្តកម្មត្រូវព្យួរការងាររបស់ខ្លួន ប្រសិនបើភាគីទាំងពីរស្នើសុំព្យួរ។ ក្នុងករណីមានការព្យួរ រយៈពេលដែលពាក់ព័ន្ធណាមួយ សម្រាប់ដំណើរការនីតិវិធីមជ្ឈត្តការត្រូវបានពន្យារបន្ថែមក្នុងរយៈពេលដែលការងារត្រូវបានព្យួរ។ ប្រសិនបើ ការងាររបស់វេទិកាមជ្ឈត្តកម្មត្រូវបានព្យួរសម្រាប់រយៈពេលលើសពី ១២ ខែ អំណាចនៃការបង្កើតវេទិកា មជ្ឈត្តកម្មត្រូវបានអស់សុពលភាព លើកលែងតែភាគីព្រមព្រៀងផ្សេងពីនេះ។

២. ភាគីទាំងពីរអាចព្រមព្រៀងបញ្ចប់ដំណើរការវេទិកាមជ្ឈត្តកម្មបាន។

## មាត្រា ១៤.១១ របាយការណ៍នៃវេទិកាមជ្ឈត្តកម្ម

១. វេទិកាមជ្ឈត្តកម្មត្រូវធ្វើរបាយការណ៍របស់ខ្លួនដោយផ្អែកទៅលើ បទប្បញ្ញត្តិពាក់ព័ន្ធក្នុងកិច្ចព្រមព្រៀងនេះ ការដាក់ភស្តុតាង និងអង្គហេតុ និងសម្អាងហេតុ និងព័ត៌មានផ្សេងទៀត ប្រសិនបើមាន ដែលខ្លួនបានទទួលស្របតាមកថាខណ្ឌ ១៤ នៃឧបសម្ព័ន្ធ ៥ (វិធាននៃនីតិវិធីនៃវេទិកាមជ្ឈត្តកម្ម)។

២. វេទិកាមជ្ឈត្តកម្មត្រូវសរសេរចូលទៅក្នុងរបាយការណ៍របស់ខ្លួននូវ៖

(ក) ផ្នែកបរិយាយដោយសង្ខេបអំពីសម្អាងហេតុរបស់ភាគីទាំងពីរនៃវិវាទ និងតតិយភាគី

(ខ) ការរកឃើញរបស់ខ្លួនលើអង្គហេតុនៃរឿងក្តី និងភាពអាចអនុវត្តបាននៃបទប្បញ្ញត្តិ នៃកិច្ចព្រមព្រៀងនេះ

(គ) សេចក្តីសម្រេចរបស់ខ្លួនថាតើ៖

(i) វិធានការដែលមានបញ្ហា គឺមិនអនុលោមជាមួយនឹងកាតព្វកិច្ចដែលមានចែងក្រោមកិច្ចព្រមព្រៀងនេះ ឬ

(ii) ភាគីឆ្លើយតបខកខានបំពេញកាតព្វកិច្ចរបស់ខ្លួនដែលមានចែងនៅក្រោម កិច្ចព្រមព្រៀងនេះ

(ឃ) សេចក្តីសម្អាង សម្រាប់ការស្វែងរក និងសេចក្តីសម្រេចដូចមានចែងនៅក្នុងវាក្យខណ្ឌ (ខ) និង (គ)។

៣. នីតិវិធីនៃវេទិកាមជ្ឈត្តកម្មគួរតែផ្តល់នូវភាពបត់បែនគ្រប់គ្រាន់ ដើម្បីធានាឱ្យបាននូវរបាយការណ៍ដែលមានគុណភាពខ្ពស់ ខណៈពេលដែលភាពបត់បែននេះមិនមានពន្យាពេលដំណើរការជំនុំជម្រះដោយមិនសមរម្យ។

៤. លើកលែងតែភាគីវិវាទព្រមព្រៀងផ្សេងពីនេះ វេទិកាមជ្ឈត្តកម្ម ត្រូវចេញរបាយការណ៍បឋមជូនភាគីទាំងពីរក្នុងអំឡុងពេល ១២០ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបង្កើត ឬក្នុងអំឡុងពេល ៩០ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបង្កើត ក្នុងករណីនៃបញ្ហាបន្ទាន់ទាក់ទង នឹងទំនិញងាយខូច។

៥. ក្នុងករណីលើកលែង ប្រសិនបើវេទិកាមជ្ឈត្តកម្មពិចារណាថាមិនអាចចេញរបាយការណ៍បឋមរបស់ខ្លួនក្នុងអំឡុងពេល ១២០ ថ្ងៃ ឬក្នុងអំឡុងពេល ៩០ ថ្ងៃ ក្នុងករណីបញ្ហាបន្ទាន់ទាក់ទងនឹងទំនិញងាយខូច វេទិកាមជ្ឈត្តកម្មត្រូវជូនដំណឹងទៅភាគីទាំងពីរជាលាយលក្ខណ៍អក្សរនូវហេតុផល សម្រាប់ការពន្យាពេលជាមួយនឹងការប៉ាន់ស្មាននូវថិរវេលាដែលវេទិកាអំឡុងពេលសមរម្យនេះនឹងចេញរបាយការណ៍របស់ខ្លួន។ ការពន្យាពេលណាមួយមិនត្រូវលើសពី ៣០ ថ្ងៃឡើយ លើកលែងតែភាគីទាំងពីរព្រមព្រៀងផ្សេងពីនេះ។

៦. ភាគីនីមួយៗអាចដាក់មតិជាលាយលក្ខណ៍អក្សរទៅវេទិកាមជ្ឈត្តកម្មក្នុងអំឡុងពេល ១៥ ថ្ងៃចាប់ពីកាលបរិច្ឆេទនៃការចេញរបាយការណ៍បឋម។ បន្ទាប់ពីបានពិនិត្យលើមតិជាលាយលក្ខណ៍អក្សរទាំងនោះដែលលើកឡើងដោយភាគីទាំងពីរ និងធ្វើការត្រួតពិនិត្យជាបន្ថែមណា ដែលខ្លួនពិចារណា ថាត្រឹមត្រូវវេទិកាមជ្ឈត្តកម្មត្រូវបង្ហាញជូនភាគីទាំងពីរនូវរបាយការណ៍ចុងក្រោយរបស់ខ្លួនក្នុងអំឡុងពេល ៣០ ថ្ងៃចាប់ពីកាលបរិច្ឆេទនៃការចេញរបាយការណ៍បឋម លើកលែងតែភាគីទាំងពីរព្រមព្រៀងផ្សេងពីនេះ។

៧. វេទិកាមជ្ឈត្តកម្មត្រូវខិតខំប្រឹងប្រែងធ្វើសេចក្តីសម្រេចរបស់ខ្លួនដោយមានការព្រមព្រៀងជាឯកច្ឆ័ន្ទ។ ប្រសិនបើវេទិកាមជ្ឈត្តកម្ម មិនអាចឈានដល់ការព្រមព្រៀងជាឯកច្ឆ័ន្ទ សេចក្តីសម្រេចត្រូវធ្វើឡើងដោយសម្លេងបោះឆ្នោតតាមមតិភាគច្រើន។ មជ្ឈត្តករទាំងអស់ត្រូវផ្តល់នូវយោបល់ដាច់ដោយឡែកពីគ្នាលើបញ្ហាដែលមិនបានព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទ។ យោបល់ទាំងអស់ ដែលបានផ្តល់ដោយមជ្ឈត្តករនីមួយៗ នៅក្នុងរបាយការណ៍របស់វេទិកាមជ្ឈត្តកម្មត្រូវបានទុកជា អនាមិក។

៨. របាយការណ៍ចុងក្រោយរបស់វេទិកាមជ្ឈត្តកម្ម គឺស្ថាពរ និងមានអានុភាពចងកាតព្វកិច្ចតែចំពោះភាគីទាំងពីរ និងចំពោះតែបញ្ហាដែលរបាយការណ៍សំដៅដល់ ក្រោមកិច្ចព្រមព្រៀងនេះតែប៉ុណ្ណោះ។

៩. លើកលែងតែភាគីណាមួយមិនយល់ព្រម របាយការណ៍ចុងក្រោយត្រូវចេញជាសាធារណៈ ក្នុងរយៈពេល ១៥ ថ្ងៃ បន្ទាប់ពីការចេញរបាយការណ៍ជូនភាគីទាំងពីរ ក៏ប៉ុន្តែត្រូវមានការការពារព័ត៌មានសម្ងាត់។

## មាត្រា ១៤.១២ ការអនុវត្តរបាយការណ៍ស្ថាពររបស់វេទិកាមជ្ឈត្តកម្ម

១. នៅពេលដែលវេទិកាមជ្ឈត្តកម្មសម្រេចថាភាគីមួយមិនបានអនុលោមតាមទាំងស្រុង ឬផ្នែកណាមួយនៃកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងនេះ ដំណោះស្រាយ គឺត្រូវតែបំបាត់ចោលភាពមិនអនុលោមទាំងនោះ ពេលណាដែលអាចធ្វើបាន។

២. ភាគីឆ្លើយតបត្រូវអនុវត្តតាមអនុសាសន៍ និងសេចក្តីសម្រេចក្នុងរបាយការណ៍ចុងក្រោយរបស់វេទិកាមជ្ឈត្តកម្ម លើកលែងតែមានការឯកភាពគ្នារវាងភាគីទាំងពីរអំពីសំណង ឬដំណោះស្រាយដោយពេញចិត្តទៅវិញទៅមក។

៣. ក្នុងកំឡុងពេល ៣០ ថ្ងៃចាប់ពីកាលបរិច្ឆេទនៃការចេញរបាយការណ៍ចុងក្រោយរបស់វេទិកាមជ្ឈត្តកម្មទៅភាគីទាំងពីរ ភាគីឆ្លើយតបត្រូវជូនដំណឹងទៅភាគីតវ៉ាអំពីឆន្ទៈរបស់ខ្លួនក្នុងការអនុវត្តតាមរបាយការណ៍ចុងក្រោយនោះ ថែមទាំង៖

(ក) ត្រូវជូនដំណឹងទៅភាគីតវ៉ាភ្លាមៗ ប្រសិនបើភាគីឆ្លើយតបគិតថាខ្លួនបានគោរពតាមកាតព្វកិច្ចក្នុងកថាខណ្ឌ ១ នៃមាត្រានេះ។ ភាគីឆ្លើយតបត្រូវបញ្ជាក់នូវការបរិយាយ អំពីវិធានការណាមួយដែលខ្លួនគិតថាបានធ្វើស្របតាមការអនុវត្តកាតព្វកិច្ច កាលបរិច្ឆេទ នៃការចូលជាធរមាននៃវិធានការនោះ ព្រមទាំងអត្ថបទរបស់វិធានការនោះផងដែរ ប្រសិនបើមាន។ ឬក៏

(ខ) បើមានការលំបាកក្នុងការអនុវត្តតាមកាតព្វកិច្ចក្នុងកថាខណ្ឌ ១ នៃមាត្រានេះភ្លាមៗទេ ភាគីឆ្លើយតប ត្រូវជូនដំណឹងទៅភាគីតវ៉ាអំពីអំឡុងពេលសមរម្យណាមួយដែលខ្លួនត្រូវការក្នុងគោរពតាមកាតព្វកិច្ចក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ជាមួយនឹងការបញ្ជាក់អំពីសកម្មភាពដែលខ្លួនអាចនឹងអនុវត្ត។

## មាត្រា ១៤.១៣ អំឡុងពេលសមរម្យ

១. អំឡុងពេលសមរម្យដែលបានប្រើក្នុងមាត្រា ១៤.១២ (ការអនុវត្តរបាយការណ៍ស្ថាពររបស់វេទិកាមជ្ឈត្តកម្ម) ត្រូវកំណត់ដោយមានការយល់ព្រម រវាងភាគីទាំងពីរ។ ពេលដែលភាគីទាំងពីរមិនអាចព្រមព្រៀងគ្នាទៅលើការកំណត់អំឡុងពេលសមរម្យបានទេ ក្នុងកំឡុងពេល ៤៥ ថ្ងៃចាប់ពីថ្ងៃចេញរបាយការណ៍ចុងក្រោយរបស់វេទិកាមជ្ឈត្តកម្ម ភាគីនីមួយៗ តាមតែអាចធ្វើទៅបាន អាចបញ្ជូនរឿងក្តីទៅវេទិកាមជ្ឈត្តកម្មដើម ដើម្បីសម្រេចអំពីអំឡុងពេលសមរម្យនោះ។

២. វេទិកាមជ្ឈត្តកម្មត្រូវផ្តល់សេចក្តីសម្រេចទៅភាគីទាំងពីរក្នុងកំឡុងពេល ៦០ ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទបញ្ជូនរឿងក្តីទៅដល់ខ្លួន។ កាលបើវេទិកាមជ្ឈត្តកម្មពិចារណាថាខ្លួនមិនអាចផ្តល់របាយការណ៍របស់ខ្លួនទាន់ពេលវេលា វេទិកាមជ្ឈត្តកម្មត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីហេតុផលនៃ ការពន្យាពេលជាមួយនឹងការប៉ាន់ស្មាននូវថិរវេលាដែលខ្លួននឹងផ្តល់សេចក្តីសម្រេច។ ការពន្យារពេលណាមួយមិនត្រូវលើសពី ៣០ ថ្ងៃឡើយ លើកលែងតែភាគីទាំងពីរព្រមព្រៀងផ្សេងពីនេះ។

៣. អំឡុងពេលសមរម្យ ជាធម្មតាមិនត្រូវលើសពី ១៥ ខែនោះទេ ចាប់ពីកាលបរិច្ឆេទចេញរបាយការណ៍របស់វេទិកាមជ្ឈត្តកម្ម។

## មាត្រា ១៤.១៤ ការត្រួតពិនិត្យលើការអនុវត្តកាតព្វកិច្ច

១. កាលណាដែលមានការខ្វែងគំនិតគ្នានៅក្នុងកិច្ចព្រមព្រៀងនេះ អំពីវត្តមាន ឬសង្គតិភាពនៃវិធានការដែលបានធ្វើឡើង ដើម្បីអនុវត្តតាមអនុសាសន៍ និងសេចក្តីសម្រេចរបស់វេទិកាមជ្ឈត្តកម្ម វិវាទនោះត្រូវ

ដោះស្រាយតាមរយៈដំណើរការនីតិវិធីដោះស្រាយវិវាទក្រោមជំពូកនេះ រួមទាំងការដោះស្រាយនៅវេទិកាមជ្ឈត្តកម្មដើម កាលបើអាចធ្វើបាន។

២. វេទិកាមជ្ឈត្តកម្មត្រូវផ្តល់របាយការណ៍ទៅភាគីទាំងពីរក្នុងអំឡុងពេល ៦០ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទបញ្ជូនរឿងក្តីទៅដល់ខ្លួន។ កាលបើវេទិកាមជ្ឈត្តកម្មពិចារណាថាខ្លួនមិនអាចផ្តល់របាយការណ៍របស់ខ្លួនទាន់ពេលវេលានោះទេ វេទិកាមជ្ឈត្តកម្មត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីហេតុផលនៃការពន្យាពេលជាមួយនឹងការប៉ាន់ស្មាននូវថិរវេលាដែលខ្លួននឹងផ្តល់សេចក្តីសម្រេច។ ការពន្យាពេលណាមួយ មិនត្រូវលើសពី ៣០ ថ្ងៃឡើយ លើកលែងតែភាគីទាំងពីរព្រមព្រៀងផ្សេងពីនេះ។

៣. បទប្បញ្ញត្តិក្នុងជំពូកនេះ ទាក់ទងនឹងនីតិវិធីនៃវេទិកាមជ្ឈត្តកម្មត្រូវអនុវត្តដូចគ្នាចំពោះនីតិវិធីក្រោមមាត្រានេះ។

## មាត្រា ១៤.១៥ សំណង និងការព្យួរសម្បទាន ឬកាតព្វកិច្ចផ្សេងទៀត

១. ការសង ការព្យួរសម្បទាន ឬកាតព្វកិច្ចផ្សេងទៀត គឺជាវិធានការបណ្តោះអាសន្ន ដែលអាចកើតឡើងបាន ក្នុងករណីដែលភាគីឆ្លើយតបខកខានក្នុងការអនុវត្តកាតព្វកិច្ចក្រោមមាត្រា ១៤.១២ (ការអនុវត្តរបាយការណ៍ស្ថាពររបស់វេទិកាមជ្ឈត្តកម្ម) នៅក្នុងអំឡុងពេលសមរម្យ។ ទោះបីជាយ៉ាងណាក៏ដោយ ទាំងសំណង ឬការព្យួរសម្បទាន ឬកាតព្វកិច្ចផ្សេងទៀត មិនមែនជាជម្រើសប្រសើរ ក្នុងការអនុលោមតាមកាតព្វកិច្ចក្នុងមាត្រា ១៤.១២ (ការអនុវត្តរបាយការណ៍ស្ថាពររបស់វេទិកាមជ្ឈត្តកម្ម) ឡើយ។ ការដាក់សំណងគឺធ្វើឡើងដោយស្ម័គ្រចិត្ត និងប្រសិនជាតម្រូវ ត្រូវអនុលោមតាមកិច្ចព្រមព្រៀងនេះ។

២. ភាគីឆ្លើយតប ត្រូវធ្វើការចរចាតបតាមការស្នើសុំរបស់ភាគីតវ៉ា ក្នុងស្មារតីដែលអាចឈានដល់ការឯកភាពទាំងសងខាងនូវសំណង នៅពេលណាដែល៖

(ក) ភាគីឆ្លើយតប បានជូនដំណឹងទៅភាគីតវ៉ា ថាខ្លួនមិនមានចេតនានឹងអនុវត្តកាតព្វកិច្ច ក្រោមកថាខណ្ឌ ១ នៃមាត្រា ១៤.១២ (ការអនុវត្តរបាយការណ៍ស្ថាពររបស់វេទិកាមជ្ឈត្តកម្ម)

(ខ) ភាគីឆ្លើយតប ខកខានក្នុងការជូនដំណឹងទៅភាគីតវ៉ា អនុលោមតាមកថាខណ្ឌ ៣ នៅមាត្រា ១៤.១២ (ការអនុវត្តរបាយការណ៍ស្ថាពររបស់វេទិកាមជ្ឈត្តកម្ម) ឬ

(គ) គណៈកម្មការត្រួតពិនិត្យការអនុវត្តកាតព្វកិច្ចសម្រេចថា ភាគីឆ្លើយតបខកខានក្នុងការអនុវត្តកាតព្វកិច្ចក្រោមកថាខណ្ឌ ១ នៃមាត្រា ១៤.១២ (ការអនុវត្តរបាយការណ៍ស្ថាពររបស់វេទិកាមជ្ឈត្តកម្ម) អនុលោមតាមមាត្រា ១៤.១៤ (ការត្រួតពិនិត្យលើការអនុវត្តកាតព្វកិច្ច)។

៣. ប្រសិនបើភាគីទាំងពីរ៖

(ក) មិនអាចព្រមព្រៀងគ្នាអំពីសំណងក្នុងកំឡុងពេល ៣០ថ្ងៃ ចាប់ពីថ្ងៃទទួលបានសំណើ ដែលបានស្នើសុំស្របតាមកថាខណ្ឌ ២ ឬ

(ខ)បានព្រមព្រៀងគ្នាអំពីសំណង ប៉ុន្តែភាគីឆ្លើយតបខកខានពុំបានប្រតិបត្តិតាមលក្ខខណ្ឌនៃការព្រមព្រៀងនោះទេ

ភាគីតវ៉ា នៅបន្ទាប់ពីនោះមក ត្រូវជូនដំណឹងទៅភាគីឆ្លើយតប ថាខ្លួនមានចេតនាព្យួរការអនុវត្តសម្បទាន ឬកាតព្វកិច្ចរបស់ខ្លួនចំពោះភាគីឆ្លើយតប សមមូលទៅនឹងកម្រិតនៃមោឃៈកម្ម ឬការខូចខាត ហើយភាគីតវ៉ាមានសិទ្ធិចាប់ផ្តើមការព្យួរសម្បទាន ឬកាតព្វកិច្ចផ្សេងទៀត ៣០ ថ្ងៃ ក្រោយពីកាលបរិច្ឆេទបានទទួលការជូនដំណឹង។

៤. បើទោះបីជាមានចែងក្នុងកថាខណ្ឌ ៣ ក៏ដោយ ភាគីតវ៉ាពុំអាចប្រើប្រាស់សិទ្ធិ ដើម្បីចាប់ផ្តើមការព្យួរសម្បទាន ឬកាតព្វកិច្ចផ្សេងទៀត ដូចក្រោមកថាខណ្ឌនោះបានទេ នៅពេលដែល៖

(ក)ការត្រួតពិនិត្យកំពុងដំណើរការស្របតាមកថាខណ្ឌ ៣ ដល់កថាខណ្ឌ ១០ ឬ

(ខ)សម្រេចបាននូវដំណោះស្រាយដែលព្រមព្រៀងគ្នាទៅវិញទៅមក។

៥. ការជូនដំណឹងស្របតាមកថាខណ្ឌ ៣ ត្រូវបញ្ជាក់ច្បាស់លាស់អំពីកម្រិតនៃការព្យួរសម្បទាន ឬកាតព្វកិច្ចផ្សេងទៀតដែលខ្លួនមានចេតនាធ្វើ និងត្រូវបង្ហាញពីវិស័យដែលភាគីតវ៉ាស្នើសុំព្យួរ នោះ។

៦. កម្រិតនៃការព្យួរសម្បទាន ឬកាតព្វកិច្ចផ្សេងទៀត ត្រូវសមមូលទៅនឹងកម្រិតនៃមោឃៈកម្ម ឬការខូចខាត។

៧. ក្នុងការពិចារណាថាសម្បទាន ឬកាតព្វកិច្ចណាផ្សេងទៀតដែលត្រូវព្យួរ ៖

(ក)ភាគីតវ៉ា គួរតែចាប់ផ្តើមព្យួរសម្បទាន ឬកាតព្វកិច្ចផ្សេងទៀតក្នុងវិស័យដូចគ្នាដែល វេទិកាមជ្ឈត្តកម្មបានសម្រេចថាគ្មានអនុលោមភាព ឬខកខានពុំបានបំពេញកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះ។

(ខ)ប្រសិនបើ ភាគីតវ៉ា ពិចារណាថាមិនអាចអនុវត្តបាន ឬគ្មានប្រសិទ្ធភាពក្នុងការព្យួរ សម្បទាន ឬកាតព្វកិច្ចផ្សេងទៀតក្នុងវិស័យដូចគ្នានោះទេ ភាគីតវ៉ាអាចព្យួរសម្បទាន ឬកាតព្វកិច្ចផ្សេងទៀតក្នុងវិស័យដទៃបាន។ ទំនាក់ទំនងដែលប្រកាសពីការសម្រេចចិត្តនេះ ត្រូវបង្ហាញពីហេតុផលដែលជាមូលដ្ឋាននៃការសម្រេចចិត្តផងដែរ។

៨. តបតាមសំណើជាលាយលក្ខណ៍អក្សររបស់ភាគីឆ្លើយតប វេទិកាមជ្ឈត្តកម្មដើម ត្រូវសម្រេច ថាតើកម្រិតសម្បទាន ឬកាតព្វកិច្ចផ្សេងទៀតដែលនឹងត្រូវព្យួរមានភាពហួសហេតុដែរឬទេ ផ្អែកទៅ លើកថាខណ្ឌ ៦ និង/ឬថាតើកថាខណ្ឌ ៧ មិនត្រូវបានអនុវត្តតាមទេ ឬយ៉ាងណា។ ប្រសិនបើ វេទិកាមជ្ឈត្តកម្មមិនអាចបង្កើតឡើងជាមួយនឹងសមាជិកមជ្ឈត្តករដើមទេ វេទិកាមជ្ឈត្តកម្មនោះត្រូវកំណត់សមាសភាពរបស់ខ្លួន ស្របទៅនឹងនីតិវិធីដែលមានចែងក្នុងមាត្រា ១៤.៧ (សមាសភាពនៃវេទិកាមជ្ឈត្តកម្ម)។

៩. វេទិកាមជ្ឈត្តកម្មត្រូវបង្ហាញប្រាប់ពីសេចក្តីសម្រេចរបស់ខ្លួន ក្នុងអំឡុងពេល ៦០ ថ្ងៃបន្ទាប់ពីការស្នើសុំដែលធ្វើឡើងស្របតាមកថាខណ្ឌ ៨ ឬបន្ទាប់ពីកាលបរិច្ឆេទដែលមជ្ឈត្តករចុងក្រោយត្រូវបានតែងតាំង ប្រសិនបើវេទិកាមជ្ឈត្តកម្មនោះមិនអាចបង្កើតឡើងជាមួយនឹងសមាជិកមជ្ឈត្តករ ដើមទេ ។

១០. ភាគីតវ៉ាមិនអាចព្យួរការអនុវត្តសម្បទាន ឬកាតព្វកិច្ចផ្សេងទៀត មុនពេលការចេញសេចក្តីសម្រេចរបស់វេទិកាមជ្ឈត្តកម្មស្របតាមមាត្រានេះបានទេ។

## មាត្រា ១៤.១៦ ក្រោយការព្យួរ

១. ដោយពុំបង្កផលប៉ះពាល់ដល់នីតិវិធីក្នុងមាត្រា ១៤.១៥ (សំណង និងការព្យួរសម្បទាន ឬកាតព្វកិច្ចផ្សេងទៀត) ភាគីឆ្លើយតប អាចជូនដំណឹងទៅកាន់ ភាគីតវ៉ាជាលាយលក្ខណ៍អក្សរ ជាមួយនឹងការបរិយាយអំពីរបៀបដែលខ្លួនបានលុបបំបាត់ភាពមិនអនុលោម ប្រសិនបើខ្លួនគិតថាបានលុបបំបាត់ភាពមិនអនុលោមដែលវេទិកាមជ្ឈត្តកម្មបានរកឃើញ។ ប្រសិនបើភាគីតវ៉ាមិនយល់ព្រម ភាគីតវ៉ាអាចបញ្ជូនរឿងក្តីទៅកាន់វេទិកាមជ្ឈត្តកម្មដើមក្នុងអំឡុងពេល ៦០ថ្ងៃ បន្ទាប់ពីទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរនោះ។ បើមិនដូច្នោះទេ ភាគីតវ៉ា ត្រូវបញ្ឈប់ការព្យួរ សម្បទាន ឬកាតព្វកិច្ចផ្សេងទៀតនោះភ្លាមៗ។

២. វេទិកាមជ្ឈត្តកម្មត្រូវបញ្ចេញរបាយការណ៍របស់ខ្លួន ក្នុងអំឡុងពេល ៦០ថ្ងៃ បន្ទាប់ពីពេលដែលភាគីតវ៉ាបានបញ្ជូនរឿងក្តីស្របតាមកថាខណ្ឌ ១។ ប្រសិនបើ វេទិកាមជ្ឈត្តកម្មសម្រេចថា ភាគីឆ្លើយតបបានលុបបំបាត់ភាពមិនអនុលោមរួចហើយ ភាគីតវ៉ាត្រូវបញ្ឈប់ការព្យួរសម្បទាន ឬកាតព្វកិច្ចផ្សេងទៀតនោះជាបន្ទាន់។

## មាត្រា ១៤.១៧ សិទ្ធិឯកជន

គ្មានភាគីណាមួយអាចប្រើប្រាស់សិទ្ធិធ្វើបណ្តឹង តាមច្បាប់ជាតិរបស់ខ្លួនប្រឆាំងនឹងភាគីមួយទៀតក្រោមហេតុផលថាវិធានដែលធ្វើឡើងដោយភាគីមួយទៀតនោះ មិនស្របទៅនឹងកិច្ចព្រមព្រៀងនេះទេ។

## ជំពូក ១៥

## ការលើកលែង

### មាត្រា ១៥.១ ការលើកលែងជាទូទៅ

១. សម្រាប់គោលបំណងនៃ ជំពូក២ ស្តីពីពាណិជ្ជកម្មទំនិញ ជំពូក៣ ស្តីពីវិធានដើមកំណើត ជំពូក៤ ស្តីពីនីតិវិធីគយ និងកិច្ចសម្រួលពាណិជ្ជកម្ម ជំពូក៥ ស្តីពីរបាំងបច្ចេកទេសពាណិជ្ជកម្ម ជំពូក៦ ស្តីពីអនាម័យ និងភូតគាមអនាម័យ និងជំពូក១០ ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មាត្រា XX នៃ កិច្ចព្រមព្រៀង GATT ឆ្នាំ ១៩៩៤ រួមទាំងកំណត់សម្គាល់បកស្រាយរបស់វា ត្រូវបានបញ្ចូលទៅក្នុង និងក្លាយជាផ្នែកនៃកិច្ចព្រមព្រៀងនេះ ដោយត្រូវយកមកអនុវត្តតាមទាំងស្រុង ។

២. សម្រាប់គោលបំណងនៃជំពូក៧ ស្តីពីពាណិជ្ជកម្មសេវាកម្ម និងជំពូក១០ ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកមាត្រា XIV នៃកិច្ចព្រមព្រៀង GATS រួមទាំងលេខយោង ត្រូវបានដាក់បញ្ចូលទៅក្នុងកិច្ចព្រមព្រៀងនេះ និងក្លាយជាផ្នែកនៃកិច្ចព្រមព្រៀងនេះ ដោយត្រូវយកមកអនុវត្តតាមទាំងស្រុង ។

### មាត្រា ១៥.២ ភាពចាំបាច់ផ្នែកសន្តិសុខ

មាត្រា XXI នៃកិច្ចព្រមព្រៀង GATT ឆ្នាំ 1994 និងមាត្រា XIV bis នៃកិច្ចព្រមព្រៀង GATS ត្រូវបានបញ្ចូលទៅក្នុងកិច្ចព្រមព្រៀងនេះ និងក្លាយជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ ដោយត្រូវយកមកអនុវត្តតាមទាំងស្រុង ។

### មាត្រា ១៥.៣ ពន្ធដារ

១. សម្រាប់គោលបំណងនៃមាត្រានេះ៖

(ក)អនុសញ្ញាស្តីពីពន្ធដារ សំដៅដល់ អនុសញ្ញាសម្រាប់ការចៀសវាងការយកពន្ធត្រួតគ្នា ឬកិច្ចព្រមព្រៀងពន្ធអន្តរជាតិផ្សេងៗទៀត ឬការរៀបចំដែលភាគីទាំងពីរជាភាគី;

(ខ)វិធានការពន្ធដារ មិនរាប់បញ្ចូលពន្ធគយដែលបានកំណត់ក្នុងមាត្រា ២.២ (និយមន័យ)។

២. លើកលែងតែមានការចែងផ្សេងនៅក្នុងមាត្រានេះ គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះត្រូវអនុវត្តចំពោះវិធានការពន្ធដារឡើយ។

៣. (ក)គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាំងពីរ ក្រោមអនុសញ្ញាស្តីពីពន្ធដារដែលភាគីទាំងពីរជាភាគីឡើយ។ ក្នុងករណី មានភាពអសង្គតិភាព ពាក់ព័ន្ធនឹងវិធានការពន្ធដាររវាងកិច្ចព្រមព្រៀងនេះ និងអនុសញ្ញាណាមួយ អនុសញ្ញាណាមួយនោះ នឹងមានអនុភាពលុបត្រឹមកម្រិតនៃអសង្គតិភាពនោះ។

(ខ)ក្នុងករណីដែលមានអនុសញ្ញាស្តីពីពន្ធដាររវាងភាគីទាំងពីរ អាជ្ញាធរមានសមត្ថកិច្ចដែលស្ថិតនៅក្រោមអនុសញ្ញានោះ ត្រូវមានទំនួលខុសត្រូវទាំងស្រុងក្នុងការកំណត់ថាតើមានភាពអសង្គតិភាពរវាងកិច្ចព្រមព្រៀងនេះ និងអនុសញ្ញានោះដែរឬទេ។

៤. បើទោះបីជាមានកថាខណ្ឌ ៣ ខាងលើក៏ដោយ កិច្ចព្រមព្រៀងនេះ ផ្តល់សិទ្ធិ ឬដាក់កាតព្វកិច្ចពាក់ព័ន្ធនឹងវិធានការពន្ធត្រឹមកម្រិតដែលសិទ្ធិ ឬកាតព្វកិច្ចនេះត្រូវបានផ្តល់ ឬដាក់នៅក្រោមកិច្ចព្រមព្រៀងស្តីពីអង្គការ WTO ប៉ុណ្ណោះ។

៥. សម្រាប់គោលបំណងនៃមាត្រានេះ អាជ្ញាធរមានសមត្ថកិច្ច ៖

ក. ចំពោះភាគីចិន សំដៅដល់ ក្រសួងហិរញ្ញវត្ថុ និងរដ្ឋបាលពន្ធដាររដ្ឋ; និង

ខ. ចំពោះភាគីកម្ពុជា សំដៅដល់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## មាត្រា ១៥.៤ ការបញ្ចេញព័ត៌មាន

គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយក្នុងន័យតម្រូវឱ្យភាគីណាមួយផ្តល់ ឬអនុញ្ញាតឱ្យទទួលបានព័ត៌មានសម្ងាត់ ដែលការបញ្ចេញព័ត៌មានទាំងនេះ នឹងរារាំងដល់ការអនុវត្តច្បាប់ ឬផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ ឬប៉ះពាល់ដល់ផលប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់របស់សហគ្រាសណាមួយ ទោះបីជាសហគ្រាសនេះជាសហគ្រាសសាធារណៈ ឬជាសហគ្រាសឯកជនក៏ដោយ។

## មាត្រា ១៥.៥ ការរក្សាការសម្ងាត់

លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ នៅពេលភាគីណាមួយផ្តល់ព័ត៌មានទៅ ភាគីមួយទៀត ដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ និងដោយបានចាត់ថ្នាក់ថាព័ត៌មាននេះ ជាព័ត៌មានសម្ងាត់ ភាគីមួយទៀតនោះ ត្រូវរក្សាការសម្ងាត់នៃព័ត៌មាននេះ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន។

## មាត្រា ១៥.៦ វិធានការការពារជញ្ជីងទូទាត់

នៅពេលដែលភាគីមួយ កំពុងស្ថិតក្នុងភាពធ្ងន់ធ្ងរនៃជញ្ជីងទូទាត់ និងហិរញ្ញវត្ថុធ្ងន់ធ្ងរ ឬការគម្រាមកំហែងនៃស្ថានភាពទាំងនោះ ភាគីនោះ អាចអនុម័តវិធានការនានាដែលចាំបាច់ ដោយអនុលោម តាមកិច្ចព្រមព្រៀងស្តីពីអង្គការ WTO និងស្របតាមមាត្រានានានៃកិច្ចព្រមព្រៀង របស់មូលនិធិរូបិយវត្ថុអន្តរជាតិ។

# ជំពូក ១៦

# អវសានប្បញ្ញត្តិ

## មាត្រា ១៦.១ ឧបសម្ព័ន្ធ និងលេខយោង

ឧបសម្ព័ន្ធ និងលេខយោងនៃកិច្ចព្រមព្រៀងនេះ គឺជាផ្នែកសារជាតុមួយនៃកិច្ចព្រមព្រៀងនេះ។

## មាត្រា ១៦.២ ការចូលជាធរមាន

កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមានក្នុងរយៈពេល ៣០ ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទដែលភាគីទាំងពីរផ្លាស់ប្តូរសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរតាមរយៈបណ្តាញការទូតដោយបញ្ជាក់ថាភាគីទាំងពីរ បានបញ្ចប់នូវលក្ខខណ្ឌតម្រូវផ្ទៃក្នុងចាំបាច់នានារបស់ខ្លួន ឬនៅកាលបរិច្ឆេទផ្សេងទៀតដូចជា ភាគីទាំងពីរឯកភាពគ្នា។

## មាត្រា ១៦.៣ វិសោធនកម្ម

១. ភាគីទាំងពីរ អាចយល់ព្រមជាលាយលក្ខណ៍អក្សរ ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងនេះ។ ការធ្វើវិសោធនកម្មណាមួយ ត្រូវចូលជាធរមាន ដោយអនុលោមតាមនីតិវិធីដែលតម្រូវ សម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។

២. ប្រសិនបើបទប្បញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងស្តីពីអង្គការ WTO ឬនៃកិច្ចព្រមព្រៀងណាមួយដែលភាគីទាំងពីរជាភាគី ដែលបានបញ្ចូលទៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានធ្វើវិសោធនកម្ម ភាគីទាំងពីរត្រូវពិគ្រោះយោបល់គ្នាថាតើត្រូវធ្វើវិសោធនកម្មកិច្ចព្រមព្រៀងនេះ ឬយ៉ាងណា លើកលែងតែកិច្ចព្រមព្រៀងនេះបានចែងផ្សេង។

## មាត្រា ១៦.៤ ការបញ្ចប់កិច្ចព្រមព្រៀង

១. កិច្ចព្រមព្រៀងនេះ ត្រូវបន្តអនុវត្តរហូតដល់ភាគីណាមួយជូនដំណឹងទៅភាគីមួយទៀតជាលាយលក្ខណ៍អក្សរដើម្បីបញ្ចប់កិច្ចព្រមព្រៀងនេះ។ ការបញ្ចប់នេះ ត្រូវមានអនុភាពអនុវត្តក្នុងរយៈពេល ១៨០ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលការជូនដំណឹងនេះ។

២. ក្នុងរយៈពេល ៣០ ថ្ងៃនៃការជូនដំណឹងដូចចែងក្នុងកថាខណ្ឌ ១ ភាគីណាមួយក៏បានអាច ស្នើសុំការពិគ្រោះយោបល់ ថាតើការបញ្ចប់នៃបទប្បញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះ ត្រូវមាន អនុភាពអនុវត្ត នៅកាលបរិច្ឆេទក្រោយកាលបរិច្ឆេទដែលត្រូវបានចែងក្នុងកថាខណ្ឌ ១ ឬយ៉ាងណា។ ការពិគ្រោះយោបល់នេះត្រូវចាប់ផ្តើមក្នុងរយៈពេល ៣០ ថ្ងៃ ចាប់ពីកាលបរិច្ឆេទទទួលសំណើបញ្ចប់នេះ។

## មាត្រា ១៦.៥ អត្ថបទដើម

កិច្ចព្រមព្រៀងនេះ ត្រូវធ្វើឡើងជាភាសាខេមរភាសា ភាសាចិន និងភាសាអង់គ្លេស។ អត្ថបទទាំងអស់មានសុពលភាព និងត្រឹមត្រូវដូចគ្នា។ ក្នុងករណីមានភាពខុសគ្នាណាមួយ អត្ថបទជាភាសាអង់គ្លេស ត្រូវយកជាអត្ថបទគោល។

ដើម្បីជាសក្ខីភាព អ្នកតំណាងស្របច្បាប់ដែលបានទទួលសិទ្ធិពេញសមត្ថភាពពីរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

ធ្វើជាពីរច្បាប់នៅប៉េកាំង និងភ្នំពេញ ដោយឡែកពីគ្នា ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ដោយភាគីនីមួយៗរក្សាទុកច្បាប់ដើមជាខេមរភាសា ភាសាចិន និងភាសាអង់គ្លេស។

| | |
|---|---|
| **សម្រាប់រាជរដ្ឋាភិបាល** | **សម្រាប់រដ្ឋាភិបាល** |
| **នៃព្រះរាជាណាចក្រកម្ពុជា** | **នៃសាធារណរដ្ឋប្រជាមានិតចិន** |